ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ឈុយ ម៉ិន : ជីវិតជួបជិត្ត
- ត្រូវការធ្វើដំណើរឆ្ពោះទៅមុខ ក្រឡេកមើលក្រោយ

[illegible]

លេខ[illegible] ខែ[illegible] ឆ្នាំ[illegible]

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤៨ ខែសីហា ឆ្នាំ២០០៣

## មាតិកា


- សំបុត្រ៖ មិនត្រូវទម្លាក់កំហុស ..........................................១

**ផ្នែកឯកសារ**

- ពេញ ធួក ហៅ សុក ហៅ វន វើត ..................................២
- បំពាក់ទស្សនៈនិងគោលជំហរមួយចំនួនក្នុងការផ្សារសន្តិបាល .........៥
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- ទុយ គិន ៖ ជំងឺផ្លូវចិត្ត ...............................................១៤
- តើសម្លាប់មនុស្សច្រើនយ៉ាងនេះដើម្បីអ្វី? ..........................១៧
- មិនចង់នឹកឃើញការឈឺចាប់ ..........................................១៩
- កាន់កន្ត្រៃមានសុភមង្គលជាងកាន់កាំភ្លើង ............................២២
- ម៉េង សុខុម៖ កម្មាភិបាលពេទ្យខ្មែរក្រហម ...........................២៤
- ធ្វើដែនទីវាលពិឃាត.....................................................២៨

**ផ្នែកច្បាប់**

- តុលាការពិសេសនៅប្រទេសសេរ៉ាឡេអូន......................... ៤០

**វេទិកាពិភាក្សាសាធារណៈ**

- ក្នុងការធ្វើដំណើរឆ្ពោះទៅមុខ ត្រូវងាកមើលក្រោយ...............៤៦
- របាយការណ៍ស្តីអំពីកិច្ចពិភាក្សា...................................... ៤៨

**ទំព័រស្វែងរកគ្រួសារ**

- ខ្ញុំរងគ្រោះព្រោះមេដឹកនាំអន្យត្តិរ្តិយ៍.................................. ៥២






ទុយ គិន

# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ៖** ប៉ាង ពីវីន, សុខ វណ្ណៈ, យិន នាន, ព្រំ ផល្លា, ផេង ពង្សរ៉ាស៊ី, ចន ឆរធីអារី, ស៊ូហ្សាណា លីនគុន, អាឡិច បូរេន, ប៉ូល វ៉ាន់ហ្សីលអ៊ីត, ឆាយ ហុកផេង, សង ហេង, **អ្នកនិពន្ធនិងស្រាវជ្រាវ៖** លី សុផល, សើ សាយ្យាណា **ជំនួយការនិពន្ធនាយក៖** សាន់ កល្យាណ **និពន្ធនាយករង៖** សួ ប៊ុនស៊ូ **អ្នកបកប្រែ៖** អេង កុកថាយ **និពន្ធនាយកទូទៅ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ីម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ៖** មាស ប៊ុនថាន

*សំបុត្រ:*

# មិនត្រូវទម្លាក់កំហុស

យុវវ័យកម្ពុជាគួរតែរៀនសូត្រឲ្យបានច្បាស់លាស់អំពីអតីតកាលរបស់ខ្លួនដើម្បីជៀសវាងការប្រព្រឹត្តិកំហុសដែលធ្លាប់មានពីមុនមក ។ ការសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រគឺជាប្រទីបបំភ្លឺផ្លូវបច្ចុប្បន្នសម្រាប់ឲ្យយើងដើរទៅរកសុភមង្គលរុងរឿងនៅក្នុងថ្ងៃអនាគត ។ ការសិក្សាអំពីប្រវត្តិសាស្ត្រគឺពុំមែនជាការចងកំហឹងគុំគួន ។

វាគឺពុំមែនជាការត្រឹមត្រូវទេក្នុងការទម្លាក់កំហុសគ្រប់យ៉ាងនាពេលបច្ចុប្បន្ននេះទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ហើយវាគឺជាកំហុសដ៏ធ្ងន់ធ្ងរបំផុតមួយប្រសិនបើយើងប្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមមិនឲ្យបន្ទោសមេដឹកនាំខ្មែរក្រហម ឬក៏ឲ្យមានការអត់ឱនដល់ជនដៃដល់ដោយគ្មានតុលាការកាត់សេចក្ដីត្រឹមត្រូវឬប្រាប់ជនរងគ្រោះឲ្យបំភ្លេចការឈឺចាប់និងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមដោយគ្មានការសិក្សាអប់រំបញ្ហានេះនៅក្នុងថ្នាក់រៀនដល់យុវវ័យកម្ពុជាជំនាន់ក្រោយ ។


ឆាំង យុ

អ្វីដែលយើងមានលទ្ធភាពធ្វើបាននៅក្នុងពេលនេះគឺបង្កលក្ខណៈនិងផ្ដល់ជាវិធីសាស្ត្រផ្សេងៗសម្រាប់ឲ្យជនរងគ្រោះនិងជនដៃដល់ស្វែងរកដំណោះស្រាយបញ្ហាយុត្តិធម៌របស់ខ្លួនដោយខ្លួនឯងផ្ទាល់ដើម្បីឈានទៅដល់ការអត់ឱន ហើយនិងអាចចាត់ទុកអំពើព្រៃផ្សៃទាំងអម្បាលម៉ាននោះជារឿងរ៉ាវប្រវត្តិសាស្ត្រ ដើម្បីឲ្យអ្នកទាំងពីរមានសេរីភាពក្នុងការធ្វើដំណើរទៅរកអនាគត ។

រឿងរ៉ាវដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម គឺជារបួសនៅក្នុងបេះដូង វាមិនមែនជាដំបៅនៅលើស្បែកដែលអាចព្យាបាលដោយថ្នាំសង្កូវ ។ របួសនៅក្នុងបេះដូងគឺតម្រូវឲ្យមានការព្យាបាលតាមរយៈការអត់ឱន ។ ជនរងគ្រោះអាចនឹងអត់ឱន ឬក៏ត្រៀមខ្លួនជាស្រេច ក្នុងការអត់ឱនដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើឃោរឃៅមកលើខ្លួន ដរាបណាខ្លួនបានដឹងជាមុនថាតើអ្នកណាខ្លះគួរត្រូវបានអត់ឱនទោសហើយនៅក្រោមបទល្មើសអ្វី ។ ការអត់ឱនគឺត្រូវតែបានធ្វើឡើងតាមរយៈការវិនិច្ឆ័យទោសនិងការកាត់សេចក្ដីមួយដែលអាចទទួលយកបានដោយជនរងគ្រោះ ។

ការទម្លាក់កំហុសទៅលើខ្មែរក្រហមទាំងស្រុងគឺជាកំហុស ហើយការប្រាប់ជនរងគ្រោះមិនឲ្យទម្លាក់កំហុសទៅលើរបបខ្មែរក្រហមគឺជាកំហុសដែលមិនអាចទទួលយកបាន ព្រោះអំពើឃោរឃៅដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាគ្រប់រូប គឺជារឿងមួយដែលត្រូវតែដោះស្រាយទៅតាមផ្លូវច្បាប់ ។ ដំណោះស្រាយនេះគឺទាមទារឲ្យមានការវិនិច្ឆ័យមុនពេលឈានទៅដល់ការលើកលែងទោស ការអត់ឱនទោសនិងការផ្សះផ្សាជាតិ ។

វប្បធម៌នៃការបង្អុលអ្នកដទៃ ឬការទម្លាក់កំហុសទៅលើអតីតកាល ឬមនុស្សដែលបាត់បង់ជីវិត ត្រូវតែបញ្ចប់ដោយឈរទៅលើការដោះស្រាយបញ្ហាចំពោះមុខតាមផ្លូវច្បាប់ ដោយពឹងផ្អែកទៅលើការសិក្សាអំពីអតីតកាលនិងអង្គហេតុពិត ។ គ្មានអ្វីដែលអាចជាសំណងដល់ជនរងគ្រោះនៃរបបខ្មែរក្រហមបានទេ ។ ជីវិតមនុស្សប្រមាណពីរលាន ផ្ទះសម្បែង និងទ្រព្យសម្បត្តិជាច្រើន បានបាត់បង់ ។ ដូច្នេះការទាមទារឲ្យមានត្រឹមតែតុលាការមួយនោះគឺតិចតួចណាស់ ។ ប្រសិនបើយើងមិនអាចជួយអ្វីដល់ជនរងគ្រោះទេនោះ យ៉ាងហោចណាស់ក៏យើងមិនត្រូវជំរុញជនរងគ្រោះឲ្យបំភ្លេចនូវការឈឺចាប់ដែលអ្នកទាំងអស់នោះបានទទួលរងនោះឡើយ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ពេញ ធួក ហៅ សុក ហៅ វន វើត



វន វើត

វន វើត ជាអតីតរដ្ឋមន្ត្រីក្រសួងខស្សរាហកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ។ វន វើត មានឈ្មោះដើម ពេញ ធួក ហៅ សុក ឈ្មោះបដិវត្តន៍ៈ មាន, តែ, កួន, វែត, វន ។ ឪពុកម្ដាយរបស់ វន ជាកសិកររស់នៅខេត្តសៀមរាប ។ កាលពីកុមារ វន រៀននៅខេត្តសៀមរាប ។ នៅឆ្នាំ១៩៤៨ វន បានផ្លាស់ទៅរៀននៅវិទ្យាល័យបាត់ដំបង ។ ឆ្នាំ១៩៥២ វន ប្រឡងជាប់ឌីប្លូម ហើយក៏ផ្លាស់មករៀននៅទីក្រុងភ្នំពេញ ដោយស្នាក់នៅផ្ទះម្ដាយមីងឈ្មោះ យឿន ដែលមានប្ដីឈ្មោះ សឺង ស៊ិន ។ ផ្ទះរបស់ យឿន គឺជាទីស្នាក់ការកាសែតប្រជាធិបតេយ្យ ។ សឺង ស៊ិន តែងតែយកកាសែតប្រជាធិបតេយ្យមកឲ្យ វន អាន និងបានអប់រំ វន ជារឿយៗអំពីខ្មែរសេរីដែលមានអាមេរិកាំងជាបង្អែក ។ វន អានកាសែតផង និងទទួលការអប់រំពី ស៊ិន ផង យូរៗទៅក៏ចូលចិត្តចង់ស្ដាប់ចង់ដឹងរឿងខ្មែរសេរី ។ ឆ្នាំ១៩៥៣ វន បានចូលរួមចលនាតស៊ូទាមទារឯករាជ្យពីបារាំង ដែលដឹកនាំធ្វើដោយក្រុមសិស្សនិស្សិត ។

បន្ទាប់ពីនោះ វន កើតមានគំនិតខ្ជិលរៀន ហើយចង់ចូលព្រៃតស៊ូតាម សឺង ង៉ុកថាញ់ វិញ ។ ខែ៧ ឆ្នាំ១៩៥៣ វន បានចេញពីទីក្រុងភ្នំពេញទៅចូលរួមជាមួយខ្មែរឥស្សរៈខាង សាវ៉ាង វង់ នៅតំបន់ស្វាយលែង ។ នៅក្នុងព្រៃបានរយៈពេល ៣ខែ វន បានស្គាល់ឈ្មោះ មាស សម័យ ។ មាស សម័យ បានបបួល វន និងមនុស្សពីរនាក់ទៀត រត់ទៅចូលរួមជាមួយចលនាខ្មែរយៀកមិញរបស់ សឺង ង៉ុកថាញ់ ប៉ុន្តែត្រូវ សាវ៉ាង តាមចាប់ខ្លួនបាន៣នាក់ រត់រួចតែ មាស សម័យ ម្នាក់ប៉ុណ្ណោះ ។ ដល់ខែ៣ ឆ្នាំ១៩៥៤ ទើប សាវ៉ាង វង់ ដោះលែង វន ឲ្យមានសេរីភាព ។ វន វិលត្រឡប់មកភ្នំពេញវិញ ស្នាក់នៅផ្ទះម្ដាយមីងឈ្មោះ យឿន ដដែល ។

ខែ៤ ឆ្នាំ១៩៥៤ វន ចេញពីទីក្រុងភ្នំពេញ ធ្វើដំណើរទៅស្រុកស៊ឹងត្រង់ ត្រៀមឆ្លងទន្លេមេគង្គទៅខាងភូមិភាគបូព៌ាទៀត ។ វន បានទៅដល់ភូមិភាគបូព៌ានៅក្នុងខែ៥ ឆ្នាំ១៩៥៤ ដោយស្នាក់នៅជិតភូមិសន្ទុះ នៅក្នុងផ្ទះមួយដែលមានបងលេខ១និងយុទ្ធជនប្រមាណបួនដប់នាក់ និងឃើញ ទូ សាមុត មកលេងម្ដងម្កាលផង ។

នៅខែ៧ ឆ្នាំ១៩៥៤ ក្រោយសន្និសញ្ញាទីក្រុងហ្សឺណែវ អង្គភាពរបស់ វន ត្រូវរំសាយ ដើម្បីត្រៀមខ្លួនវិលត្រឡប់មកភ្នំពេញវិញ ។ ចុងខែ១០ វន បានមកដល់ភ្នំពេញជាមួយ សុកខ្នុល, ហើយក៏បានបែកផ្លូវគ្នាធ្វើដំណើរទៅផ្ទះម្ដាយមីងដែលធ្លាប់ស្នាក់នៅពីពេលមុនដដែល ។ ពីរបីថ្ងៃក្រោយមក វន បានជួប ពឹង សយ ដែលជាខ្សែរបស់បងទី១(ប៉ុលពត) ហើយ ពឹង សយ ក៏បានណែនាំឲ្យ វន បានបង្រៀននៅសាលាចំរើនវិជ្ជា ។ ខែ១២ បងទី១ បានបញ្ចូល វន ទៅក្នុងជួរបក្ស ។

នៅសាលាចំរើនវិជ្ជា វន បានស្គាល់ មុី ផាត់ និង ផ្លែក ភិន ហើយត្រូវបានអ្នកទាំងពីរអូសទាញឲ្យចូលសេអ៊ីអា ។ ចាប់ពី

ពេលនោះមក វន ធ្វើបដិវត្តន៍ផង បន្តប់យកការណ៍ពីបដិវត្តន៍ផង ។ នៅក្នុងថ្នាក់រៀន វន ព្យាយាមឃោសនាលើកតម្កើងអាមេរិក បញ្ចុះបញ្ចូលមហាជនកុំឲ្យប្រឆាំងនឹងសន្ធិសញ្ញាយោធាខ្មែរ-អាមេរិកាំង ផ្សព្វផ្សាយទស្សនាវដ្តីអាមេរិក បញ្ចុះបញ្ចូលសិស្សឲ្យចង់ទៅរៀននៅអាមេរិក ឃោសនាវាយប្រហារបដិវត្តន៍ និងយកការណ៍សម្ងាត់ពីបដិវត្តន៍ឲ្យសេអ៊ីអា ។

ឆ្នាំ១៩៥៩ វន បានក្លាយជាសមាជិកគណៈកម្មាធិការបក្សប្រចាំទីក្រុងភ្នំពេញ ។ ឆ្នាំ១៩៦៣ វន បានចូលក្នុងអង្គការមជ្ឈិមរបស់បក្ស ។ ពេលនេះ វន មិនសូវហ៊ានធ្វើសកម្មភាពសេអ៊ីអាជាចំហទេ គិតតែខិតខំធ្វើខ្លួនឲ្យល្អដើម្បីឲ្យបក្សទុកចិត្ត ។ ចុងឆ្នាំ១៩៦៣ បងៗមួយចំនួនត្រូវចេញទៅជនបទ ដូច្នេះ វន ក៏ទទួលខុសត្រូវដឹកនាំការងារនៅក្នុងក្រុង ។ ចលនាបដិវត្តន៍កាន់តែរីកចំរើននៅទូទាំងប្រទេស ប្រមូលកម្លាំងបានកាន់ច្រើន ហើយឈានទៅដល់ធ្វើបាតុកម្មវាយកម្ទេចស្ថានទូតអាមេរិកដោយគ្មាននរណាអាចទប់បាន ។

ឆ្នាំ១៩៦៤-៦៥ វន កាន់កាប់ការងារក្រុងជាមួយសមមិត្ត គី ។ វន ទទួលខុសត្រូវខាងការងារបក្ស ចំណែកឯសមមិត្ត គី ទទួលខុសត្រូវខាងយុវជន ។ ដោយសារមានការបង្ក្រាបខ្លាំងពីសំណាក់រដ្ឋាភិបាលនៅចុងឆ្នាំ១៩៦៤ សមមិត្ត អន ដែលទទួលខុសត្រូវខាងផ្នែកកម្មករត្រូវបក្សដកទៅខាងនិរតី ហើយពាក់កណ្តាលឆ្នាំ១៩៦៥ សមមិត្ត គី ត្រូវដកទៅជនបទខាងពាយ័ព្យ ។ យុវជនមួយចំនួនជាប់គុក ដូច្នេះការងារនៅក្រុងត្រូវខើចបន្តិច ។ គណៈក្រុងថ្មីមាន វន ជាលេខា សមមិត្ត ដាំ ផេង ជាអនុលេខា លៀង គឹមហួត ជាសមាជិក ។ វន បានស្នើសុំកម្លាំងខ្លះពីសមមិត្ត ធុច រិន មកបន្ថែម ។

ឆ្នាំ១៩៦៧ ចលនាតស៊ូរបស់បដិវត្តន៍នៅខាងពាយ័ព្យមានសន្ទុះខ្លាំងឈានទៅធ្វើកុប្បកម្មនៅសំឡូត ខេត្តបាត់ដំបង ។ ដើមឆ្នាំ១៩៦៨ ផ្ទុះចលនាកុប្បកម្មនៅគ្រប់ខេត្តក្រុងទាំងអស់ ។ ខែ៨ ឆ្នាំ១៩៦៨ រដ្ឋាភិបាលចាប់ផ្តើមបង្ក្រាបចលនាខ្មែរក្រហមនៅភ្នំពេញយ៉ាងខ្លាំងក្លា ជាហេតុធ្វើឲ្យខ្សែបក្សនៅក្នុងទីក្រុងបាត់មូលដ្ឋាន ដាច់ការទាក់ទងគ្នាមួយរយៈ ។ វន ខ្លួនឯងដែលត្រូវរដ្ឋាភិបាលតាមចាប់ខ្លួន ក៏ទៅលាក់ខ្លួននៅផ្ទះសមមិត្ត ខ្មៅ អស់រយៈពេល២-៣ខែ ។ ចុងឆ្នាំ១៩៦៩ ដោយអស់មនុស្សធ្វើការ វន បានយកសមមិត្ត ហង់ មកធ្វើការជំនួសនៅបក្សក្រុង ខ្លួនគាត់ចេញទៅប្រជុំរៀនសូត្រនៅភ្នំឳរ៉ាល់ ហើយក៏កើតជំងឺគ្រុនចាញ់អស់ជាច្រើនខែ ត្រឡប់មកព្យាបាលនៅភ្នំពេញរហូតដល់ចុងខែ៥ ឆ្នាំ១៩៧០ ទើបជាសះស្បើយ ។ បន្ទាប់ពីជាសះស្បើយពីជំងឺ វន បានចេញទៅភ្នំឳរ៉ាល់ម្តងទៀត និងបានជួប ហ៊ូ យន់, ហ៊ូ នឹម សំណេះសំណាលគ្នាអស់រយៈពេលជិតមួយម៉ោង ក៏មានសំបុត្ររបស់អង្គការមកថាឲ្យបងៗទាំងអស់ចុះទៅភ្នំពឹសដើម្បីត្រៀមធ្វើដំណើរទៅអង្គការលើ ។ ធ្វើដំណើរទៅដល់ភ្នំពឹសសម្រាកបាន២-៣ថ្ងៃក៏បែកគ្នា ។ ហ៊ូ យន់ និង ហ៊ូ នឹម ឡើងទៅជួបអង្គការលើ ។ វន ត្រូវបានតាម៉ុក ចាត់តាំងឲ្យទទួលខុសត្រូវនៅមន្ទីរភូមិភាគនិរតីជាមួយឈ្មោះ សែ ហើយខ្លួនគាត់នាំទ័ពដើរវាយបន្តទៀត ។

ដើមឆ្នាំ១៩៧១ អង្គការបានចាត់តាំងឲ្យ វន មករៀបចំភូមិភាគពិសេសនៅខាងលិចទីក្រុងភ្នំពេញ ក្នុងឋានៈជាលេខា ។ វន រៀបចំមន្ទីរ៣០៥នៅឃុំពាម ហើយចាត់តាំង រស់ ជេដ្ឋ ហៅ ជាតិ ធ្វើជាប្រធានមន្ទីរ សៀង ប៉ោសែ ហៅ នាគ ទទួលខាងសេដ្ឋកិច្ច និង ធី គឹមអាន ទទួលខាងឃោសនា និងបោះពុម្ពផ្សាយ ។ ខែ៧ ឆ្នាំ១៩៧១ អង្គការបានដកតំបន់២៥ ដែលគ្រប់គ្រងដោយ ដៃ សួន ឲ្យស្ថិតនៅក្រោមចំណុះភូមិភាគពិសេសវិញ ។ ពេលនោះនៅតំបន់២៥មានទំនាស់ដណ្តើមអំណាចគ្នារវាងពួកមកពីខាងជើងនិងពួក សុក, ចំរើន និង ហួត សេ ។ បក្សសម្រេចឲ្យ ភឹម ដកពួកខាងជើងទៅភូមិភាគបូព៌ាវិញ ទំនាស់ក៏ចប់ ។

ឆ្នាំ១៩៧៣ វន ចុះទៅតំបន់២៥ដើម្បីជំរុញការប្រយុទ្ធនៅសមរភូមិខាងត្បូងនៃភូមិភាគ ពិសេសដើម្បីសម្រុកវាយផ្តាច់ព្រ័ត្រតាមផែនការរបស់បក្ស ។ កងទ័ពដែលនៅសមរភូមិខាងត្បូងមានពីរកងពល គឺកងពលរបស់សមមិត្ត ណាត និងកងពលរបស់សមមិត្ត រឿន ។ វន បាននិយាយថា ខ្លួនគាត់ជាអ្នកអប់រំកងទ័ពទាំងនោះ ប៉ុន្តែមិនហ៊ានអប់រំផ្ទុយនឹងមាគ៌ារបស់បក្សទេ ព្រោះខ្លាចបែកការណ៍សម្ងាត់ គ្រាន់តែបានកសាងមនោសញ្ចេតនាខ្លះៗសម្រាប់ថ្ងៃមុខតែប៉ុណ្ណោះ ។

ចុងឆ្នាំ១៩៧៣ អង្គការសម្រេចឲ្យដកកងទ័ពភូមិភាគបូព៌ា

មួយកងឡើងមកផ្លូវជាតិលេខ១ ។ វន បានដឹងថា ដៃ សួន, ឈូក, ចក្រី, សុផាន, លីផែន និង សុក ជាខ្មែរសេរីអា ប៉ុន្តែធ្វើជាមិនដឹងមិនឮ ព្រោះមិនចង់ឲ្យបែករឿងដល់ខ្លួន ។ នៅឆ្នាំ ១៩៧៤ វើត បានណែនាំ ដៃ សួន កុំឲ្យទាក់ទងគ្នាធ្វើសកម្មភាពសេរីពេក ព្រោះបដិវត្តន៍មុខតែឈ្នះហើយ ។ ត្រូវបង្កប់ឲ្យស្ងាត់ ហើយស៊ីរូងផ្ទៃក្នុងបន្តទៀត ។ ពេលនេះត្រូវតែប្រឹងឲ្យបដិវត្តន៍ឈ្នះសិនទៅ ព្រោះទប់មិនបានទេ ។

ពាក់កណ្តាលឆ្នាំ១៩៧៤ វន ក៏បានទាក់ទងញឹកញាប់ជាមួយ សោ ភឹម លេខា (ភូមិភាគបូព៌ា) តាមរយៈ ដៃ សួន និងបានដឹងច្បាស់ថា ភឹម ជាខ្មែរសេរីអាមួយធំនៅក្នុងបក្ស ។ ក្រោយថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ កម្លាំងសេរីអាសំខាន់ៗមាន ភឹម (សោ ភឹម) លេខាភូមិភាគបូព៌ា, ស៊ី (ជូ ជេត) លេខាភូមិភាគបស្ចិម, ញឹម (រស់ ញឹម) លេខាភូមិភាគពាយ័ព្យ, ធុច (កុយ ធួន) លេខាភូមិភាគឧត្តរ បានរៀបគម្រោងធ្វើរដ្ឋប្រហារផ្តួលរំលំរដ្ឋអំណាចបដិវត្តន៍ដោយមាន យ៉ា (ណៃ សារ៉ាន់) ជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការរៀបចំផែនការ ។ វន និង ដៃ សួន ត្រូវអង្គការដកមកនៅភ្នំពេញ ហើយតំបន់២៥ត្រូវប្រគល់ឲ្យខាងភូមិភាគនិរតីគ្រប់គ្រងវិញ ។ វន កាន់កាប់និងរៀបចំក្រសួងកសិកម្មជាមួយនឹងសមមិត្ត អន ។ វន រំសាយមន្ទីរភូមិភាគពិសេស ហើយដកមនុស្សជិតមួយរយនាក់មកជួយរៀបចំរោងចក្រនៅភ្នំពេញ ។ សមមិត្ត អន ក៏យកមនុស្សមួយចំនួនពីតំបន់១៥មកដែរ ។ វន ស្នើយកសមមិត្ត ប្រាង នៅខាងរទេះភ្លើង មកឲ្យរៀបចំជួសជុលផ្លូវស្ពាន ។

ដើមឆ្នាំ១៩៧៦ ចក្រី, ឈូក, ដៃ, និង ធុច ត្រូវអង្គការបោសសម្អាត ។ វន ឃើញថា ខាងបដិវត្តន៍មានកម្លាំងខ្លាំង រីឯខាងសេរីអាចេះតែចុះខ្សោយជាលំដាប់ ក៏ធ្វើឲ្យខ្លួនមានអារម្មណ៍មិនប្រាកដប្រជា មិនដឹងថាគួរបន្តសកម្មភាពក្បត់នឹងបដិវត្តន៍ទៀត ឬគួរតែឈប់ទេ ប៉ុន្តែ សោ ភឹម ចេះតែគាបសង្កត់ជាប់មិនឲ្យដកខ្លួនថយ ដូច្នេះ វន ក៏បន្តសកម្មភាពក្បត់ជាសម្ងាត់តទៅទៀត ។

ចុងឆ្នាំ១៩៧៧ សោ ភឹម បានស្នើថ្នាក់លើសុំវាយយួនដោយយកលេសថាដើម្បីម្ចាស់ការមុនក្នុងកិច្ចការពារផលស្រូវ តាមពិតគឺចង់ឆ្លៀតឱកាសទាក់ទងជាមួយយួន ។ បក្សក៏អនុញ្ញាតឲ្យវាយ ។ នេះជាមូលហេតុដែលនាំឲ្យកងទ័ពយួនវាយសន្ទាប់ចូលជ្រៅក្នុងទឹកដីកម្ពុជា ។ ខែ១ ឆ្នាំ១៩៧៨ វន នាំទ័ពទៅទប់ទល់នឹងទ័ពយួននៅផ្លូវជាតិលេខ៧ ។ វន បានជួប កែ ពក ក្នុងសភាពបាក់ទ័ព ហើយក៏បានជួយជំរុញលើកទឹកចិត្តនិងពួតដៃគ្នាដេញទាហានយួនទៅវិញ ។ កងកម្លាំងរបស់បក្សកុម្មុយនិស្តកម្ពុជាបានវាយរុញច្រានកងទ័ពយួនទៅវិញអស់ផែនការរបស់ ភឹម ត្រូវបរាជ័យ ។ កម្លាំងមួយចំនួននៅខេត្តស្វាយរៀងត្រូវអង្គការបោសសម្អាត ហើយ ភឹម ខ្លួនឯងក៏ត្រូវបើកមុខជាបណ្តើរៗនិងធ្លាក់ខ្លួនឈឺជាទម្ងន់ ។ តាំងពីមានសមរភូមិនៅផ្លូវជាតិលេខ៧ វន ខស្បាហ៍ទៅជួបជាមួយ ពក ជាញឹកញាប់ ដើម្បីតាមដានសមរភូមិ និងរាយការណ៍ជូន ពក អំពីសមរភូមិផ្សេងៗ ។ នៅចុងខែ៣ វន បានយកឡានទៅដឹក ភឹម ដែលកំពុងឈឺ មកសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅក្នុងទីក្រុងភ្នំពេញ ។ បន្ទាប់ពីពេលនោះមក វន មិនមានភារកិច្ចទៅសមរភូមិផ្លូវជាតិលេខ៧ទៀតទេ ។ ក្រោយពីជាសះស្បើយពីជំងឺ ភឹម ក៏ជិះរថភ្លើងទៅបាត់ដំបងជាមួយ ញឹម នៅដើមខែ៤ឆ្នាំ ១៩៧៨ ដើម្បីទៅរៀបចំកម្លាំងនៅខាងភូមិភាគពាយ័ព្យ ។ ផែនការរបស់ ភឹម យឺតបន្តិច ព្រោះបក្សបានដឹងជាមុន ។ បក្សបានចាប់ផ្តើមបោសសម្អាតនៅខាងភូមិភាគបូព៌ានិងឈានទៅបោសសម្អាតជាបន្តបន្ទាប់នៅខាងភូមិភាគពាយ័ព្យ ឧត្តរ និងឦសាន ដែលជាហេតុនាំដល់ការរលំរលាយកម្លាំងបក្សពលករ និងសេរីអា ។

ដោយសារមានការកម្ទេចមេដឹកនាំក្បត់ វន បានណែនាំថ្នាក់ក្រោមឲ្យផ្អាកសកម្មភាពសិន ប៉ុន្តែគាត់នៅតែខិតខំរកវិធីជួយសមិត្ត ចាន់ និងសមមិត្ត គី ដើម្បីប្រមូលកម្លាំងបន្តសកម្មភាពទៅទៀតសម្រាប់ត្រៀមរដូវប្រាំងចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ។ ផែនការរបស់ វន ក៏មិនបានសម្រេចដែរ ហើយនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ វន ត្រូវអង្គការចាប់ខ្លួន ។

វន ត្រូវបានបញ្ជូនមកឃុំឃាំងនៅមន្ទីរ ស-២១ និងត្រូវសួរចម្លើយចំនួន៥ដង ។ លើកទី១នៅថ្ងៃទី៦ ខែ១១ លើកទីពីរនៅថ្ងៃទី១០ ខែ១១ លើកទី៣នៅថ្ងៃទី១ ខែ១២ លើកទី៤នៅថ្ងៃទី៣ ខែ១២ និងលើកទី៥ នៅថ្ងៃទី៥ ខែ១២ ឆ្នាំ១៩៧៨ ។

**សាន់ កល្យាណ**

# បំពាក់ទស្សនៈនិងគោលជំហរមួយចំនួនក្នុងការងារសន្តិបាល

***សំណួមពរ***

១) ទស្សនៈគោលជំហរស្ទាក់ស្ទើរមិនជឿបក្សចំពោះខ្មាំងដែលបក្សចាប់មក ។

២) ជម្រះទស្សនៈនិងគោលជំហរដែលចេះតែជឿខ្មាំងសារភាព ខ្ជិលវិភាគ ខ្ជិលគិតគូរ នាំឲ្យមានអន្តរាយដល់កំលាំងបក្ស ។

៣) ជម្រះទស្សនៈនិងគោលជំហរមិនជឿខ្មាំងសារភាព មានមនោសញ្ចេតនាបុគ្គលគ្រួសារ បក្សពួក (ល) ដែលធ្វើឲ្យខ្មាំងស៊ីរូងបំផ្លាញបក្ស លាក់ខ្លួនធ្វើសកម្មភាពប្រឆាំងបក្សជាបន្តបន្ទាប់ ។

## I. ***អំពីភារកិច្ចសួរ***

១) សួរចម្លើយ វិភាគចម្លើយ ចម្រាញ់ចម្លើយ ទាំងអស់នេះជាភារកិច្ចសួររបស់យើង ។

២) ការងារបង្កបង្កើនផល ចិញ្ចឹមសត្វ អនាម័យ ជាការងារបន្ទាប់ ។

៣) រៀនសូត្រចលនា៣គោន១ហិកតាៈ

ក) ចាត់ចែងកម្លាំងវាយសម្រុកឲ្យបានចំទិស គឺយើងសម្រុកអ្វីមុន សម្រុកអ្វីក្រោយ ។ យើងសម្រុកត្រូវឈរលើអ្វីដោយសំខាន់ ដែលចាំបាច់តាមការណែនាំរបស់បក្សដាច់ខាតឥតលក្ខខណ្ឌ ។

ខ) មនុស្សណាដែលវាសារភាពច្បាស់ យើងមានសភាពវាយសម្រុកបានលទ្ធផលមុនគេ ដោយវាដឹងរឿងច្រើន យើងសម្រុកសួរវានោះមុនគេ យើងសម្រុកដោយមិនស្ទាក់ស្ទើរ មិនតែពីសតែពាសទេ ។ ធ្វើយ៉ាងនេះទើបយើងមិនខាតកម្លាំង មិនខាតពេលវេលា ធ្វើឲ្យបក្សមានវិធានការទាន់ពេលវេលានិងមិនប្រឡំ ។ សរុបទៅ យើងឆាប់បានទទួលលទ្ធផលរាយការណ៍ជូនបក្ស ។

ពិសោធន៍ដែលយើងជួបប្រទះគឺ÷

ក) បក្សផ្លាស់ប្តូរញឹកញាប់

ខ) បក្សដូរមនុស្សទោសដែលត្រូវសួរមិនទៀងពេល

គ) បក្សផ្លាស់ប្តូរក្រុមចុះឡើង ម្តងទៅក្រុមនេះ ម្តងទៅក្រុមនោះ ឬរហូតប្តូរភារកិច្ចយើងផង ។

ឃ) បក្សប្តូរពិសោធន៍ទាំងធ្វើឯកសារ ទាំងវិធីសួរ ទាំងវិធីធ្វើនយោបាយឃោសនា ទាំងវិធីធ្វើទារុណកម្ម ទាំងវិធីបណ្តើរឬឃុំឃាំង ញឹកញាប់ណាស់ ។ ទាំងអស់នេះគឺទាល់តែយើងមានអង្គការវិន័យខ្ពស់ជ្រះស្រឡះកុំស្មុគស្មាញ នោះទើបយើងបត់ខ្លួនទាន់សភាពការណ៍ ស៊ុះតាមចលនា៣គោន១ហិកតាបាន ។

## II. ***ទស្សនៈគោលជំហរចំពោះខ្មាំងដែលបក្សចាប់មក***

១) មនុស្សដែលបក្សចាប់មកមានពីរប្រភេទគឺ÷

ក) វាមានសកម្មភាពខ្លាំងនៅមូលដ្ឋាន ជាការប្រឆាំងគ្រប់យ៉ាង ជាសេរីទាក់ទងក្រៅការចាត់តាំងជាបន្តបន្ទាប់ជាហូរហែ ។

ខ) តាមសេចក្តីរាយការណ៍របស់សន្តិបាលយើង ហើយដែលបក្សបានពិនិត្យតាមដានច្បាស់ហើយ ។

២) ដូច្នេះយើងកុំស្ទាក់ស្ទើរមន្ទិលសង្ស័យក្នុងសតិអារម្មណ៍ដែលធ្វើឲ្យរាំងស្ទះដល់ភារកិច្ចរបស់យើង ទោះអ្នកនោះជាបងប្អូនយើងក៏ដោយ ឬជាមនុស្សយើងធ្លាប់ទុកចិត្តដូចម្តេចក៏ដោយ ។

៣) សំខាន់បំផុតសម្រាប់យើងគឺជឿបក្សដាច់ខាត ។

៤) ផលវិបត្តិម្យ៉ាងដែលមនុស្សវាប្រើឧបាយកលបំភាន់យើងគឺ÷

ក) វាតម្អូតម្អូញអង្វរករយើង ។ វាធ្វើបុកជាស្លូតបូតសម្តីវាថាមិនក្បត់យើងទេ ។

ខ) វាប្រតិកម្មជេរជៀលត្មះយើង ថាយើងធ្វើបាបវា ថាវានេះមិនមែនជាមនុស្សក្បត់ ជួនរហូតដល់មានប្រតិកម្មធំដុំទៀត ។

គ) វាថាវាសារភាពព្រោះឈឺ (ល)

ក្នុងករណីនេះ បើយើងពុំទាន់តាមដានវាក្នុងប្រការណាមួយក៏មិនអំណោយដល់ការងារសួរចម្លើយយើងដែរ ។ ផលវិបត្តិគឺសួរយឺត ព្រោះមានមន្ទិលវាមិនមែនខ្មាំង ដូច្នេះក៏ខុះម្ចាស់ការហើយឈានទៅបាត់ម្ចាស់ការទៀត ។

៥) វិធានការរបស់យើងគឺ÷

ក) រក្សាទស្សនៈឲ្យវារស់យូរដើម្បីយកចម្លើយជូនបក្ស ។

ខ) កុំបណ្ដែតបណ្ដោយឲ្យវាតម្អែតម្អូញឬមានប្រតិកម្ម ។

គ) ត្រូវខំឃោសនាជាមួយវា ធ្វើឲ្យវាមើលឃើញថាបក្សចាប់វាមកមិនច្រឡំទេ ។

◆ សារភាពជូនបក្សឲ្យវារស់ កុំឲ្យវាងាប់ជួសមេវា ឲ្យវានឹកដល់ប្រពន្ធកូនវា ។

◆ គ្មាននរណាជួយវាទេ ឲ្យវាជឿលើបក្ស ដូចនេះយើងបំបែកបំបាក់វាលែងទុកចិត្តគ្នាវា មេវា ផែនការវា ។

◆ សន្តិបាលនេះជាសន្តិបាលបក្ស ដូច្នេះពុំចេះតែចាប់សម្លាប់ទេ ។

◆ តែយើងកុំមានមោទនភាពមិនបដិវត្តន៍ ជំពាក់ថាយើងជាសន្តិបាលបក្ស ។

សរុបទៅគឺធ្វើយ៉ាងណាឲ្យវាស្រពេចស្រពិលលើបញ្ហាស្លាប់រស់ នៅសង្ឃឹមថាវាអាចរស់ ។

ឃ) ត្រូវកំណត់ទស្សនៈថា បញ្ហាទុកឲ្យវារស់ឬសុំរឿងវាឬកម្ទេចវា គឺស្រេចនៅលើបក្សវិនិច្ឆ័យ ចំពោះយើងគឺយើងធ្វើដូចម្ដេចឲ្យតែបានចម្លើយជូនបក្ស នេះជាភារកិច្ចខត្តុង្គខត្តមរបស់យើង ។

## III. ទស្សនៈគោលជំហរចំពោះវិធីសួរចម្លើយ

១) វិធានការសម្រាប់យើងម្នាក់ៗក្នុងពេលសួរចម្លើយវាមានពីរយ៉ាង÷

ក) គាបខាងនយោបាយ គឺយើងឃោសនាគាបវាជាប់ជានិច្ចជាបន្តបន្ទាប់គ្រប់ពេលវេលា ។

ខ) ធ្វើទារុណកម្មជាវិធានការរួមផ្សំ ។

២) ពិសោធន៍កន្លងមករបស់មិត្តយើងអ្នកសួរចម្លើយគឺច្រើនធ្លាក់ទៅខាងទារុណកម្ម មើលធ្ងន់ទារុណកម្មទៅជាការឃោសនា នេះជាពិសោធន៍ខុសឆ្គងដែលយើងត្រូវបំពាក់ជាប់ដាច់ខាត ។

៣) ខ្មាំងពុំឆ្លើយសារភាពឲ្យយើងស្រួល សារភាពពេលយើងធ្វើនយោបាយក៏វាសារភាពក្នុងកម្រិតទាបបំផុត ចៀសមិនផុតពីទារុណកម្មទេ គ្រាន់តែខុសគ្នាត្រង់តិចឬច្រើនប៉ុណ្ណោះ ។ តែទុកជាទារុណកម្មជាវិធានការចាំបាច់យ៉ាងនេះក៏ដោយ ក៏យើងត្រូវតែខិតខំធ្វើនយោបាយឲ្យវាសារភាពយើងដាច់ខាតជាប់ជានិច្ច ។ ទាល់តែយើងគាបវាខាងនយោបាយ ប្រកខាងនយោ-បាយឲ្យវាសារភាព ទើបទៅទារុណកម្មបានផល ។

ការដែលយើងខិតខំធ្វើនយោបាយគឺធ្វើឲ្យយើងមានសភាពខាងឃោសនាមិនជាន់កែងឯងនេះម្យ៉ាង ម្យ៉ាងទៀតគឺធ្វើឲ្យអ្នកទោសជ្រះស្រឡះក្នុងការឆ្លើយ ទោះយើងធ្វើទារុណកម្មក្រោយមកក៏ដោយ ក៏ធ្វើឲ្យវាឆាប់សារភាព គ្រាន់បើជាងយើងគិតតែពីវ៉ៃមិនគិតឃោសនាសោះ ក្នុងការធ្វើនយោបាយគឺទាមទារជំហរអត់ធ្មត់បំផុតកុំតក់ក្រហល់ ។

រូបភាពឃោសនាដែលយើងធ្វើកន្លងមកគឺ÷

ក) លួងលោងឲ្យនេះឲ្យនោះស៊ី លួងលោមខាងបក្សថាឲ្យឋានៈវិញ ។

ខ) សម្លុតកំហែង បង្កើបំបែកបំបាក់ដោយការប៉ិនប្រសប់រៀបចំឆាកតូចៗធ្វើឲ្យវាស្លុត អស់សង្ឃឹមថាមិនអាចរីងរូសតទៅទៀតបានទេ ។

គ) នាំវានិយាយលេងសើចខ្លះតែថ្លៃថ្នូរនិងមានប្រយោជន៍ ។

ឃ) អូសទាញសពោ្ធតនាឲ្យវាវិលវល់ក្នុងវង្វង់គ្រួសារប្រពន្ធកូន អាយុជីវិតវា ដោយបញ្ជាក់ថាទោសវាតូចទេ ។ ពេលវាសារភាពក្ដី មិនទាន់សារភាពក្ដី យើងត្រូវណែនាំវាជាប់ជានិច្ចអំពីខ្លួនវាណើងមិនមែនជាមេធំទេ កុំរីងរូសនាំឲ្យរឿងកាន់តែធ្ងន់ កុំឲ្យធ្វើទារុណកម្មទាន់ ឬធ្វើអ្វីធ្ងន់ទៀត នាំឲ្យលំបាកដល់សុខភាពផងនិងលំបាកមើលមុខគ្នាទៅថ្ងៃក្រោយផង ។

ង) និយាយរឿងតូចធ្វើឲ្យទៅជារឿងធំ ។ បើរាយការណ៍រឿងធំនោះជូនអង្គការវាធូរស្រាលវិញ ។

ច) និយាយមួលបង្កាច់អ្នកបដិវត្តន៍ថាក្បត់ ធ្វើឲ្យខ្លួនវាធ្លាក់ក្នុងឧបាយកលបំផ្លាញកម្លាំងបដិវត្តន៍ ដូច្នេះទោសក៏នាំធ្ងន់ដដែល ។

ឆ) បើវាថាមានគ្នីគ្នាវាចាប់មកមុន គឺត្រូវលើកសរសើរថាពួកមុនរាយការណ៍ច្បាស់អំពីខ្លួនឯងនិងមេវាជូនអង្គការហើយ យើងចោទប្រកាន់ជាប់ជានិច្ចថានៅមិនទាន់ស្មោះត្រង់ ដោយលើកចំណុចខ្សោយវាមកសង្កត់សួរកុំឲ្យវាប្រកែករួច ។

ជ) ចៀសវាងកុំឃោសនាឲ្យវាក្ដាប់ចំណុចខ្សោយរបស់យើងបាន ដូចជាវាដឹងថាយើងចង់ឲ្យវាសារភាពពីនរណា ពីសកម្មភាព

អ្វី ។

ឈ) ដាក់សំណួរត្រូវឲ្យចំទិសហើយនឹងន កុំលោភលន់បញ្ហាស្មុគស្មាះ ដែលធ្វើឲ្យវាពិបាកឆ្លើយ ហើយវាពុំដឹងយើងសួរអំពីអ្វី ។

៤) បញ្ហាធ្វើទារុណកម្ម

ក) សំណូមពរនៃការធ្វើទារុណកម្មគឺយកចម្លើយរបស់វា ពុំមែនធ្វើដើម្បីសប្បាយទេ ដូចនេះត្រូវធ្វើឲ្យវាឈឺដើម្បីឲ្យវាឆាប់ឆ្លើយ ។ សំណូមពរម្យ៉ាងទៀតគឺកាច់វាឲ្យខ្លាចបាក់ស្បាត មិនមែនធ្វើតាមកំហឹងបុគ្គលឲ្យអស់ក្តៅ ដូច្នេះគឺវ៉ៃឲ្យវាខ្លាចតែមិនឲ្យងាប់ដាច់ខាត ។ ពេលធ្វើទារុណកម្មត្រូវពិនិត្យមើលសុខភាពវាមុន ត្រូវពិនិត្យមើលរំពាត់ ។ កុំលោភចង់ឆាប់នាំឲ្យស្លាប់បាត់ឯកសារ ខាត ។

ខ) ត្រូវជ្រួតជ្រាបថាធ្វើនយោបាយគឺសំខាន់ណាស់ ។ គឺចាំបាច់ ចំណែកខាងទារុណកម្មជារឿងបន្ទាប់ ជាបញ្ហារួមផ្សំនឹងនយោបាយក្នុងចំណែកណាមួយប៉ុណ្ណោះ ។ ដូចនេះ បញ្ហាធ្វើនយោបាយគឺដើរតួគ្រប់ម៉ោងពេល សូម្បីតែធ្វើទារុណកម្មក៏ត្រូវឃោសនាជាប់ជានិច្ចដែរ ។

គ) ជាមួយនេះក៏ត្រូវចៀសវាងបញ្ហាស្ទាក់ស្ទើរមិនហ៊ានធ្វើទារុណកម្មដែរ ដែលធ្វើឲ្យសួរចម្លើយខ្មាំងមិនចេញ នាំឲ្យយឺតយូរការងាររយើង ។ សរុបទៅ ឃោសនាក្តី ធ្វើទារុណកម្មក្តី លើកសំណួរសួរវាក្តី ចោទប្រកាន់វាក្តី ត្រូវប្រកាន់ជំហរម៉ឺងម៉ាត់ កុំស្ទាក់ស្ទើរ ត្រូវដាច់ខាត នោះទើបមានប្រសិទ្ធភាពល្អ ។

៥) ដូចម្តេចបានជាខ្មាំងមានប្រតិកម្ម

ក) មូលហេតុសំខាន់បំផុតគឺយើងចាញ់ប្រៀបនយោបាយវា ពេលយើងឃោសនាឬពេលយើងធ្វើទារុណកម្មដំបូង ។ ឧទាហរណ៍ៈ យើងតក់ក្រហល់ពេក ឃោសនាជាន់កែងឯង ។ ឧទាហរណ៍ៈ ធ្វើទារុណកម្មលើវាដោយភ្លេចត្រៀមយថាហេតុមុន ធ្វើឲ្យវាអស់សង្ឃឹម ។

ខ) គុណវិបត្តិផ្តល់ឲ្យយើងពេលវាប្រតិកម្មនេះ ឬម្យ៉ាងផ្អើលគេឯង សំខាន់បំផុតអាចគ្រោះថ្នាក់ដល់យើងនិងមិត្តដទៃ ម្យ៉ាងផ្អើលរំខានការងាររមិត្តដទៃទៀត ។ តែសំខាន់បំផុតពេលវាប្រតិកម្មហើយគឺឲ្យខ្លួនយើងមានមន្ទិលក្នុងសតិជាប់ដោយបារម្ភក្រែងវាមានប្រតិកម្មទៀត ជួនញញើតញញើមវា ជួនចេះតែក្តៅក្រហាយនឹងវា ធ្វើឲ្យយើងបាត់ម្ចាស់ការ ហើយចំណែកវាវិញ ជួនក៏ធ្វើឲ្យមានសតិអារម្មណ៍មិនអស់មិនហើយ វិលវល់គិតគូរបញ្ហាស្លាប់រស់ ជួនវាគិតផ្សេងពីនេះ ។

គ) វិធានការទប់ទល់របស់យើង ដំបូងបំផុតយើងឃោសនារំពុកវាអំពីសតិអារម្មណ៍អន្តការវិន័យនិងឧបាយកលរបស់អ្នកមានខ្លួនពេលជាប់ឃុំឃាំងនេះ គឺមានប្រតិកម្មមិនចេះចប់ គ្រប់ខ្នាត ។ យើងឃោសនាក្នុងគោលបំណងស្រះផ្លូវបង្កាមុន សង្កេតទឹកមុខនិងអាកប្បកិរិយាវាជាប់ ។ បើវាផ្លាស់ប្តូរប្រុងមានប្រតិកម្មគឺត្រូវដើរចេញ កុំឆេវឆាវវាយវា ។ ធ្វើដូចម្តេចកុំឲ្យវាម្ចាស់ការមុនយើង ឧទាហរណ៍ៈ វារង់ចាំឲ្យយើងតមាត់ជាមួយវា ឬជេរឬវាយវា វានឹងអាលជេរយើងវាយយើងវិញ ។ ដូចនេះ បើយើងភ្លាត់ស្នៀតមិនអត់ធ្មត់ គឺវាយកម្ចាស់ការវាប្រតិកម្មបាន ។ ដើម្បីចៀសវាងប្រតិកម្មនេះ គឺយើងត្រូវម្ចាស់ការបំបែកសតិអារម្មណ៍វា ឲ្យគិតបញ្ហាផ្សេងទៀតដូចជាឲ្យវានឹកឃើញគ្រួសារ ឪពុកម្តាយ ប្រពន្ធកូនវា អាយុជីវិតវា (ល)

ឃ) ប្រជុំពិសោធន៍មួយពេល ខ្មាំងផ្ទៃក្នុងរត់រួចគឺជាបរាជ័យយ៉ាងជូរចត់របស់ក្រសួងសន្តិបាលយើងជាងលើកណាៗទាំងអស់ ពីព្រោះវាជាខ្មាំងផ្ទៃក្នុង ។ បរាជ័យនេះមានអត្ថន័យពីរយ៉ាងគឺ÷

១) បែកការណ៍សម្ងាត់ៈ ការសម្ងាត់ដែលយើងថែរក្សាពីរបីខែកន្លងមកនេះត្រូវផ្ទុះធ្លាយជ្រៅទូលាយណាស់ វាទៅនិយាយខ្ទេចខ្ទីអំពីចម្លើយវា ។ អស់ការសម្ងាត់គឺអស់អ្វីៗដែលហៅថាសន្តិបាលហើយ អស់ន័យរលីង ។ ឧត្តមគតិរបស់ជនកុម្មុយនិស្តគឺបម្រើបក្ស ។ យើងមិនចង់ឲ្យបក្សលំបាកដោះស្រាយយើងដាច់ខាត តែលើកនេះបក្សលំបាកដោះស្រាយយើង ។ បក្សកំពុងដោះស្រាយរឿងនេះ ។ ន័យយើងបម្រើបក្សត្រូវរលំរលាយហើយ ។

២) គិញរត់រួចយើងមិនទាន់សម្រេចសំណូមពរចាប់បានដោយដៃយើងម្តងទេ ។ មិនមែនជាបរាជ័យទេ តែជាការខុះខាតរបស់យើងដែលយើងត្រូវដោះស្រាយជាបន្ទាន់បំផុត ។ មូលហេតុគឺយើងទាំងអស់គ្នាមើលស្រាយចំពោះករណីគិញរត់រួច

ពីកន្លែងសួរ ។

## IV. ទស្សនៈគោលជំហរចំពោះឯកសារចម្លើយសារភាពរបស់ខ្មាំង

១) ត្រូវជ្រួតជ្រាបថាខ្មាំងវាសារភាពពីរឿងតិចទៅរឿងច្រើន ពីរឿងតូចទៅរឿងធំ ដូចនេះយើងកុំលោភចង់បានឲ្យវាសារភាពម្តងឲ្យអស់ ។ បើវាឆ្លើយមិនអស់ មិនច្បាស់ គឺអស់សង្ឃឹម ជាពិសោធន៍កន្លងមកពុំដែលមានខ្មាំងណាដែលសារភាពលើកទី១ គឺច្បាស់ល្អិតអស់រឿងក្បត់នោះទេ ជាក់ស្តែងគឺវាវិវត្តិបន្តិចម្តងៗ តែទិសសារភាពទៅមុខជានិច្ច ។ ការដែលវាសារភាពហើយបដិសេធខ្លះវិញគឺជារឿងធម្មតា តែពេលក្រោយមកគឺវាសារភាពច្បាស់បន្តទៀត ។

២) ត្រូវបណ្តោយឲ្យវានិយាយឬឲ្យវាសរសេរ កុំបន្ទុចបន្ទាក់វា កុំកែតម្រង់វាភ្លាមៗតាមចំណង់ចិត្តរបស់យើងដែលយើងដឹងឬដែលយើងចង់ឲ្យវានិយាយ ។ លើកលែងតែចំណុចណាដែលបក្សណែនាំឲ្យសួរសឹមយើងសួរ ព្រោះបក្សក្តាប់សភាពការណ៍បាន ។ តែបើយើងចុចឈ្មោះ ឬចុចសកម្មភាព ធ្វើឲ្យវាប្រឌិតរឿងតាមចំណុចចិត្តរបស់យើង ដូចនេះនាំឲ្យបាត់កម្លាំងបដិវត្តន៍ នាំឲ្យវាយកសភាពការណ៍បដិវត្តន៍មកច្របូកច្របល់ ធ្វើឲ្យខ្ចីមសារចម្លើយទៅជាព្រាលឥតតម្លៃអស់ ការពិតខូចទាំងឥទ្ធិពលសន្តិបាលរបស់យើង ។ ពេលវាសារភាពគឺត្រូវខិតខំលម្អិតដំណើរការសកម្មភាពឲ្យស៊ីស្របនឹងបាតុភាពជាក់ស្តែងនិងជាចំហខ្លះ មានផែនការមានមូលហេតុត្រឹមត្រូវ ។ បើសួររកមនុស្ស ត្រូវលម្អិតប្រវត្តិរូប អត្តចរិត សកម្មភាពទាក់ទងគ្នាបានគោលបំណងក្នុងការធ្វើសកម្មភាព ដូចនេះត្រូវប្រុងប្រយ័ត្នវាយករឿងបុគ្គលមិនមែនខ្មាំងមកច្របូកច្របល់ថាជាខ្មាំង ។

សរុបទៅ ដំណើររឿងគឺដូចម្តេច កុំឲ្យខ្លួនយើងឆ្ងល់ខ្លួនយើងផង ហើយថ្នាក់លើមើលសេចក្តីរាយការណ៍យើងក៏ឆ្ងល់ដែរ ម្យ៉ាងទៀតបើយើងសរសេរក៏កុំខ្ចីពេក កំបុតដើមហើយបើបែរជាវែងវិញគឺវែងឥតប្រយោជន៍ ។

៣) វិធីធ្វើឯកសារ

ក) ត្រូវរៀបចំឲ្យវាសរសេរឆាកជីវិតវាដែលក្បត់ ដែលអានទៅឃើញដំណើររឿងកុបកិនពីរោះ ហើយជាក់ស្តែងច្បាស់ៗ មានហេតុមានផល មានមូលដ្ឋានអំពីចារកម្មស៊ីរូងផ្ទៃក្នុងយើងជារយៈៗតាមផែនការវា ។

ខ) ល្អបំផុតគឺឲ្យវាសរសេរខ្លួនវា មានសម្តីវា មានឃ្លាប្រយោគវា មានគំនិតវាទាំងស្រុង ចៀសវាងយើងហៅឲ្យវាសរសេរ ។ ដូចនេះពេលវានិយាយរឿងឬសរសេរមួយចប់សឹមយើងលើកចំណុចខ្សោយរបស់វាសង្កត់វា ពន្យល់ហេតុផលឲ្យវាឃើញថាវានៅភូត នៅលាក់ នៅពន្ធនិងពង្រួញសាច់រឿង បញ្ហាសរសេរត្រូវឲ្យស្អាតទាំងអក្សរទាំងក្រដាស ។

គ) ត្រូវខិតខំព្យាយាមបញ្ហាបណ្តោយឲ្យវានិយាយប៉ុតណាប៉ុតណី សរសេរប៉ុតណាប៉ុតណីមិនច្បាស់គ្រប់បញ្ហា យើងធ្វើបញ្ហាណាមួយឲ្យច្បាស់បញ្ហានោះ កុំឲ្យរាយប៉ាយ កុំឲ្យខាតពេលហើយមិនបានផលប្រយោជន៍អ្វីសោះ ។

ឃ) ឯកសារសន្តិបាលដែលល្អគឺឯកសារដែលមិត្តយើងអ្នកសួរប៉ិនប្រសប់វិភាគ ប៉ិនប្រសប់លម្អិតបញ្ហា ប៉ិនប្រសប់ឆ្ងល់ ប៉ិនប្រសប់ឆ្កឹះចំណុចខ្សោយវា សរុបទៅគឺឯកសារដែលមិត្តយើងឈ្លាសវៃ ។ យើងឈ្លាសវៃច្នៃប្រឌិតបានល្អអាស្រ័យជំហរយើងរឹងប៉ឹង សកម្មប្រយុទ្ធ មិនធុញទ្រាន់ មិននឿយណាយក្នុងការចង់ដឹង ពិសេសគឺស្មារតីគោរពបក្ស ស្រឡាញ់បក្ស និងចង់ការពារបក្ស ។ សរុបទៅ ការងារសន្តិបាលពុំមែនជាការងារធ្វើឲ្យរួចតែពីដៃ ចង់គិតគូរវិភាគក៏បាន មិនចង់គិតគូរវិភាគក៏បាននោះទេ សេរីស្រេចនឹងចិត្តនោះទេ ។

៤) ពិសោធន៍កន្លងមករបស់យើង យើងពុំដែលបានសួរគិញឲ្យច្បាស់ល្អិតសព្វគ្រប់មួយរយភាគរយទេ ទុកជាយើងខំឈ្លុសឈ្លុលរាប់ថ្ងៃរាប់ខែរហូតដល់វាងាប់ទៅហើយក៏ដោយ អាថ៌កំបាំងរបស់អង្គការសេអ៊ីអានៅតែកប់គិនក្នុងខ្លួនវាជានិច្ច តិចឬច្រើនសំខាន់ខ្លាំងឬតិចប៉ុណ្ណោះ ។ ឧទាហរណ៍ៈ អ្នកទោសម្នាក់នៅកន្លែងយើងវាសារភាពច្រើនហើយ តែពេលវាលេបដែកគោល បក្សបានហៅពេទ្យចូលមកវះកាត់ដល់កន្លែងយើង យើងចំណាយកម្លាំងពេទ្យពីរនាក់ជាប្រចាំ ចំណាយថ្នាំល្អៗសម្រាប់ព្យាបាលវា ។ សភាពការណ៍សព្វថ្ងៃបក្សយើងក្រតែបក្សត្រូវការអាថ៌កំបាំងដែលនៅក្នុងខ្លួនវា ។

យើងមើលឃើញបែបនេះដើម្បីមើលឲ្យឃើញនូវសេចក្តី

ត្រូវការរបស់បក្សក្នុងការចង់ដឹងអាថ៌កំបាំងពីខ្លួនវាកម្រិតណា ។ ដូចនេះយើងជាកុលបុត្ររបស់បក្សមានភារកិច្ចដូចម្តេចខ្លះ?

ការលើកឡើងអំពីពិសោធន៍នេះ គឺក្នុងគោលបំណងឲ្យមិត្តយើងកម្ចាត់ទស្សនៈខុសឆ្គងខ្លះដូចតទៅ÷

ក) ស្ទាក់ស្ទើរមិនម្ចាស់ការ

ខ) វាមិនដឹងរឿងច្រើនទេ ហើយមិនខិតខំឆ្កឹះឆ្កៀលចម្រាញ់ចម្លើយវា ជឿពាក្យបោកប្រាសវាដែលថាវាប៉ុននិយាយអស់តែប៉ុណ្ណឹងហើយ ។

គ) ស្ទាក់ស្ទើរមិនដាច់ខាតចំពោះវា ដូចនេះត្រូវចៀសវាងឲ្យបានបញ្ហាពឹងផ្អែកលើថ្នាក់លើជួយដឹកនាំតម្រែតម្រង់គ្រប់ជំហាន ហើយខ្លួនយើងចាំតែធ្វើ ។ ឥតជួយលើកសំណួរក៏នៅឆ្ងាយហើយបន្ទោសថ្នាក់លើ ។ ត្រូវយល់ថាថ្នាក់លើជួយជាបញ្ហាបន្ទាប់ទេ ។

៥) ចម្លើយរបស់ខ្មាំងតើយើងជឿដូចម្តេច?

ចំពោះយើងអ្នកសួរមិនចោទធូនធូរទេ តែយើងត្រូវមានជំហរជឿបក្ស បក្សណែនាំដូចម្តេចយើងធ្វើឲ្យបាន ហើយឲ្យកក់ក្តៅក្នុងសតិអារម្មណ៍យើងផង ។ ជាមួយនោះ យើងទម្លាប់ខ្លួនវិភាគខ្លួនឯង ហើយរាយការណ៍ជូនបក្ស ដើម្បីឲ្យបក្សជួយតម្រែតម្រង់ ហើយយើងដើរតាមបក្ស កុំមើលឃើញតម្លៃនៃការវិភាគរបស់យើងវាវិសេសវិសាលជាងបក្ស ។

៦) ធ្វើម្តេចឲ្យបក្សកក់ក្តៅនឹងឯកសារសារភាពរបស់ខ្មាំង?

ក) សំខាន់គឺយើងកុំចុចឈ្នោះ កុំនាំវានិយាយ ឬវាយបន្ទំឲ្យវានិយាយតាមបំណងរបស់យើង ។

ខ) សំខាន់ជាងនេះទៀតគឺគោរពការណែនាំរបស់បក្សដោយឥតលក្ខខណ្ឌលើគ្រប់បញ្ហា កុំឲ្យល្មើសឲ្យសោះ ។

ពិសោធន៍ការខុះខាតរបស់យើងកន្លងមកគឺអ្នកទោសខ្លះបក្សមិនទាន់ឲ្យវ៉ៃតែយើងលបវ៉ៃ បក្សឲ្យឃោសនាបែបនេះ យើងឃោសនាបែបនោះ មិត្តខ្លះមកពីភ្លេចពុំបានកត់ទុកការណែនាំរបស់បក្ស តែមិត្តខ្លះទៀតបុគ្គលអំនួត ។ មិត្តខ្លះបក្សឲ្យសួររឿងនយោបាយគាត់សួររឿងសីលធម៌ស្រីញីតាមសតិអារម្មណ៍ភ្លើតភ្លើនរបស់ខ្លួន ។ បក្សឲ្យវ៉ៃអ្នកទោសស្រីនឹងរំពាត់ដាច់ខាតមិនវាយនឹងដៃ យើងកុំល្មើស ។

គ) ចម្លើយដែលវាសរសេរត្រូវឲ្យវាស៊ីញ៉េទទួលខុសត្រូវមានថ្ងៃខែច្បាស់លាស់ មានលើកទី១ មានលើកទី២ ដើម្បីបក្សក្តាប់សតិអារម្មណ៍វិវត្តរបស់វា ។

## V. ទស្សនៈគោលជំហរចំពោះស្មារតីប្រុងប្រយ័ត្នបដិវត្តន៍រក្សាការសម្ងាត់

១) យើងការពារខ្មាំងជាប់ទើបយើងសម្រេចភារកិច្ចសួរឈ្លេចឈ្លីចម្លើយខ្មាំងបាន ដូចនេះបើខ្មាំងរត់រួច ខ្មាំងប្រតិកម្ម ខ្មាំងឈឺដើរមិនរួច ហាមាត់មិនបានដោយទារុណកម្ម ខ្មាំងស្លាប់ ទាំងអស់នេះសុទ្ធតែរំខានដល់បក្ស ។

មិត្តយើងអ្នកសួរត្រូវកំណត់ទស្សនៈថា បញ្ហាការពារខ្មាំងឲ្យជាប់គឺជាភារកិច្ចទី១របស់យើង ។ ត្រូវកម្ចាត់ទស្សនៈថាភារកិច្ចការពារជាភារកិច្ចរបស់កងការពារទេ ។ ដើម្បីការពារជាប់ ត្រូវរៀនសូត្រពិសោធន៍របស់មិត្តយើងពីមុនដោយកំណត់ទស្សនៈថាដាក់ខ្នោះ ដាក់កង ដាក់រនងច្រវាក់ ឆែកឆេរក្នុងខ្លួនវា រាល់ពេលសួរកុំដាក់របស់អ្វីជិតវាក្រែងវាយកធ្វើជាអាវុធ កុំដេកសួរ កុំដើរចោលខ្មាំង បើមិត្តយើងអនុវត្តបានគឺជាសតិអារម្មណ៍អង្គការវិន័យ ។

២) ស្មារតីរក្សាការសម្ងាត់គឺជាដួងព្រលឹងរបស់ការងារសន្តិបាល អស់ការសម្ងាត់គឺអស់ន័យសន្តិបាលហើយ ។ វិធានការរបស់យើងដើម្បីរក្សាការសមាត់បានគឺ÷

ក) ការពារខ្មាំងឲ្យជាប់ ព្រោះបើវារត់រួចវាយកទៅនិយាយអំពីសេចក្តីសារភាពរបស់វា ។ ដូចនេះការសម្ងាត់សន្តិបាលគឺបែកចំកន្លែងដែលមិនត្រូវឲ្យបែកដាច់ខាត ។

ខ) ចម្លើយខ្មាំងកុំដើរនិយាយឆ្លងក្រុម ឆ្លងមន្ទីរ ឆ្លងក្រសួង ឆ្លងគ្រួសារ ។ ភារកិច្ចរាយការណ៍ឲ្យគឺមេក្រុមតាមការចាត់តាំង ។ ម្យ៉ាងទៀត ឯកសារដែលសល់អំពីរាយការណ៍ ហើយពុំមានផលប្រយោជន៍អ្វីសូមកុំទុករាយមាយ ត្រូវដុតចោល ប្រយ័ត្នធ្លាក់ដល់ដៃខ្មាំង ។

គ) កម្ចាត់ជំហរភ្លើតភ្លើនភ្លេចខ្លួន ផ្សងទណៈភាពការងារសន្តិបាល ។

៣) គិញរត់រួច គិញប្រតិកម្ម គឺយើងទទួលខុសត្រូវផ្ទាល់ខ្លួន ចំណែកមេក្រុមឬថ្នាក់លើគឺជួយរួមចំណែកកម្រិតណា

ប៉ុណ្ណោះ តែបើគេជួយណែនាំយើងជាបន្តបន្ទាប់ហើយយើងនៅតែសេរីនោះគឺយើងទទួលវិន័យម្នាក់ឯង ។

## VI. ការប្រជុំពិសោធន៍ចំពោះការងារសន្តិបាល

១) និយាយដល់សន្តិបាលគឺនិយាយដល់យើងនិងខ្មាំង ទាំងពីរខាងគឺមានទំនាស់ស្លាប់រស់ (បដិបក្ខ) កាលនៅលើសមរភូមិ យើងវាយប្រហារទីតាំង១គឺមានខ្មាំងតបតយើង យើងនិងខ្មាំងដៃកាន់កាំភ្លើងដូចគ្នា យើងមិនបាញ់វា វាមិនបាញ់យើង ។ តែចំពោះសន្តិបាល ខ្មាំងជាប់ចំណងមែន ទោះវាអត់អាវុធក្តី ទោះវាមានរូបភាពជាអ្នកបដិវត្តន៍ក្តី ក៏ធាតុពិតរបស់វាជាខ្មាំងចំពោះខ្មាំងក្បត់ផ្ទៃក្នុង ពួកប្រភេទនេះវាឃោរឃៅហើយស៊ីជម្រៅណាស់ ដូចនេះយើងត្រូវប្រុងប្រយ័ត្ន

ក) កុំឲ្យវារបូតពីចំណង វាវាយយើងបានវិញ

ខ) វាធ្វើអត្តឃាតខ្លួនវាដើម្បីលាក់ខ្សែសន្ទាក់ ។

គ) ភ្លេចខ្លួនមួយភ្លែតយើងគ្រោះថ្នាក់ បក្សលំបាកដោះស្រាយយើងផង ជួនរហូតអន្តរាយនយោបាយនិងវិធានការខ្វះរបស់បក្ស ។

ឃ) វាឆ្លើយដាក់កម្លាំងយើង យកពាក្យស្លោកបក្សកុម្មុយនិស្តបំផ្លាញបក្សកុម្មុយនិស្ត ។ ជាមួយនោះធ្វើឲ្យមានផលវិបាករឹតតែធ្ងន់ដល់បក្ស ហើយវារក្សាក្បាលម៉ាស៊ីនក្បត់របស់វាបាន ។

២) សរុបទៅខុសគ្នាមួយជំហានទេ ។

ដូចនេះ គ្រប់បាតុភាពដែលកើតមានឡើង យើងមានពិសោធន៍ដោះស្រាយជាប្រជុំដកពិសោធន៍ភ្លាមៗ កែប្រែពិសោធន៍ភ្លាមៗ ដើម្បីឲ្យទាន់សភាពការណ៍ ជាមួយនោះមិត្តយើងម្នាក់ៗក៏ត្រូវស្មោះត្រង់និងឆាប់រាយការណ៍បំផុត ។

ការងារសន្តិបាលទាមទារការប្រជុំពិសោធន៍ញឹកញាប់ ដោយគ្មានពេលកំណត់បានទៀងទាត់ទេ ។ សរសៃញាក់របស់យើងម្នាក់ៗគឺញាក់តែនឹងការប្រជុំពិសោធន៍ យើងប្រជុំពិសោធន៍ស្អេកស្កះ សស្រាក់សស្រាំ តាមអង្គភាពសួរទាំងមូលផង តាមមុខសញ្ញាផង តាមក្រុមផង តែជាពិសេសគឺយើងដកពិសោធន៍ខ្លួនឯង លួចរៀនពិសោធន៍ពីមិត្តដទៃផង រៀនពិសោធន៍របស់ថ្នាក់លើផង ។

៣) ជាពិសោធន៍កន្លងមក យើងដកពិសោធន៍ដោយប្រើពេលខ្លីយូរបំផុត១ម៉ោង យើងដកពិសោធន៍ក្រៅម៉ោងធ្វើការផងក៏មាន ដើម្បីកុំឲ្យមានខ្មាំងរត់រួច ហើយខ្លួនយើងក៏ធ្លាក់ក្នុងរឿងម៉ោងនិយមដែរ បើយើងគិតម៉ោងគឺមិនទាន់ផែនការដែលបក្សត្រូវមួយភ្លែតៗទេ ។

សរុបទៅ ភារកិច្ចរបស់យើងគឺបក្សត្រូវការថ្មើរណាគឺវាយសម្រុកពេលនោះ ។

## VII. ផ្នែកសរុប

១) ការងារសួរចម្លើយគឺសរុបចម្លើយ យើងសរុបដោយធ្វើការវិភាគនិងចម្រាញ់ចម្លើយ គឺជាការងារលម្អិតគ្រប់ជ្រុងជ្រោយថ្លឹងថ្លែងវិភាគគិតគូរពុំឲ្យមានចន្លោះពេល ។ គឺជាការងារសម្ងាត់បំផុត ។

២) មិត្តយើងអ្នកសួរគឺជាអ្នកពូកែឆ្ងល់ ពូកែឈ្លុសឈ្លុលដេញដោលដើម្បីទម្លាយអាថ៌កំបាំងនៅក្នុងខ្លួនវា ។

៣) ជំហររបស់យើងគឺអត់ធ្មត់ នឹងន មិនតក់ក្រហល់ មិនភ្លើតភ្លើននឹងជ័យជំនះបន្តិចបន្តួច មិនទិដ្ឋិនិយមអស់សង្ឃឹម តែសប្បាយរីករាយជាប់ជានិច្ចក្នុងគ្រប់ករណីបរាជ័យឬជ័យជំនះជាធម្មតា ហើយជំនឿលើបក្សគោរពការណែនាំរបស់បក្សឥតលក្ខខណ្ឌដាច់ខាតនិងរាបសាបំផុត គឺជាយុទ្ធមិត្តដែលមានអង្គការវិន័យខ្ពស់ មិនសេរីចង់ដឹងរឿងគេ មិនសេរីនិយាយរឿងយើងប្រាប់គេ ប្រុងប្រយ័ត្នរក្សាការសម្ងាត់បានខ្ពស់ ។

៤) ភារកិច្ចសួរចម្លើយគឺជាភារកិច្ចដែលមានការតស៊ូតឹងតែងរវាងយើងដែលជាអ្នកចង់ដឹងអាថ៌កំបាំងខ្មាំងដែលវាខំប្រើគ្រប់ឧបាយកលលាក់សកម្មភាពក្បត់ខ្សែសន្ទាក់និងមេកោយវា ។ គឺជាភារកិច្ចការពារប្រទេសដែលប្រកបទៅដោយការតស៊ូវណ្ណៈតឹងតែងនិងក្តៅងំជាប់ជានិច្ច ។



៥) ពិសោធន៍កន្លងមក កម្មាភិបាលយើងមិត្តយើងខ្លះយល់ថា ការងារសន្តិបាល ពិសេសផ្នែកសួរចម្លើយ ជាការងារបច្ចេកទេស ។ ការវាយតម្លៃបែបនេះគឺមកពីយើងមិនទាន់ជ្រួតជ្រាបភារកិច្ចសន្តិបាល មិនទាន់ស្គាល់សេជាតិសន្តិបាលនៅឡើយ ។

ឧទាហរណ៍ៈ ធ្វើម៉ាស៊ីនជាការបច្ចេកទេស វត្ថុបំណងរបស់បច្ចេកទេសគឺម្ចាស់ការលើធម្មជាតិ តែបច្ចេកទេសអាចបម្រើវណ្ណៈណាក៏បាន ។

ការងារសន្តិបាលជាការងារតស៊ូវណ្ណៈ គឺសំដៅកម្ទេចវណ្ណៈជិះជាន់ គាស់រំលើងឲ្យអស់ឫសគល់របស់វា ដើម្បីការពារបក្ស ការពារវណ្ណៈអធន ការពារកម្ពុជាប្រជាធិបតេយ្យ ការពារមាគ៌ាឯករាជ្យម្ចាស់ការ ដូចនេះគឺមានតែបក្សកុម្មុយនិស្តកម្ពុជាតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់វណ្ណៈអធនកម្ពុជាតែមួយ តែយើងបម្រើ យើងក្តាប់បញ្ហាតាមជាក់ស្តែង យើងខំជាប់ យើងចំរើនជាប់ ។ អាថ៌កំបាំរបស់ខ្មាំងទោះបីងងឹតយ៉ាងណាក៏យើងពិតជាគាស់រំលើងបាន កម្ទេចខបាយកលវាបាន ខ្សែចាត់តាំងវាបាន ផែនការវាបានកាន់តែមានប្រសិទ្ធភាព កាន់តែប្រយុទ្ធ កាន់តែស្គាល់សេជាតិជាយុទ្ធជនរបស់វណ្ណៈអធន កាន់តែសប្បាយ កាន់តែក្លាហានមិនឈប់ឈរ ។

គ្មានភ្នាក់ងារខ្មាំងណាធ្វើដូចយើងបានទេ ។

**ឯកសារខ្មែរក្រហមៈ D ០៦៩៣៦**



*«នេះគឺអគារ សេ "C" ដែលខ្ញុំ (ប៊ូ ម៉េង) ជាប់ក្នុងទីនេះ»*
*វិចិត្រករ ៈ ប៊ូ ម៉េង (អតីតជនរងគ្រោះនៅមន្ទីរស-២១)*

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៨២៧ | ហ៊ី ឆេងគួយ | សក្តិ១ | ភូមិភាគឦ | ៣០-៨-៧៦ | ១៦-៩-៧៦ |
| ៨២៨ | ស្រី ណាំ | អាត់សាដង់ | ភូមិភាគឦ | ៣០-៨-៧៦ | ១៦-៩-៧៦ |
| ៨២៩ | គីម យា | សក្តិ២ | ភូមិភាគឦ | ៣០-៨-៧៦ | ១៦-៩-៧៦ |
| ៨៣០ | គីម ភឿកទឿង | សក្តិ៤កាំភ្លើងធំ | ភូមិភាគឦ | ៣០-៨-៧៦ | ១៦-៩-៧៦ |
| ៨៣១ | ម៉ី សុខន | សក្តិ២ | ភូមិភាគឦ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៣២ | គង់ ហ៊ត | សក្តិ២ | ភូមិភាគឦ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៣៣ | ញ៉ែម សុវ៉ាន | ចក្របាលឯក | ភូមិភាគឦ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៣៤ | អាន ហៀវ ហៅ នង សំអឿន | អាត់សាដង់ | ភូមិភាគឦ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៣៥ | ហេង តៃម៉េង | សក្តិ១រថក្រោះ | ភូមិភាគឦ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៣៦ | ស៊ិន យ៉ែម | ទូរលេខ | កងពល៥០២ | ៤-៧-៧៦ | ១៦-៩-៧៦ |
| ៨៣៧ | គីម ប៊ិន ហៅ យាង | ប្រធានវរសេនាធំ | កងពល១៧០ | ៨-៧-៧៦ | ១៦-៩-៧៦ |
| ៨៣៨ | ដួង វ៉ិន | ប្រធានវរសេនាធំ | កងពល១៧០ | ៨-៧-៧៦ | ១៦-៩-៧៦ |
| ៨៣៩ | សុក ងីម ហៅ គាត | អនុវរសេនាធំ | កងពល១៧០ | ៨-៧-៧៦ | ១៦-៩-៧៦ |
| ៨៤០ | អន ញ៉ឹប ហៅ អ៊ុកដល | ជំនួយការ | កងពល១៧០ | ៩-៧-៧៦ | ១៦-៩-៧៦ |
| ៨៤១ | សាន ពុំ | ប្រធានពេទ្យ | កងពល១៧០ | ៩-៧-៧៦ | ១៦-៩-៧៦ |
| ៨៤២ | ឈីម ដូ | ប្រធានមន្ទីរ | កងពល១៧០ | ៩-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៣ | ប៊ុត យ៉ន | ជំនួយការ | កងពល១៧០ | ៩-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៤ | ជិន ឆាង ហៅ សាន | ស្នងការវរសេនាតូច | កងពល១៧០ | ៩-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៥ | ហួត សិត | ជំនួយវរសេនាធំ | កងពល១៧០ | ៩-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៦ | ប៉ាន់ ហួរ ហៅ ឈីម | មេក្រុម | កងពល៥០២ | ២៣-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៧ | យិន អេន ហៅ អ៊ាន | កងហា | កងពល៥០២ | ២៣-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៨ | ស៊ិន សារឿន | ជំនួយការកងពល | កងពល៥០២ | ២៣-៧-៧៦ | ១៦-៩-៧៦ |
| ៨៤៩ | នួន អុន | មេពួក | កងពល៥០២ | ២៥-៧-៧៦ | ១៦-៩-៧៦ |
| ៨៥០ | ព្រុំ អឿន | កងហា | កងពល៥០២ | ២៥-៧-៧៦ | ១៦-៩-៧៦ |
| ៨៥១ | ទុំ ខេន ហៅ ខន | យុទ្ធជន | កងពល៥០២ | ២៥-៧-៧៦ | ១៦-៩-៧៦ |
| ៨៥២ | ចាន់ ដាន | មេក្រុម | កងពល៥០២ | ២៨-៧-៧៦ | ១៦-៩-៧៦ |
| ៨៥៣ | ឃ្លោក ព្រិល | មេក្រុម | កងពល៥០២ | ២៨-៧-៧៦ | ១៦-៩-៧៦ |
| ៨៥៤ | អ៊ុក វ៉ាត | មេក្រុម | កងពល៥០២ | ៣១-៧-៧៦ | ១៦-៩-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ៨៥៥ | សាន់ ម៉ុន | យុទ្ធជន | កង៥០២ | ៣១-៧-៧៦ | ១៦-៩-៧៦ |
| ៨៥៦ | គង់ អួន | យុទ្ធជន | កង៥០២ | ៣១-៧-៧៦ | ១៦-៩-៧៦ |
| ៨៥៧ | ឌុល ឡួន | មេពួក | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៥៨ | ឯក អឿន | មេពួក | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៥៩ | នួន ស៊ាប ហៅ ដាន | យុទ្ធជន | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦០ | ឡាយ ឡឿន | យុទ្ធជន | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦១ | ភិន អុល | មេក្រុម | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦២ | កែវ ដានី | មេក្រុម | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៣ | សោម នៅ ហៅ សាម៉ន | មេក្រុម | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៤ | នៅ ណាត | យុទ្ធជន | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៥ | ម៉ូវ មុត | យុទ្ធជន | កង៥០២ | ១-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៦ | ស្រី ឈិន ហៅ កួយ | យុទ្ធជន | កង៥០២ | ៣-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៧ | នៅ អាង ហៅ ដាត | យុទ្ធជន | កង៥០២ | ៣-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៨ | សេង សារ៉េត | យុទ្ធជន | កង៥០២ | ៣-៨-៧៦ | ១៦-៩-៧៦ |
| ៨៦៩ | ដួន នួន | មេក្រុម | កង៥០២ | ៣-៨-៧៦ | ១៦-៩-៧៦ |
| ៨៧០ | មុី ថែម | មេក្រុម | កង៥០២ | ៣-៨-៧៦ | ១៦-៩-៧៦ |
| ៨៧១ | ព្រៀម ចាន់ណា | យុទ្ធជន | កង៥០២ | ៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៧២ | នុត វ៉ាត | យុទ្ធជន | កង៥០២ | ៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៧៣ | សោម វង់ | យុទ្ធជន | កង៥០២ | ១២-៨-៧៦ | ១៦-៩-៧៦ |
| ៨៧៤ | សោម វ៉ាត ហៅ សាម៉ឺន | អនុក្រុម | កង៥០២ | ១២-៨-៧៦ | ១៦-៩-៧៦ |
| ៨៧៥ | ម៉ាន់ ធូ | មេក្រុម | កង៥០២ | ១២-៨-៧៦ | ១៦-៩-៧៦ |
| ៨៧៦ | ជា គ្រាន់ | មេក្រុម | កង៥០២ | ១២-៨-៧៦ | ១៦-៩-៧៦ |
| ៨៧៧ | ងិន សារិន | យុទ្ធជន | កង៥០២ | ១២-៨-៧៦ | ១៦-៩-៧៦ |
| ៨៧៨ | មាន អឿន | អនុក្រុម | កង៥០២ | ៣០-៧-៧៦ | ១៦-៩-៧៦ |
| ៨៧៩ | រស់ ឆេង | យុទ្ធជន | កង១៧០ | ២០-៨-៧៦ | ១៦-៩-៧៦ |
| ៨៨០ | យិន សយ | សេដ្ឋកិច្ចកងវរយ | កង១៧០ | ២០-៨-៧៦ | ១៦-៩-៧៦ |
| ៨៨១ | សោម សារឿន | ជំនួយសេដ្ឋកិច្ច | កង១៧០ | ២០-៨-៧៦ | ១៦-៩-៧៦ |
| ៨៨២ | ណុប ខែម | គ្រូខ្មែរ | កង១៧០ | ១៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៨៣ | ព្រាប អាន | មេក្រុម | កង១៧០ | ១៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៨៤ | បេង ហេ ហៅ ណារិន | មេក្រុម | កង១៧០ | ១៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៨៥ | ជុំ សារ៉ន | យុទ្ធជន | កង១៧០ | ១៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៨៦ | នួន ទន | យុទ្ធជន | កង១៧០ | ២០-៨-៧៦ | ១៦-៩-៧៦ |
| ៨៨៧ | អ៊ឹម ដុន | យុទ្ធជន | កង១៧០ | ២០-៨-៧៦ | ១៦-៩-៧៦ |
| ៨៨៨ | ពៅ សុត ហៅ សុភា | មេក្រុម | កង១៧០ | ២៦-៨-៧៦ | ១៦-៩-៧៦ |

(នៅមានត)

# ទុយ គិនៈ ជំងឺផ្លូវចិត្ត

ទុយ គិន បានទទួលការព្យាបាលជំងឺផ្លូវចិត្តពីសំណាក់វេជ្ជបណ្ឌិតឯកទេសផ្នែកជំងឺផ្លូវចិត្តនៅផ្ទះរបស់គាត់ ស្ថិតនៅស្រុកកោះធំ ខេត្តកណ្តាល ។ គិន ធ្លាប់ធ្វើជាយុទ្ធនារីខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៩ ។ ស្ថិតនៅក្នុងផ្ទះរបស់គាត់ដែលសង់អំពីឈើប្រក់ស្បូវ គិន បានឲ្យដឹងថា កាលពីពេលសុខភាពរបស់គាត់មិនទាន់ទ្រុឌទ្រោម គាត់តែងតែដើរធ្វើការឲ្យអ្នកស្រុកដើម្បីយកប្រាក់កម្រៃមកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។ បច្ចុប្បន្ននេះ ដោយសារបញ្ហាសុខភាពមិនប្រក្រតី មានថ្ងៃខ្លះគាត់មិនអាចចេញទៅរកប្រាក់បានឡើយ ។ ទោះបីជាពេលវេលាបានកន្លងទៅជាងម្ភៃឆ្នាំទៅហើយក្តី រឿងរ៉ាវអតីតកាលរបស់ គិន នៅក្នុងរបបខ្មែរក្រហមនៅតែប៉ះពាល់ដល់អារម្មណ៍និងជីវភាពគ្រួសាររបស់គាត់ជាប់ជាប្រចាំ ។

មជ្ឈមណ្ឌលឯកសារកម្ពុជារួមជាមួយអង្គការសុខភាពផ្លូវចិត្តសហគមន៍ (TPO) បានរៀបចំឡើងនូវកម្មវិធីព្យាបាលជំងឺផ្លូវចិត្តមួយ ដើម្បីព្យាបាលជនរងគ្រោះនិងអតីតកម្មាភិបាលថ្នាក់ក្រោមរបស់ខ្មែរក្រហម ។ កម្មវិធីនេះបានចាប់ផ្តើមអនុវត្តចាប់តាំងពីដើមឆ្នាំ២០០៣ រួមជាមួយកម្មវិធីដទៃទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងអនុវត្តរហូតមកដល់សព្វថ្ងៃនេះ រួមមាន «កម្មវិធីជំរុញឲ្យមានការទទួលខុសត្រូវខ្ពស់បំផុតរបស់ខ្មែរក្រហម» «កម្មវិធីផ្សះផ្សាផ្លូវចិត្តតាមរយៈការខិតចូលជិតជីវភាពរស់នៅរាល់ថ្ងៃរបស់អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម និងសាកសួរពត៌មានផ្សេងៗទាក់ទិននឹងរឿងរ៉ាវកាលពីរបបខ្មែរក្រហម» «ការស្ទាបស្ទង់មតិ» និង «កម្មវិធីធ្វើកោសល្យវិច័យឆ្អឹងនិងលលាដ៍ក្បាលជនរងគ្រោះសម័យខ្មែរក្រហម» និងកម្មវិធីដែលបង្កើតក្រោយគឺ «កម្មវិធីផ្តល់ការប្រឹក្សានិងថែទាំសុខភាពផ្លូវចិត្ត» ។ ក្នុងកម្មវិធីផ្តល់ការប្រឹក្សានិងសុខភាពផ្លូវចិត្តនេះមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការសុខភាពផ្លូវចិត្តសហគមន៍បានជ្រើសរើសយកស្រុកកោះធំនិងស្រុកស្អាង ខេត្តកណ្តាលជាកន្លែងបំពេញការងារ ។


ទុយ គិន ឆ្នាំ១៩៧៧


ទុយ គិន ឆ្នាំ២០០៣

កម្មវិធីព្យាបាលជំងឺផ្លូវចិត្តដូចដែលរៀបរាប់មកនេះបាននិងកំពុងសហការរួមគ្នារវាងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានតួនាទីផ្តល់ពត៌មាននិងស្វែងរកលំនៅឋានអតីត

កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមនិងជនរងគ្រោះ និងបុគ្គលិកអង្គការសុខភាពផ្លូវចិត្តសហគមន៍ដែលមានតួនាទីផ្តល់ការប្រឹក្សាយោបល់ និងផ្តល់ការព្យាបាលផ្សេងទៀតទាក់ទងនឹងសុខភាពផ្លូវកាយនិងផ្លូវចិត្ត ។

មជ្ឈមណ្ឌលឯកសារកម្ពុជាអាចស្វែងរកអតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះតាមរយៈឯកសារប្រវត្តិរូបរបស់អ្នកទាំងនោះដែលបានធ្វើនៅក្នុងរបបខ្មែរក្រហម ហើយដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ ។ នៅក្នុងរយៈពេល៦ខែដំបូងក្រុមការងារបានព្យាបាលអតីតកម្មាភិបាលខ្មែរក្រហមចំនួន ១៥នាក់ដែលពិនិត្យឃើញថាមានជំងឺផ្លូវចិត្ត ។

តាមរយៈប្រវត្តិរូបមួយសន្លឹក នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០៣ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា នាយកអង្គការសុខភាពផ្លូវចិត្តសហគមន៍និងបុគ្គលិករបស់លោកចំនួន២រូបទៀតគឺវេជ្ជបណ្ឌិត ជី វុទ្ធី និង គាំ សុខអណ្ដែត ព្រមទាំងខ្ញុំ (ផេង ពង្សរ៉ាស៊ី) ដែលជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅជួបជាមួយនឹង ទុយ គិន ។ គិន បានប្រាប់អំពីអាការៈជំងឺរបស់គាត់ដល់ក្រុមវេជ្ជបណ្ឌិតទាំងសភាពហេវហត់ អស់កម្លាំង ស្ពេកស្ពាំង ញញើញញ័រ និងលាយឡំដោយការភិតភ័យ ។ ក្រុមវេជ្ជបណ្ឌិតបានសួរសំណួរជុំវិញបញ្ហាសុខភាពរបស់គាត់ទាក់ទងនឹងព្រឹត្តិការណ៍នានាដែលបណ្តាលឲ្យគាត់មានសភាពបែបនេះ ។

ក្រុមវេជ្ជបណ្ឌិតមិនទាន់អនុវត្តការព្យាបាលភ្លាមៗទេ ទោះបីជាបានពិគ្រោះនិងស្វែងយល់អំពីប្រភេទជំងឺជាលើកដំបូងរួចហើយយ៉ាងណាក៏ដោយ ។ បន្ទាប់ពីមានការស្នើសុំ គិន រួមទាំងក្រុមគ្រួសាររបស់គាត់ផងនោះ មួយសប្តាហ៍ក្រោយ ក្រុមវេជ្ជបណ្ឌិតចាប់ផ្តើមព្យាបាលជំងឺរបស់ គិន ។ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា ជាអ្នកព្យាបាល គិន ដោយផ្ទាល់ ។ លោកបានឲ្យដឹងថាជំងឺផ្លូវចិត្តរបស់ គិន មានសភាពធ្ងន់ធ្ងរដោយសារវាមានការលាយចូលគ្នារវាងជំងឺធ្លាក់ទឹកចិត្តនិងជំងឺបាក់ស្បាតដែលបណ្តាលមកពីការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងក្លាជាយូរឆ្នាំមកហើយ ។ គិន ពុំដែលបានទទួលការព្យាបាលផ្នែកផ្លូវចិត្តពីមុនមកសោះ ។ ជំងឺដែលមានលក្ខណៈដូចគាត់បែបនេះ គ្រូពេទ្យជំងឺទូទៅ ឬគ្រូពេទ្យដែលពុំមានជំនាញផ្នែកចិត្តរោគ មិនអាចធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលបានត្រឹមត្រូវឡើយ ។

វេជ្ជបណ្ឌិត ឈឹម សុធារ៉ា មានប្រសាសន៍បន្តថា “ជំងឺដូច គិន ចាំបាច់ណាស់ត្រូវការពេលវេលាច្រើនដើម្បីព្យាបាល ហើយការព្យាបាលទៀតសោតត្រូវមានការចូលរួមពីសំណាក់ក្រុមគ្រូពេទ្យជំនាញជំងឺផ្លូវចិត្ត ឬអ្នកចិត្តវិទ្យា សហគមន៍ ជាពិសេសពីសំណាក់ក្រុមគ្រួសារនិង ទុយ គិន ខ្លួនឯងផ្ទាល់តែម្តង ។ ជាដំបូងយើងត្រូវធ្វើយ៉ាងណាឲ្យគាត់មានការទុកចិត្តមកលើយើង (គ្រូពេទ្យឬវេជ្ជបណ្ឌិត) ជាមុនសិន ។ បន្ទាប់មកទៀតទើបយើងប្រាប់គាត់ព្រមទាំងទាញហេតុផលនានាដែលអាចឲ្យគាត់យល់ដោយខ្លួនឯងថាជំងឺរបស់គាត់សព្វថ្ងៃនេះវាមានទំនាក់ទំនងទៅនឹងបញ្ហាដែលគាត់ធ្លាប់ជួបប្រទះកាលពីអតីតកាល ។ នេះជាករណីសំខាន់បំផុតពីព្រោះអ្នកជំងឺភាគច្រើនមិនបានគិតថា ជំងឺសព្វថ្ងៃរបស់ខ្លួនពិតជាជាប់ទាក់ទងទៅនឹងរឿងរ៉ាវពីអតីតកាលនោះទេ បែរជាគិតផ្សាយៗថាជាជំងឺរាងកាយទៅវិញ ។ ការព្យាបាលជំងឺផ្លូវចិត្តត្រូវប្រើវិធីច្រើនយ៉ាង រួមមានទាំងការព្យាបាលតាមបែបចិត្តសាស្ត្រដែលទាមទារឲ្យអ្នកជំងឺត្រូវធ្វើលំហាត់សម្រាកកាយ លំហាត់ដកដង្ហើម លំហាត់បន្ធូយកំហឹង ឬលំហាត់ប្រើគំនិតតាមបែបចិត្តសាស្ត្រផ្សេងៗ ។ ការព្យាបាលតាមវិធីសាស្ត្រដូចដែលបានរៀបរាប់នេះ ចាំបាច់អ្នកជំងឺម្នាក់ៗត្រូវតែអនុវត្តឲ្យបានជាប្រចាំតាមការណែនាំរបស់គ្រូពេទ្យឬវេជ្ជបណ្ឌិត ។ ក្នុងករណីដែលជំងឺផ្លូវចិត្តមានលក្ខណៈធ្ងន់ធ្ងរ អ្នកជំងឺចៀសមិនផុតពីការប្រើប្រាស់ថ្នាំពេទ្យបន្ថែមទៀតឡើយ ។

ដោយសារតែកង្វល់អំពីជីវភាពប្រចាំថ្ងៃ រួមផ្សំនឹងរឿងរ៉ាវអតីតកាលជំនាន់របបខ្មែរក្រហមនៅតែវិលវល់ក្នុងអារម្មណ៍ផងនោះ ទើបជំងឺរបស់ គិន ធ្លាក់ដល់កម្រិតបែបនេះ ។ ស្ថិតក្នុងស្ថានភាពដែលមានជំងឺបៀតបៀន គិន មិនបានគិតគូរនិងចាប់អារម្មណ៍អំពីអ្វីទាំងអស់ សូម្បីតែការរៀបចំឲ្យមានតុលាការឯករាជ្យមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ឬក៏ការបោះឆ្នោតជាតិកាលពីចុងខែកក្កដាឆ្នាំ២០០៣នេះក៏ដោយ ។ មុនពេលទទួលបានការព្យាបាលពីវេជ្ជបណ្ឌិតជំនាញខាងចិត្តសាស្ត្រ គិន ក៏ធ្លាប់ទទួលការព្យាបាលដោយគ្រូពេទ្យនៅក្នុងភូមិនិងគ្រូថ្នាំបុរាណជាច្រើនលើកមកហើយដែរ ប៉ុន្តែគាត់មិនបានធូរស្បើយ

ឡើយ ។ គិន បានប្រាប់ថា រហូតមកដល់សព្វថ្ងៃនេះ គាត់នៅតែបន្តដាំថ្នាំបុរាណដែលគាត់បានទិញមកពិសាជដដែល ។ គិន យល់ដោយខ្លួនឯងថា ការព្យាបាលដោយប្រើឱសថបុរាណប្រហែលជាមានប្រសិទ្ធភាពច្រើនជាង ប៉ុន្តែផ្ទុយទៅវិញ គិន នៅតែទទួលរងការញាំញីពីរោគារបស់គាត់គ្មានថ្ងៃណាស្រាកស្រាន្ត ។ ការងាររចិញ្ចឹមជីវិតត្រូវផ្អាកអស់រយៈពេលយ៉ាងយូរ ដោយសារគ្មានកម្លាំងកំហែង ។

ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិតេយ្យ ប្រជាជនស្លូតត្រង់ប្រមាណពីរលាននាក់បានស្លាប់បាត់បង់ជីវិតដោយសារជំងឺ ការអត់ឃ្លាន ការបង្ខំឲ្យធ្វើពលកម្មហួសកម្លាំង និងការសម្លាប់រង្គាល ។ អ្នកដែលរួចផុតពីសេចក្ដីស្លាប់ភាគច្រើនបានបន្តរស់នៅជាមួយនឹងស្លាកស្នាមរបួសផ្លូវចិត្តនិងសុបិនអាក្រក់មកពីអតីតកាលដែលមិនអាចបំភ្លេចបានក្រោមទារុណកម្មរបស់ខ្មែរក្រហម ។ គិន និយាយថា «ជីវិតរបស់ខ្ញុំពុំដែលមានថ្ងៃណាបានរីករាយឡើយ» ។

នៅក្នុងឆ្នាំ១៩៨០ គិន ត្រូវបានអាជ្ញាធរខេត្តកណ្ដាលឃុំខ្លួនរយៈពេល១៨ខែនៅមន្ទីរឃុំឃាំងខេត្តកណ្ដាល ពីបទជាប់ពាក់ព័ន្ធជាមួយរបបខ្មែរក្រហម និងចោទប្រកាន់ថាបានសម្លាប់អ្នកទោសចំនួន៣០០នាក់នៅមន្ទីរសន្តិសុខខ្មែរក្រហម ស-២១ (គុកទួលស្លែង) ។ មូលហេតុដែលនាំឲ្យមានការចោទប្រកាន់នោះ ដោយសារតែរូបថតមួយសន្លឹករបស់គាត់(រូបក្របមុខនៃទស្សនាវដ្ដីនេះដែលថតសម្រាប់ធ្វើប្រវត្តិរូបនៅក្នុងរបបខ្មែរក្រហមត្រូវបានដាក់តាំងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ទោះបីជាយ៉ាងណាក៏ដោយ គិន បាននិយាយថា «ខ្ញុំសំបូងសង្រួងថា ប្រសិនបើខ្ញុំពិតជាបានសម្លាប់បងប្អូនណាម្នាក់មែននោះ សូមទេព្តាបរាមុខខ្ញុំទៅចុះ» ។

ទោះបីជា គិន ត្រូវបានដោះលែងឲ្យមានសេរីភាពវិញក៏ដោយ ក៏គាត់ត្រូវរស់នៅក្នុងភាពមន្ទិលសង្ស័យពីសំណាក់ញាតិជិតខាងចំពោះអតីតភាពរបស់គាត់ដែលជិតជាមមកអំពីរបបខ្មែរក្រហម ។ គ្រូពេទ្យម្នាក់ឈ្មោះ ហ៊ិ លាងស្រ៊ី ដែលធ្លាប់បានព្យាបាលជំងឺរបស់ គិន បាននិយាយថា «ពីមុនមកខ្ញុំស្អប់វា(គិន) ខ្លាំងណាស់ ខ្ញុំចង់សម្លាប់វាទៀតផង ពីព្រោះវាជាកម្មាភិបាលខ្មែរក្រហម ។ អ្នកភូមិមួយចំនួនក៏ធ្លាប់បានគិតដូចខ្ញុំដែរចំពោះអតីតកាលរបស់ គិន ។ បន្ទាប់ពីព្យាបាលជំងឺរបស់ គិន មួយរយៈកន្លងមក ឥឡូវនេះខ្ញុំលែងស្អប់វាទៀតហើយ ។ ខ្ញុំដឹងថា គិន គ្រាន់តែជាឧបករណ៍របស់ខ្មែរក្រហមតែប៉ុណ្ណោះ» ។

គិន បាននិយាយថា «ខ្ញុំដឹងថាអ្នកភូមិមួយចំនួនស្អប់ខ្ញុំ ចោទខ្ញុំថាជាប៉ុលពត ។ ខ្ញុំមិនខឹងនឹងគេទេ នេះដោយសារតែខ្ញុំធ្លាប់ធ្វើជាកងទ័ពនារីឲ្យ ប៉ុលពត ប៉ុន្តែខ្ញុំមិនដែលសម្លាប់មនុស្សទេ ។» បច្ចុប្បន្ន គិន កំពុងទទួលការព្យាបាលដោយមិនយកប្រាក់កម្រៃពីសំណាក់ក្រុមវេជ្ជបណ្ឌិតឯកទេសជំងឺផ្លូវចិត្តនៃអង្គការសុខភាពផ្លូវចិត្តសហគមន៍ ក្រោមការឧបត្ថម្ភថវិកាពីស្ថានទូតហុល្លង់ ប្រចាំនៅទីក្រុងបាងកក ។ ទន្ទឹមនឹងនេះ គិន ក៏បានទទួលការថែរក្សាពីកូនស្រីរបស់គាត់ដែលមានអាយុ១៩ឆ្នាំ និងប្ដីរបស់គាត់ដែលមានអាយុជាង៦០ឆ្នាំទៅហើយ ។

**រដ្ឋ ពន្យ៉ាស៊ី**

# ពន្យល់ពាក្យខ្មែរក្រហម

◆ ***កសិកម្មសម័យ:*** ការធ្វើស្រែចម្ការដោយប្រើកម្លាំងម៉ាស៊ីនពី៧០-៨០ភាគរយឡើងទៅ ហើយម្ចាស់ការលើកទំនប់ទឹកលើដី លើថ្នាំកសិកម្មនិងបច្ចេកទេសដាំដុះទាំងស្រុង ។

◆ ***សហជីព:*** អង្គការដែលកម្មកររស់នៅគិតគូរ ធ្វើការងារនិងទទួលផលជាសមូហភាពទាំងអស់ ។

◆ ***ស្រែសម័យ:*** ស្រែដែលមានប្រព័ន្ធភ្លឺប្រឡាយថ្មីកាត់ខ្វាត់ខ្វែងជាក្រឡាឈើត្រង់ ។

◆ ***ខន្ទេសនាម:*** អធិប្បាយពន្យល់អំពីបញ្ហាអ្វីមួយ ។

◆ ***និស្ស័យពលកម្ម:*** ចិត្តគំនិតស្រឡាញ់ការងារដែលធ្វើដោយបញ្ចេញកម្លាំង ។

***(ដកស្រង់ចេញពីសៀវភៅរៀនអក្សរថ្នាក់ទី២ ឆ្នាំ១៩៧៧)***

# តើសម្លាប់មនុស្សច្រើនយ៉ាងនេះដើម្បីអ្វី?


សៅ ជុន

សៅ ជុន បានចាកចេញពីឪពុកម្តាយនិងស្រុកកំណើតដើម្បីចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧៤ ។ គាត់ត្រូវបានអង្គការខ្មែរក្រហមចាត់តាំងឲ្យធ្វើការជាច្រើនកន្លែង ។

សៅ ជុន មានស្រុកកំណើតនៅភូមិចេក ឃុំរកា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ គាត់មានឪពុកឈ្មោះ គង់ សៅ ម្តាយឈ្មោះ គឿន សៅ បច្ចុប្បន្នលោកទាំងពីរអនិច្ចកម្មទៅហើយ ។ ជុន មានបងប្អូនប្រាំនាក់ ។ ជុន ធំពេញវ័យចំពេលដែលប្រទេសកម្ពុជាមានសង្គ្រាម ហើយតំបន់មួយចំនួនមានការប្រយុទ្ធប្រទាញប្រទង់គ្នាយ៉ាងខ្លាំងរវាងខ្មែររំដោះនិងរបបសាធារណរដ្ឋខ្មែរ ។ ជុន ជាកូនកសិករដែលមានវណ្ណៈភាពកណ្តាលថ្នាក់ក្រោម និងបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៧ចាស់ ។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៤ ជុន បានស្ម័គ្រចិត្តចូលខ្មែររំដោះដោយសារគណៈឃុំអប់រំបំពាក់បំប៉នមនោគមវិជ្ជាឲ្យមានការឈឺចាប់ចំពោះខ្មាំងសត្រូវ ។ មុនដំបូង ជុន បានទទួលតួនាទីមេពួកនិងបន្ទាប់មកទៀតបានក្លាយជាមេក្រុម ។ មុនកងទ័ពខ្មែរក្រហមកាន់កាប់ទូទាំងប្រទេស ជុន មាននាទីប្រមូលកងនារីទាំងអស់ទៅប្រចាំការនៅផ្លូវជាតិលេខ៤ ដើម្បីជួយដឹកជញ្ជូនគ្រាប់និងចាំទទួលជ័យភណ្ឌពីកងទ័ពខ្មែររំដោះដែលវាយដណ្តើមបានទីតាំងខាងទាហានលន់ណុល ។ ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមបានទទួលជ័យជំនះ អង្គការបានចាត់តាំង ជុន ឲ្យមកនៅទីក្រុងភ្នំពេញ ក្នុងកងវរសេនាតូចលេខ២៥០ ក្រោមការគ្រប់គ្រងរបស់ រ៉េន ។

នៅខែកក្កដាឆ្នាំ១៩៧៥ អង្គការបានចាត់តាំងក្រុមនារីឲ្យមករៀនកាត់ដេរនៅក្បែរស្ថានទូតចិន ដើម្បីកាត់ដេរសម្លៀកបំពាក់កងទ័ព ។ ជុន បានឲ្យដឹងថា កាលនោះទីក្រុងភ្នំពេញមានសភាពស្ងាត់ច្រៀប គឺមានតែរោងចក្រមួយចំនួនប៉ុណ្ណោះដែលដំណើរការដោយកម្មាភិបាលខ្មែរក្រហមដែលមានសម្លៀកបំពាក់ពណ៌ខ្មៅ ។ ជុន និយាយថាក្រុមនារីកាត់ដេរទាំងអស់ត្រូវផ្លាស់ប្តូរគ្នារវាងពីរខែម្តង គឺពីរខែធ្វើស្រែ និងពីរខែកាត់ដេរសម្លៀកបំពាក់ឲ្យកងទ័ព ។

ក្រោយមក អង្គការបានចាត់តាំងឲ្យ ជុន ទៅធ្វើការនៅរោងចក្រក្តារបន្ទះស្ថិតនៅភូមិស្ពានកន្លែង ស្រុកកៀនស្វាយ ខេត្តកណ្តាល តាមបណ្តោយផ្លូវជាតិលេខ១វិញ ។ រោងចក្រនេះមានទីតាំងនៅជាប់នឹងមាត់ទន្លេ ព្រោះងាយស្រួលយកឈើមូលឡើងពីទន្លេ ។ ឈើមូលល្អៗយកមកពីខេត្តក្រចេះដោយចងជាក្បូនបណ្តែតតាមទឹកទន្លេ ។ អ្នកធ្វើការនៅរោងចក្រក្តារបន្ទះភាគច្រើនជាស្ត្រី និងមានជនាញការចិនមកបង្រៀនផ្នែកបច្ចេកទេស ។ ក្តារដែលកែច្នៃហើយ ត្រូវដាក់ចូលឡាំងដឹកទៅប្រទេសចិន ។ ជុន បានឲ្យដឹងថា ការងារនៅក្នុងរោងចក្រក្តារបន្ទះពុំដែលមានថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃច័ន្ទឡើយ ។ ចំណែកការហូបចុកគ្រប់គ្រាន់ហើយ យប់ខ្លះមានបញ្ចាំងខ្សែភាពយន្តអំពីប្រទេសចិនឲ្យយុទ្ធជនយុទ្ធនារីមើលទៀតផង ។ ធ្វើការនៅរោងចក្រក្តារបន្ទះបានបួនខែ ជុន ត្រូវអង្គការបញ្ជូនមកកាត់ដេរនៅទីក្រុងភ្នំពេញវិញ ។

នៅខែឧសភា ឆ្នាំ១៩៧៧ អង្គការបានបង្ខំឲ្យ ជុន រៀបការ ។ ក្នុងពិធីរៀបការពេលនោះមានយុទ្ធជនយុទ្ធនារីចំនួន២៨គូ ។ យុទ្ធជននិងយុទ្ធនារីដែលត្រូវរៀបការនឹងគ្នាពុំដែលបានស្គាល់មុខគ្នាពីមុនមកទេ ហើយឪពុកម្តាយមិនមានវត្តមាននៅពេលរៀបការនោះទេ ។ ជុន និយាយថា “គួរឲ្យស្តាយណាស់ ពេលមានប្តីមិនបានរៀបការតាមប្រពៃណីខ្មែរ ហើយឪពុកម្តាយបងប្អូនក៏មិនដឹងនៅទីណា?” ។ ពិធីរៀបការធ្វើឡើងដោយគ្រាន់តែឲ្យប្តីប្រពន្ធឡើងចាប់ដៃគ្នាប្តេជ្ញាចិត្តព្រមទទួលយកគ្នា និងប្តេជ្ញាចិត្តដើរតាមមាគ៌ារបស់អង្គការ ។ បន្ទាប់ពីរៀបការ អង្គការអនុញ្ញាតឲ្យប្តីប្រពន្ធរស់នៅជាមួយគ្នាបានតែមួយថ្ងៃគត់ ។ បន្ទាប់ពីនោះត្រូវបំបែកទៅធ្វើការនៅតាមអង្គភាពរៀងៗខ្លួនវិញ ។

ពីរខែក្រោយមក ខ្មែរក្រហមយកប្តីរបស់ ថុន ទៅសម្លាប់ ព្រោះគាត់ជាអតីតយុទ្ធជននៅកងពល៧០៣ ។ មិនបានប៉ុន្មានខែផង ខ្មែរក្រហមក៏ចាប់ ថុន ទៅដាក់គុកនៅវត្តគោកខ្សាច់មួយរយៈដោយសារជាប់និន្នាការពីប្តី ។

នៅឆ្នាំ១៩៧៨ អង្គការបានដោះលែង ថុន រួចបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលដល់ទីក្រុងភ្នំពេញ ថុន បានរត់ទៅព្រំដែនថៃអស់មួយរយៈ ។ ក្រោយមកដោយមានការនឹករលឹកឪពុកម្តាយបងប្អូន ណាមួយរស់នៅក្នុងព្រៃលំបាកវេទនាផង ថុន ក៏សម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតវិញ ។

បច្ចុប្បន្ន ថុន មានអាយុ៥០ឆ្នាំ និងជាស្ត្រីមេម៉ាយគ្មានកូន ។ ថុន នៅតែមានកាយសម្បទាមាំមួននៅឡើយ ។ គាត់ដិះកង់ពីភូមិមួយទៅភូមិមួយប្រកបរបររកទទួលទានចិញ្ចឹមជីវិត ។ នៅក្នុងរបបខ្មែរក្រហម ថុន មិនបានដឹងថាមានការសម្លាប់មនុស្សដ៏ច្រើនទេ ព្រោះកាលដែលគាត់ធ្វើការនៅក្នុងរោងចក្រ គាត់បានទទួលរបបហូបចុកធម្មតាមិនមានការខ្វះខាតឡើយ ហើយគាត់ក៏មិនដែលឃើញខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់ចោលដែរ ។ គាត់គ្រាន់តែដឹងថាមានយុទ្ធជនខ្លះត្រូវផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយនិងខ្លះទៀតត្រូវនាំយកទៅរៀនសូត្រតែប៉ុណ្ណោះ ។ រហូតដល់ក្រោយឆ្នាំ១៩៧៩ តាមរយៈខ្សែភាពយន្តឯកសារ និងការឃើញរណ្តៅសាកសពតាមភូមិ ស្រុកដោយផ្ទាល់ភ្នែក ទើប ថុន ភ្ញាក់ខ្លួននិងដឹងថាមានការសម្លាប់មនុស្សយ៉ាងរង្គាលនៅក្នុងរបបខ្មែរក្រហម ។ ថុននិយាយថា “មិនសមណាអ្នកដឹកនាំរបបខ្មែរក្រហមនាំគ្នាប្រព្រឹត្តអំពើព្រៃផ្សៃមកលើជាតិសាសន៍ខ្លួនឯងសោះ ។ ថុន សួរថាធ្វើនេះមានប្រយោជន៍អ្វីខ្លះសម្រាប់ប្រទេសជាតិ? តើសម្លាប់មនុស្សច្រើនយ៉ាងនេះដើម្បីអ្វី?» មិនមែនមានតែ ថុន ម្នាក់ទេដែលឆ្ងល់ ប្រជាជនកម្ពុជាទាំងអស់ក៏ឆ្ងល់ និងចង់បានចម្លើយពុទ្ធនិងត្រចៀកពីមេដឹកនាំខ្មែរក្រហមទាំងអស់ ។

**សុខ ខណ្ណៈ**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ “**វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជា-ធិបតេយ្យ**” ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការបងចាំ គឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី “ស្វែងរកការពិត” ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ និង០១២ ៩៨៨ ១៧៦ ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ។

**យូ បូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# មិនចង់នឹកឃើញការឈឺចាប់


សុខ យិន

លោកតា សុខ យិន អាយុ៨១ឆ្នាំ រស់នៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ លោកតាកើតឆ្នាំឆ្លូវ នៅភូមិឃុំ ដែលលោកតារស់នៅបច្ចុប្បន្ន ។ ឪពុកម្តាយរបស់តាឈ្មោះ តាសុខ យាយហែម ។ លោកតាមានបងប្អូនបង្កើតចំនួន៧នាក់ ខ្លួនលោកតាជាកូនទី២ ។ កាលពីនៅក្មេង កុមារ យិន ត្រូវម្តាយ ប្រើឲ្យមើលគោជារៀងរាល់ថ្ងៃ លុះដល់អាយុ៦ឆ្នាំ ទើបម្តាយ ឪពុកយកទៅឲ្យសំណាក់រៀនអក្សរលេខនពុទ្ធជាមួយព្រះសង្ឃ នៅវត្តកំពង់ត្រឡាចលើ ។ ដោយសារឪពុកម្តាយជាអ្នកទីទ័លក្រ គ្មានអ្នកជួយជំនួសកម្លាំងពលកម្ម ដូច្នេះកុមារ យិន ទៅរៀនបាន តែមួយឆ្នាំប៉ុណ្ណោះ ក៏ត្រូវត្រឡប់មកមើលគោវិញដដែល ។ ពេល ទំនេរពីមើលគោ កុមារ យិន ជួយដកស្ទូងនិងឆ្កៀតឡើងត្នោត ។

នៅពេលដែលលោកតា យិន មានវ័យជំទង់ គឺជាពេលដែល ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមរបស់ជប៉ុន ។ ជប៉ុន បានសង់វាលយន្តហោះចំនួនពីរនៅក្នុងខេត្តកំពង់ឆ្នាំងមួយមាន ទីតាំងនៅទីរួមខេត្ត និងមួយទៀតមានទីតាំងនៅស្ពានពោធិ ស្ថិត នៅក្នុងឃុំសេដ្ឋី ស្រុកកំពង់ត្រឡាច ។ ជប៉ុនកេណ្ឌប្រជាជនខ្មែរទាំង ស្រីទាំងប្រុស ចាប់ពីអាយុ១៧ឆ្នាំរហូតដល់អាយុ៤០ឆ្នាំ ឲ្យទៅ សាងសង់វាលយន្តហោះ ដោយឲ្យឈ្នួលពលកម្មក្នុងមួយថ្ងៃ ៧កាក់ ។ លោកតា យិន បានឲ្យដឹងថា ប្រាក់៧កាក់នេះគ្រប់ សម្រាប់តែទិញបាយម្ហូបបរិភោគមួយថ្ងៃៗប៉ុណ្ណោះ មិនមាន សល់ទេ បើអ្នកណាដែលរេចអង្ករប្រហុកត្រីងៀតពីផ្ទះទៅ ក៏សន្សំបានប្រាក់កាសខ្លះត្រឡប់មកផ្ទះវិញ ។ បើអ្នកណាមិនមាន រេចអង្ករនិងម្ហូបក្រៀមពីផ្ទះទៅទេ គឺគ្មានសេសសល់ប្រាក់កាស ឡើយ ។ ក្នុងរយៈពេលមួយសប្តាហ៍ជប៉ុនប្តូរកម្លាំងពលកម្មម្តង ដោយឲ្យអ្នកចាស់ត្រឡប់មកផ្ទះហើយយកអ្នកថ្មីទៅវិញ ។ កម្លាំងត្រូវផ្លាស់ប្តូរវិលចុះវិលឡើងជារៀងរាល់សប្តាហ៍ ។

ពេលដែលមានអាយុ១៧-១៨ឆ្នាំ លោកតា យិន ជាប់ កំណែនទៅធ្វើវាលវង់យន្តហោះនៅទីរួមខេត្តកំពង់ឆ្នាំងចំនួនពាដង ។ គាត់ត្រូវកេណ្ឌទាំងមនុស្សទាំងរទេះគោទៅដឹកថ្មពីភ្នំក្រាំងដីមាស យកទៅដាក់នៅវាលវង់យន្តហោះ ។ លុះចប់ពីវាលវង់យន្តហោះ នៅខេត្តកំពង់ឆ្នាំងប្រមាណ៣-៤ខែ គាត់ក៏ត្រូវជប៉ុនកេណ្ឌទៅ ធ្វើវាលវង់យន្តហោះនៅស្ពានពោធិទៀត ។ លោកតា យិន បានឲ្យដឹងថា ជប៉ុនកេណ្ឌអស់មនុស្សដែលពេញកម្លាំង ក្នុងភូមិ នៅសល់តែកូនក្មេងនិងមនុស្សចាស់តែប៉ុណ្ណោះ ម៉្លោះហើយគ្មាន សល់កម្លាំងធ្វើស្រែចម្ការ គ្មានអ្នកត្បាញរវៃឡើយ ។ ប្រជាជន ក្រសម្បៀកបំពាក់ខ្លាំងណាស់ អ្នកខ្លះស្លៀកខោអាវដែលរហែករ យ៉ៃបំណះរាប់សិប អ្នកខ្លះទៀតស្លៀកបាវក៏មាន ។ ស្រែក៏ មិនសូវឥតបានធ្វើព្រោះគ្មានកម្លាំងគ្រប់គ្រាន់ ។ លោកតា យិន ធ្វើការនៅវាលវង់យន្តហោះស្ពានពោធិបានប្រមាណ២ខែ ជប៉ុន បានដកអាណានិគមពីប្រទេសកម្ពុជា ហើយបារាំងក៏ដាក់នឹម អាណានិគមមកលើប្រទេសកម្ពុជាម្តងវិញ ។

លោកតា យិន បានឲ្យដឹងទៀតថា ក្រោមនឹមអាណានិគម របស់បារាំង បារាំងទារពន្ធលើដីធ្លីដែលប្រជាជនធ្វើស្រែចម្ការ និងទារពន្ធកាតទៀត ។ បុរសៗចាប់ពីអាយុ២០ឆ្នាំឡើងទៅត្រូវ បារាំងដាក់កម្រិតឲ្យកាន់កាត និងត្រូវបង់ប្រាក់ចំនួន៧រៀលក្នុង មួយឆ្នាំ ។ មនុស្សស្រីមិនត្រូវកំហិតឲ្យបង់ឡើយ ។ លោកតា យិន និយាយថា *«៧រៀលនេះមិនងាយរកបានបង់ទេ ព្រោះ កាលនោះក្រណាស់»* ។ នៅក្នុងគ្រួសាររបស់លោកតា យិន ត្រូវ បង់កាតតែឪពុកម្នាក់ប៉ុណ្ណោះ និងត្រូវបង់ពន្ធដីប្រមាណ៥ឬ៦ រៀលទៀតក្នុងមួយឆ្នាំ ។ ជំទប់ភូមិជាអ្នកមានតួនាទីប្រមូលប្រាក់

ពន្ធអំពីប្រជារាស្ត្រទាំងអស់នៅក្នុងភូមិ ។

បន្ទាប់ពីជប៉ុនបញ្ចប់អាណានិគមលើប្រទេសកម្ពុជា ព្រះមហាក្សត្របានត្រាស់បង្គាប់ឲ្យយុវជនចាប់ពីអាយុ១៩ដល់៣០ឆ្នាំនៅគ្រប់ភូមិឃុំទាំងអស់ ហាត់ជីវពលដើម្បីត្រៀមលក្ខណៈសម្បត្តិការពារភូមិឃុំ ។ ពេលនោះមានលេចចេញនូវកងកម្លាំងខ្មែរឥស្សរៈដែលជាចលនាតស៊ូនៅក្នុងព្រៃប្រឆាំងនឹងបារាំង ។ កងទ័ពឥស្សរៈបានលបឆ្មក់ចូលក្នុងភូមិហើយឃោសនាអូសទាញប្រជាជនឲ្យចូលរួមជាមួយខ្លួន ។ លុះដល់ឆ្នាំ១៩៥៤ ទើបប្រទេសកម្ពុជាបានទទួលឯករាជ្យទាំងស្រុងពីអាណានិគមនិយមបារាំង និងបានទទួលសុខសន្តិភាពរហូតមក ។

លោកតា យិន រៀបការនៅអាយុ១៩ឆ្នាំ ។ ភរិយារបស់គាត់ជាអ្នកស្រុកភូមិជាមួយគ្នា ឈ្មោះ អ៊ុក អូន និងមានកូន៦នាក់ដែលនៅរស់ទាំងអស់រហូតមកដល់បច្ចុប្បន្ននេះ ។

នៅឆ្នាំ១៩៧២ ស្រុកកំពង់ត្រឡាចបានធ្លាក់ទៅក្រោមចម្បាំងដ៏ក្តៅគគុករវាងលន់ណុលនិងខ្មែរក្រហម ។ ប្រជាជនភិតភ័យរត់ចោលផ្ទះសម្បែងភូមិករទៅរស់នៅប្រមូលផ្តុំក្នុងបន្ទាយលង្វែកក្រោមការការពាររបស់ទាហានលន់ណុល ។ ផ្ទះរបស់លោកតា យិន និងផ្ទះរបស់ប្រជាជនជាច្រើននៅក្នុងភូមិ ត្រូវភ្លើងឆេះខ្ទេចខ្ទីអស់ ។ បន្ទាយលង្វែកដែលមានបណ្តោយប្រវែង៣គីឡូម៉ែត្រ និងទទឹងប្រវែងជាង១គីឡូម៉ែត្រមានប្រជាជនរាប់រយគ្រួសាររស់នៅកកកុញ ។ រដ្ឋាភិបាលលន់ណុល បានផ្តល់អង្ករឲ្យប្រជាជនដោយទម្លាក់តាមយន្តហោះ ប៉ុន្តែមានការខ្វះខាតម្ហូប ព្រោះប្រជាជនមិនអាចចេញទៅរកម្ហូបនៅក្រៅបន្ទាយបានឡើយខ្លាចជួបនឹងកងទ័ពខ្មែរក្រហម ។ ខ្មែរក្រហមនឹងសម្លាប់ប្រជាជនណាដែលខ្លួនបានជួប ដូច្នេះប្រជាជនភ័យខ្លាចមិនហ៊ានចេញក្រៅឡើយ សុខចិត្តសំងំតែនៅក្នុងបរិវេណបន្ទាយតែប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅតែមានប្រជាជនស្លាប់ជារៀងរាល់ថ្ងៃដោយសារកងទ័ពខ្មែរក្រហមលបឆ្មក់បាញ់សម្លាប់ឬ ផ្លោងកាំភ្លើងធំពីចម្ងាយ ។ នៅបន្ទាយលង្វែកអស់រយៈពេលជាច្រើនខែ ដោយឃើញប្រជាជនស្លាប់ច្រើនពេក ទាហានលន់ណុលក៏យកម៉ារីនមកដឹកប្រជាជនទៅដាក់នៅទីរួមខេត្តកំពង់ឆ្នាំងវិញ ។

បន្ទាប់ពីខ្មែរក្រហមបានទទួលជ័យជំនះទូទាំងប្រទេស លោកតា យិន និងក្រុមគ្រួសារ ព្រមទាំងប្រជាជនដែលភៀសខ្លួនមិនអាចត្រឡប់មកភូមិកំណើតវិញបានឡើយ ។ ខ្មែរក្រហមបានបញ្ជូនទៅរស់នៅក្នុងឃុំត្រាវពន្លក ស្រុកទឹកផុស គឺជាតំបន់ព្រៃភ្នំដែលមានជំងឺគ្រុនចាញ់យ៉ាងកាចសាហាវ ។ នៅទីនោះប្រជាជនជាច្រើនបានស្លាប់ដោយជំងឺគ្រុនចាញ់និងគ្មានអាហារបរិភោគ ។ លោកតា យិន រស់នៅក្នុងសហករណ៍ស្វាយរពាក់ ត្រូវបានប្រធានសហករណ៍ចាត់ឲ្យមើលក្របីមួយហ្វូងដែលមានចំនួនជាង១០០ក្បាល ជាមួយនឹងបុរសចំណាស់ម្នាក់ទៀតនិងក្មេងជំទង់ប្រមាណ៣ឬ៤នាក់ ។

រៀងរាល់កន្លះខែឬមួយខែម្តង លោកតាត្រូវទៅប្រជុំនៅទីស្នាក់ការឃុំជាមួយនឹងអ្នកឃ្វាលគោក្របីនៃសហករណ៍ផ្សេងៗទៀត ដើម្បីរាយការណ៍ជូនគណៈឃុំអំពីសភាពការណ៍ក្របីនៅក្នុងហ្វូង ។ លោកតាត្រូវរាយការណ៍ថាតើក្របីកើតកូនបានប៉ុន្មាន បាត់ប៉ុន្មាន ខាងសហករណ៍និងកងចល័តស្នើយកទៅប្រើនិងធ្វើម្ហូបអស់ប៉ុន្មាន ។ គាត់មិនដែលប្រជុំរួមជាមួយនឹងប្រជាជននៅក្នុងសហករណ៍ឡើយ ។ ពេលយប់គាត់មិនហ៊ានត្រឡប់ទៅសម្រាកនៅផ្ទះទេ ត្រូវសម្រាកយាមនៅក្រោលក្របី ខ្លាចក្រែងក្របីធ្លាយក្រោលទៅស៊ីស្រូវស៊ីដំណាំរបស់សហករណ៍ នាំឲ្យមានទោសពៃរ៍ថែមទៀត ។ ក្នុងមួយថ្ងៃ លោកតា យិន បានទទួលរបបអាហារពីរពេល មួយពេលបានបបរកវមួយចាន ជួនកាលបានអង្ករមួយកំប៉ុងសម្រាប់៣ឬ៤នាក់ ។ ប្រជាជនទូទៅក៏ដូចគ្នាដែរ ប៉ុន្តែប្រជាជនអាចហូបផលដំណាំដែលដាំជុំវិញផ្ទះរបស់ខ្លួន ។ ដោយឡែកក្រុមឃ្វាលក្របីអាចរកបេះផ្លែឈើព្រៃ ដូចជា ផ្សៀវ ក្តួបាត ព្រីង ជាដើម ហូបបន្ថែមទៀត ។ ប្រជាជនបានហូបឆ្អែតបរិបូរតាមចិត្តចង់តែនៅពេលមានបុណ្យជាតិធំៗតែប៉ុណ្ណោះ (ឧទាហរណ៍ បុណ្យខួបជ័យជំនះរបស់បក្សកុម្មុយនិស្តកម្ពុជា) ប៉ុន្តែលោកតា យិន និយាយថា ឲ្យតែមានបុណ្យធំៗដែលមានម្ហូបអាហារបរិបូរតែងតែមានប្រជាជនស្លាប់ច្រើនដែរ ដោយសារតែអ្នកទាំងនោះហូបច្រើនជ្រុល ។

ប្រពន្ធរបស់គាត់ត្រូវបានអង្គការចាត់តាំងឲ្យនៅក្នុងកងស្ទូងដោយទៅធ្វើការបាត់ៗមួយអាទិត្យឬកន្លះខែទើបបានមកលេង

ផ្ទះម្តង ។ កូនធំៗចូលក្នុងកងចល័ត ទៅលើកទំនប់ជីកប្រឡាយ ឆ្ងាយៗពីភូមិ ចំណែកកូនតូចបង្អស់ស្ថិតនៅក្រោមការថែទាំរបស់ យាយចាស់ៗទាំងថ្ងៃទាំងយប់ ។ ប្រហែលកន្លះខែម្តង កូនៗរបស់ តាយិន បានច្បាប់មកលេងផ្ទះ ប៉ុន្តែមិនបានយូរទេ តែមួយយប់ ប៉ុណ្ណោះត្រូវត្រឡប់ទៅកងវិញហើយ បើចង់នៅមួយថ្ងៃឬពីរថ្ងៃ ត្រូវតែសុំអនុញ្ញាតពីប្រធានភូមិជាមុន និងសុំរបបអាហារពីចុងភៅ បើមិនដូច្នោះទេពិតជាគ្មានរបបអាហារឡើយ ។

លោកតា យិន បាននិយាយថា ពេលមួយនោះ (ប្រហែល នៅអំឡុងពាក់កណ្តាលនៃរបបខ្មែរក្រហម) នៅពេលដែលគាត់ កំពុងតែឃ្វាលក្របីនៅជើងភ្នំ គាត់ឃើញខ្មែរក្រហមដឹកមនុស្ស ចំនួន៥ឡានយកទៅសម្លាប់ ក្នុងមួយឡានមានប្រមាណ៣០ នាក់ ។ គាត់រំឭកព្រឹត្តិការណ៍នាពេលនោះថា *“ពេលនោះវាសួរខ្ញុំថា ញោមធ្វើអីនៅកន្លែងហ្នឹង? ខ្ញុំថា បាទ! ឃ្វាលក្របី ។ បើឃ្វាលក្របី ញោមឯងថយពីត្រង់ហ្នឹងបន្តិចទៅ កន្លែងខ្ញុំធ្វើការ ។ ខ្ញុំថយទៅ ប្រហែល១០០ម៉ែត្រ ឡើងលើដើមត្បែងលបមើល ។ វាប្រើ មែកដ្ចឹកវ៉ៃកញ្ចឹងក វ៉ៃក្បាល ហើយប្រមៀលបោះទៅក្នុងរណ្តៅ ។ ដល់វ៉ៃរួចហើយ ឈើវាកាប់ស្រេចៗ ប្រមៀលសង្កត់ ។ មនុស្ស យើងត្រូវមួយដំបងពីរដំបងមានទាន់ងាប់ឯណា អ្នកណាងាប់ក៏ ងាប់ទៅ អ្នកណាមិនទាន់ងាប់ក៏នៅ ម៉្លោះហើយវាយកឈើប៉ុនៗ នេះយកទៅសន្ទប់ទៅ ។”* ទីកន្លែងដែលលោកតា យិន ឃើញការ សម្លាប់មនុស្សឈ្មោះ អូររលុង ស្ថិតនៅក្នុងឃុំត្រាវពន្លក ស្រុក ទឹកផុស ខេត្តកំពង់ឆ្នាំង ។

លោកតាបានឲ្យដឹងថា ប្រជាជនដែលទៅពីខដុគ្គនិងលង្វែក ត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់ ។ គ្រួសារណាដែលមាន កូនប្រុបងប្អូនជាអតីតទាហានរបបលន់ណុល ត្រូវខ្មែរក្រហម យកទៅសម្លាប់មួយពូជតែម្តង ។ សូម្បីតែអ្នកដែលលួចបេះ បោចដំណាំរបស់សមូហភាពក៏មានទោសប្រហារជីវិតដែរ ។ ជនរងគ្រោះខ្លះត្រូវខ្មែរក្រហមវាយទម្លាក់ក្នុងរណ្តៅរួម ខ្លះវាយ ទម្លាក់ជ្រោះ ខ្លះទៀតសម្លាប់ចោលនៅកណ្តាលវាលតែម្តង ។ ក្រៅពីត្រូវខ្មែរក្រហមសម្លាប់ ប្រជាជនជាច្រើនត្រូវស្លាប់ដោយ ជំងឺគ្រុនចាញ់និងអត់អាហារទៀត ។ ក្លិនស្អុយអសោចនៃសាកសព ជះសាយភាយគ្រប់ទីកន្លែងទាំងអស់ ។ នៅពេលដែលឃើញ មនុស្សស្លាប់ច្រើនដូច្នេះ លោកតា យិន រន្ធត់ចិត្តខ្លាំងណាស់ ។ គាត់និយាយថា “ដល់ទៅមែនទែនទៅខ្ញុំរន្ធត់ រន្ធត់នឹងស្អុយ រន្ធត់នឹងឃើញដឹកមនុស្សទាំងឡានៗទៅវ៉ៃ” ។

ពេលដែលកងទ័ពវៀតណាមវាយលុកចូលប្រទេសកម្ពុជា ខ្មែរក្រហមបានកៀរប្រជាជនឲ្យធ្វើដំណើរយ៉ាងលំបាកវេទនា ឡើងទៅតំបន់ភ្នំលើៗកាន់តែឆ្ងាយទៅៗ ។ ទៅដល់វត្តដំបូលប្រាំ នៅក្នុងឃុំតាប៉ាក ខេត្តកំពង់ស្ពឺ ប្រជាជននៅក្នុងក្រុមរបស់ លោកតាបានមូលមតិគ្នាថាលែងទៅមុខតាមបញ្ជារបស់ខ្មែរ ក្រហមទៀត ។ ប្រជាជននាំគ្នាកាន់កាំបិតពូថៅចាំកាប់កងទ័ព ខ្មែរក្រហមដែលមកបង្ខំឲ្យខ្លួនធ្វើដំណើរទៅមុខ ។ ប្រជាជនរង់ចាំ នៅទីនោះរហូតដល់កងទ័ពវៀតណាមទៅដល់ ហើយក៏ធ្វើដំណើរ ត្រឡប់មកភូមិស្រុកកំណើតវិញ ។

មកដល់ភូមិកំណើត ជីវភាពគ្រួសាររបស់លោកតាមាន សភាពត្រដាបត្រដួសខ្លាំងណាស់ ។ លោកតាបានយកមាសដែល ខំលាក់ទុកតាំងពីយូរមកហើយ ទៅដូរស្រូវអង្ករយកមកចិញ្ចឹមកូន និងខិតខំធ្វើស្រែចម្ការទម្រាំតែមានជីវភាពសម្បូរសប្បាយ ដូចសព្វថ្ងៃ ។ បច្ចុប្បន្ន តាមានដីស្រែវស្សាមួយហិកតា ដីស្រែ ប្រាំងពីរហិកតា និងមានផ្ទះក្បឿងធំមួយដែលតានិងយាយ រស់នៅជាមួយកូនប្រុសពៅដែលមានប្រពន្ធនិងមានកូន២នាក់ ។

លោកតា យិន មិនចង់រំឭករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ឡើងវិញទេ ព្រោះតាមិនចង់នឹកឃើញការឈឺចាប់នាពេលនោះ ។ តាលើកដៃបួងសួងកុំឲ្យរបបខ្មែរក្រហមកើតម្តងទៀត ខ្លាចក្រែង កូនចៅរបស់តាជួបប្រទះនឹងការលំបាកវេទនាដូចដែលតាធ្លាប់ បានជួប ។ តានិយាយថា *“របបខ្មែរក្រហមអត់ស្រួលទេក្មួយអើយ រហេមរហាមណាស់ ស៊ីក៏មិនបានឆ្អែត ដេកក៏មិនបានស្រួល ។ ខ្ញុំ មិនចង់នឹកវាទៀតទេ ពិបាកណាស់ បើរបបហ្នឹងកើតទៀតលំបាក ហើយ លំបាកកូនចៅណា៎ ។ របបសព្វថ្ងៃហ្នឹង វាស្រួលអស់យ៉ាង ស្រួលហើយ គ្មានរបបណាមកទារពន្ធទារកាតអីទៀតទេ យើងធ្វើ ស្រែបានប៉ុន្មានធ្វើទៅ យើងរកបានប៉ុន្មានហូបប៉ុណ្ណឹងទៅ ។ ខ្ញុំផ្តាំ កូនផ្តាំចៅថាបើរបបណាសុខសប្បាយ យើងយកតែរបបហ្នឹងទៅ កុំទៅស្រវារបបណាផ្សេងក្រែងកើតចម្បាំងរាំងដល់ទៀត ។”*

**សាន់ កល្យាណ**

# កាន់កន្ត្រៃមានសុភមង្គលជាងកាន់កាំភ្លើង

ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៣ៈ សេន យេន មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលកម្ពុជាបង្ហាញឯកសារប្រវត្តិរូបរបស់គាត់ ដែលគាត់បានធ្វើតាំងពីរបបខ្មែរក្រហម ។ គាត់មិននឹកស្មានសោះថាឯកសារនោះនៅសេសសល់មកដល់បច្ចុប្បន្ន ។ សេន យេន បច្ចុប្បន្នអាយុ៤៨ឆ្នាំ មានទីលំនៅនៅស្រុកកងមាស ខេត្តកំពង់ចាម ជាអតីតកងទ័ពខ្មែរក្រហមដែលធ្លាប់បានឆ្លងកាត់ការប្រយុទ្ធជាច្រើនសមរភូមិ ។ បច្ចុប្បន្ន សេន យេន ពិការជើងម្ខាង ប្រកបរបរកាត់សក់ដើម្បីចិញ្ចឹមប្រពន្ធនិងកូនប្រាំនាក់ ។

សេន យេន រៀនបានត្រឹមតែថ្នាក់ទី៩ចាស់ (ស្មើនឹងថ្នាក់ទី៤បច្ចុប្បន្ន) នៅសាលារការអារ ។ នៅឆ្នាំ១៩៧០ សេន យេន បានឈប់រៀនដើម្បីមកជួយមើលគោនិងឡើងត្នោតជាមួយឪពុកម្តាយ ។ ចុងឆ្នាំ១៩៧២ ដោយមានការអូសទាញពីមិត្តភក្តិ និងដោយសារសន្ទុះចិត្តពុះកញ្ជ្រោល យេន បានស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហមជាមួយមិត្តភក្តិរបស់គាត់ ដោយស្ពាយកាំភ្លើងអូសដីនៅឡើយ ។ គាត់លួចរត់ចោលបំពង់ទឹកត្នោតដែលកំពុងឡើង ទៅបម្រើកងទ័ពដោយគ្មានការអនុញ្ញាតពីឪពុកម្តាយ ។

លើកដំបូងដែល យេន ចូលបម្រើកងទ័ពខ្មែរក្រហម គាត់ត្រូវបានចាត់តាំងទៅក្នុងកងទ័ពតំបន់នៅខាងភូមិភាគឧត្តរ មានភារកិច្ចដើរល្បាតតាមភូមិ ដោយពុំបានទទួលការបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រអ្វីទាំងអស់ ។ ពីរឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៤ យេន ត្រូវអង្គការបញ្ជូនទៅប្រយុទ្ធនៅសមរភូមិចំការសាមសិប ក្នុងខេត្តកំពង់ចាម ។ ចុងឆ្នាំ១៩៧៤ យេន ត្រូវបានដកមកទ័ពចល័តដែលបោះទីតាំងនៅព្រៃកក្តាម ។ នៅព្រៃកក្តាមបានមួយរយៈ យេន ត្រូវអង្គការបញ្ជូនមកភូមិស្តើងជ័យ ឃុំស្តើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដើម្បីហាត់រៀនបច្ចេកទេសប្រយុទ្ធរយៈពេលមួយខែ បន្ទាប់មកចូលបម្រើការងារនៅក្នុងកងពិសេសនៃវរសេនាធំលេខ៥០២ កងពលតូចលេខ៨០៨ មេបញ្ជាការឈ្មោះ ម៉ាច ហើយអង្គការបានដកគាត់ទៅវាយនៅត្រពាំងជ្រៃ នៅភ្នំប្រសិទ្ធិ ។ នៅពេលវាយចូលដល់ព្រែកព្នៅ យេន ត្រូវរបួសជើង ដេកពេទ្យអស់រយៈពេលបួនខែ ។ មុនដំបូង យេន ដេកនៅពេទ្យជើងឆ្នុក ហៅ ៣-៤ ក្រោយមកគាត់ត្រូវបញ្ជូនមកដេកពេទ្យចំការអណ្តូង ។ មួយថ្ងៃបន្ទាប់ពីខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ យេន បានដើរពីចំការអណ្តូងមកភ្នំពេញ ។

មកដល់ភ្នំពេញដំបូង ដោយហេតុមិនដែលស្គាល់ភ្នំពេញ យេន និងមិត្តភក្តិរបស់គាត់ បាននាំគ្នាដើរលេងដោយមិនទាន់ទៅរកអង្គភាពភ្លាមៗនៅឡើយទេ ។ ក្នុងពេលដើរលេងនោះ គាត់ឃើញតែប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុងធ្វើដំណើរយ៉ាងពពាក់ពពូនតាមដងផ្លូវ និងរូបភាពនៃអំពើកំណាចឃោរឃៅទាំងឡាយដែលកងទ័ពខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជន ។ ដើរលេងបានពីរថ្ងៃ ទើបគាត់រកឃើញអង្គភាពនៅក្បែរស្ពានជ្រោយចង្វារទល់មុខស្ថានទូតបារាំង ។ តួនាទីរបស់អង្គភាពពិសេសនៅពេលនោះគឺការពារសន្តិសុខ និងត្រៀមកម្លាំងចាំទទួលបញ្ជាពីអង្គការ ។

សេន យេន បានបន្តទៀតថា ក្នុងពេលកំពុងជម្លៀសប្រជាជន ខ្មែរក្រហមបានឃោសនាថា «ទាហានលន់ណុលចាប់ពីស័ក្តិបីឡើងទៅ ត្រឡប់មកជុំគ្នានៅភ្នំពេញដើម្បីអង្គការចាត់ចែងឲ្យធ្វើការវិញ» ។ ប្រមាណ១០ថ្ងៃក្រោយមក អ្នកដែលបានទៅចុះឈ្មោះទាំងប៉ុន្មាន ត្រូវខ្មែរក្រហមសម្លាប់ចោលទាំងពូជ សូម្បីតែកូនង៉ែតក៏មិនទុកដែរ ។ គាត់ប្រាប់ទៀតថា មានបុរសម្នាក់ជាកម្មករធាក់ស៊ីក្លូសោះ មកប្រាប់ថាជាទាហានស័ក្តិបីក្នុងរបប លន់ណុល ។ ដល់ពេលខ្មែរក្រហមយកទៅសម្លាប់ទើបប្រកែកថា គាត់ជាអ្នកធាក់ស៊ីក្លូ មិនមែនជាទាហានលន់ណុលទេ ប៉ុន្តែហួសពេលទៅហើយ ព្រោះខ្មែរក្រហមមិនព្រមដោះលែងគាត់ទេ ។

ពីដំបូង អង្គការស្នើឲ្យ សេន យេន និងយុទ្ធមិត្តរបស់គាត់ ទៅសម្លាប់អតីតទាហានទាំងនោះ ប៉ុន្តែគាត់បដិសេធ ។ ដូច្នេះអង្គការ ក៏បញ្ជាឲ្យជីករណ្តៅវិញ ។ យេន និយាយថា "គេឲ្យខ្ញុំជីករណ្តៅ ជម្រៅជាងបីម៉ែត្រនៅម្តុំអង់តែនទូរទស្សន៍ ដើម្បីឲ្យក្រុមអ្នក សម្លាប់វាយចូលរណ្តៅ ។ ខ្ញុំឃើញគេវាយមនុស្សនឹងឈើប្លូន ជ្រុង វាយចំកញ្ចឹងក អាខ្លះគ្មានស្លាប់ទេ ដីផងខ្លួនឡើងគិតតែដេរ ។ គ្មានបានប៉ុន្មានទេ គេកប់ទាំងរស់ហ្នឹង ។ សម្លាប់ចាប់ពីម៉ោងបី រសៀលរហូតដល់ម៉ោងបីជិតភ្លឺទើបបានសម្រាក" ។ រណ្តៅខ្លះ ដែលកប់រាក់ៗត្រូវឆ្កែកកាយទាំអូសទាញខ្មោចចេញមកក្រៅជះ ក្លិនស្អុយពេញតំបន់ទួលគោក ។ អង្គការបញ្ជាឲ្យក្រុមរបស់គាត់ ទៅទាញខ្មោចចូលរណ្តៅនិងលុបវិញឲ្យជិត ។ សេន យេន លាន់ មាត់ថា "ទៅលុបខ្មោចវិញលោកអើយ ខ្មោចវាស្អុយណាស់" ។

នៅក្នុងឆ្នាំ១៩៧៥ដដែលនេះ សេន យេន ត្រូវអង្គការដក ទៅយាមកំពង់ផែកំពង់សោម និងដឹកជញ្ជូនទំនិញដាក់កប៉ាល់ដើម្បី ដឹកទៅប្រទេសចិន ។ ទំនិញដែល យេន ជញ្ជូនមានដូចជាជ័រកៅស៊ូ ដែលដឹកមកពីចំការលើ ម្រេចដឹកមកពីស្រែអំបិល និងដូង ។ ទំនិញ ដែលដឹកមកពីប្រទេសចិនវិញគឺរថយន្ត ។ បន្ទាប់ពីធ្វើការនៅ កំពង់សោមបានប្រហែលប្រាំខែ អង្គភាពរបស់ យេន ត្រូវផ្ទេរ ឡើងមកធ្វើការនៅកប់ស្រូវខាងលិចទីក្រុងភ្នំពេញឲ្យធ្វើស្រែ លើកប្រព័ន្ធភ្លឺស្រែ និងឡើងត្នោត ។ ចុងឆ្នាំ១៩៧៥ អង្គការ ដកកងរបស់ យេន ទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។ ការងារមុនដំបូងនៅទីនោះគឺកាប់គល់ត្នោត ។ គាត់បានបញ្ជាក់ថា ធ្វើការនៅកំពង់ឆ្នាំងមានវិស្វករចិនជាអ្នកដឹកនាំធ្វើគ្រប់មុខព្រួញ ។

នៅឆ្នាំ១៩៧៦ មានលេចឮពត៌មានថាប្រធានភូមិភាគឧត្តរ ក្បត់ អង្គការក៏ចាប់ខ្លួនខ្សែដឹកនាំតាំងពីថ្នាក់លើរហូតដល់ថ្នាក់ ប្រធានកង ។ ចំណែកយុទ្ធជនដូចជា សេន យេន ក៏ជាប់ចោទថា មាននិន្នាការក្បត់ ត្រូវអង្គការបញ្ជូនមកកសាងខ្លួននៅភ្នំពេញ ឲ្យធ្វើបង្គីរ ធ្វើប៉ោត និងលើកទំនប់នៅបឹងប្រយាប ។ ដើមឆ្នាំ ១៩៧៨ ដោយឃើញកសាងខ្លួនបានល្អហើយ អង្គការក៏បញ្ជូន សេន យេន ទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងវិញ ។ លើកនេះក្រុមរបស់គាត់មានសមាជិក៣៦នាក់ មានតួនាទីសង់ ផ្ទះថ្ម ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិស្វករចិនដូចមុន ដដែល ។ សេន យេន បញ្ជាក់ពីការលំបាកក្នុងការងារថា "ការងារ នោះវាលំបាកក៏ដូចជាមិនលំបាកដែរពេលហ្នឹងចៀសមិនផុតទេ ត្រូវតែធ្វើហើយ ទាំងគេទាំងយើង បើយើងមិនធ្វើមានតែយក ទៅកម្ទេចចោល ។ តែខ្ញុំលប្រអូសក៏មិនបានដែរ" ។ អង្គការចែក របបអង្ករឲ្យយុទ្ធជនម្នាក់៧០០ក្រាម ចំណែកម្ហូបត្រូវរកដោយ ខ្លួនឯង ។

ក្នុងរយៈពេលពីរឬបីថ្ងៃម្តង អង្គការអនុញ្ញាតឲ្យក្រុមការងារ មើលភាពយន្ត ។ ខ្សែភាពយន្តនិយាយអំពីប្រទេសចិន ។ សេន យេន និយាយថា "រឿងគេហ្នឹងមានតែរឿងកម្មករ រឿងសហករណ៍ ដាំបាយ រោងបាយដូចយើង ។ យើងយកពីណោះមកអនុវត្តនៅ ស្រុកខ្មែរដូចតែគ្នា" ។

ចុងឆ្នាំ១៩៧៨ ពេលដែលវៀតណាមចាប់ផ្តើមវាយលុក ចូលប្រទេសកម្ពុជា វិស្វករចិនបាននាំគ្នាជិះឡានរត់ទៅតាមផ្លូវ ជាតិលេខ៥ ។ ចំណែកយុទ្ធជនដែលធ្វើការនៅព្រលានយន្តហោះ ត្រូវបានអង្គការបំពាក់អាវុធឲ្យតស៊ូទៀត ។ សេន យេន និង យុទ្ធមិត្តរបស់គាត់ប្រាំនាក់ តស៊ូនៅក្នុងព្រៃនៅខេត្តបាត់ដំបង យ៉ាងលំបាកវេទនា ដោយសារតែខ្វះខាតស្បៀង ។ គាត់ហូបតែ ដំឡូងឈើ និងលួចចាប់គោប្រជាជនធ្វើជាអាហារ ។

ដោយទ្រាំនឹងជីវភាពលំបាកវេទនានៅក្នុងព្រៃតទៅទៀត លែងបាន សេន យេន ក៏សម្រេចចិត្តវិលមករស់នៅក្នុងភូមិ កំណើតវិញនៅចុងឆ្នាំ១៩៧៩ កសាងគ្រួសារមួយ និងប្រកបមុខ របរឡើងត្នោតដដែល ។ សំណាងអាក្រក់ សេន យេន ធ្លាក់ពីលើ ដើមត្នោត បណ្តាលឲ្យពិការជើងម្ខាង ។ បន្ទាប់ពីធ្លាក់ខ្លួនពិការ សេន យេន ចាប់យកមុខរបរថ្មីមួយទៀតគឺជាងកាត់សក់ ។

ពីមុន សេន យេន ធ្លាប់គិតថា កាន់កាំភ្លើងបាញ់គ្នាគឺជាការ សប្បាយ ប៉ុន្តែក្រោយមកទើបគាត់ដឹងថាគាត់គិតខុស ព្រោះការ តស៊ូរបស់គាត់មិនបាននាំឲ្យខ្លួនគាត់និងប្រទេសជាតិបានសុខ សប្បាយទេ ផ្ទុយទៅវិញទទួលបានតែការលំបាកវេទនាតែ ប៉ុណ្ណោះ ។ ពេលនេះទើប សេន យេន ដឹងថា ជីវិតកាន់ក្រាសនិង កន្ត្រៃកាត់សក់ មានសុភមង្គលជាងជីវិតកាន់កាំភ្លើង ។

ព្រុំ ផល្លា

# ម៉េង សុខុម : កម្មាភិបាលពេទ្យខ្មែរក្រហម

ទីកដីស្រុកកោះធំមានចម្ងាយប្រមាណ៥០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ។ នៅមុនឆ្នាំ១៩៧៥ មានយុវនារីជាច្រើននាក់បានចូលបម្រើបដិវត្តខ្មែរក្រហម ។ ម៉េង សុខុម ក៏ជាយុវនារីម្នាក់ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។ ក្រោយឆ្នាំ១៩៧៩ សុខុម ត្រូវរងនូវការចោទប្រកាន់ពីសំណាក់រដ្ឋអំណាចមូលដ្ឋានថាជាកម្មាភិបាលពេទ្យខ្មែរក្រហម ។

ម៉េង សុខុម អាយុ១៨ឆ្នាំ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧២ ហើយត្រូវបានតែងតាំងជាប្រធានសិល្បៈ (គ្រូបង្រៀនកុមារ) ប្រចាំភូមិ ។ មូលហេតុដែលប្រធានភូមិចាត់តាំងឲ្យសុខុមធ្វើជាគ្រូបង្រៀន ដោយសារតែ សុខុម ធ្លាប់បានរៀនសូត្រដល់ថ្នាក់ទី១០កាលពីសង្គមចាស់ ។ ទីកន្លែងដែល សុខុម បង្រៀន គឺនៅក្រោមផ្ទះនិងក្នុងវត្ត ។ សិស្សរបស់គាត់មានចំនួន៤៦នាក់ មានស្រី មានប្រុស ។ ថ្នាក់របស់គាត់គឺថ្នាក់ដំបូង ។ ពេលណាសិស្សចេះប្រកបអក្សរបានច្រើនហើយ គាត់ក៏បញ្ជូនឲ្យទៅរៀនជាមួយគ្រូផ្សេងទៀត ។


ម៉េង សុខុម

មកដល់ឆ្នាំ១៩៧៥ ប្រធានភូមិបានសួរ សុខុម ថាតើចង់ចូលធ្វើពេទ្យទេ? គាត់ឆ្លើយថាចង់ ពីព្រោះគាត់យល់ឃើញថាចូលធ្វើពេទ្យដើម្បីជួយសង្គ្រោះប្រជាជននិងម្យ៉ាងទៀតដោយសារតែឆ្មបខ្មែរដែលមានវ័យចំណាស់បានដកខ្លួនអស់ទៅហើយ ។ សុខុម បានចូលរៀនវគ្គបណ្តុះបណ្តាលជំនាញពេទ្យរយៈពេល៨ថ្ងៃ ។ នៅក្នុងការរៀនសូត្រនេះមានរៀនទ្រឹស្តីនិងអនុវត្តន៍ផ្ទាល់ ។ បន្ទាប់ពីរៀនថ្នាក់បណ្តុះបណ្តាលរយៈពេល៨ថ្ងៃ សុខុម ចេញទៅបំពេញការងារនៅក្នុងមន្ទីរពេទ្យ ។ សុខុម អាចព្យាបាលជំងឺទូទៅ អាចធ្វើឆ្មបបង្កើតកូន

និងព្យាបាលយុទ្ធជន-យុទ្ធនារីដែលរងរបួសនៅក្នុងសមរភូមិប្រយុទ្ធ ។ អ្នកជំងឺណាដែលធ្ងន់ធ្ងរខ្លាំង សុខុម បញ្ជូនទៅពេទ្យស្រុកឬតំបន់ ព្រោះបើមានអ្នកជំងឺស្លាប់ក្រោមការថែទាំរបស់គាត់ គាត់នឹងត្រូវប្រធានកងយកទៅកសាងឬសម្លាប់ចោល ។ នៅពេលមួយ សុខុម ត្រូវវេនយាមអ្នកជំងឺពេលយប់ ។ ដោយអស់កម្លាំងពេក គាត់បានដេកលក់ក្នុងម៉ោងយាម ។ ប្រធានរបស់គាត់បានហៅគាត់ទៅកសាងហើយគំរាមថាបើនៅតែធ្វេសប្រហែសទៀតនឹងត្រូវបញ្ជូនទៅពោធិទន្លេមិនខាន ។

មន្ទីរឃុំឃាំងនៅពោធិទន្លេគឺជាផ្ទះឈើប្រក់ក្បឿងដ៏ធំមួយស្ថិតនៅក្នុងភូមិពោធិទន្លេ ឃុំកោះធំ “ក” ស្រុកកោះធំ ខេត្តកណ្តាល មានទីតាំងនៅទល់មុខភូមិដែល សុខុម រស់នៅ ។ សុខុម ប្រាប់ថា ពេលខ្លះគាត់ឮសំឡេងមេក្រូចាក់បទចម្រៀងយ៉ាងរំពងនៅពោធិទន្លេ ហើយពេលខ្លះទៀតគាត់ឮសូរសម្រែកឈឺចាប់របស់មនុស្ស ។ ប្រជាជនខ្លះបានលួចខ្សឹបប្រាប់ សុខុម ថា ពេលណាដែលឮសំលេងមេក្រូ គឺជាពេលវេលាដែលខ្មែរក្រហមសម្លាប់មនុស្សហើយ ។ អ្នកធ្វើការនៅក្នុងមន្ទីរពេទ្យជាមួយ សុខុម ឈ្មោះ គី ត្រូវប្រធានមន្ទីរពេទ្យបញ្ជូនទៅនៅសហករណ៍ថ្មីនៅពោធិទន្លេ ហើយមិនឃើញត្រឡប់មកវិញសោះ ។ សុខុម សន្និដ្ឋានថា គី ច្បាស់ជាត្រូវបញ្ជូនទៅសម្លាប់យ៉ាងពិតប្រាកដ ។ តាមរយៈឯកសារដែលតម្កល់ទុកនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា មានកត់ត្រាថា អ្នកទោសដែលស្លាប់នៅមន្ទីរឃុំឃាំងពោធិទន្លេមានចំនួនប្រមាណ បីម៉ឺននាក់ និងមានចំនួន ៥៥រណ្តៅ ។

ក្រោយពី សុខុម ចូលធ្វើពេទ្យបានមួយរយៈពេលខ្លី ប្រធានភូមិបម្រុងបញ្ជូនម្តាយរបស់គាត់ទៅធ្វើស្រែនៅទំនាបទន្លេមេគង្គ ។ សុខុម បានតវ៉ាថា ប្រសិនបើបញ្ជូនម្តាយគាត់ទៅធ្វើការនៅទន្លេមេគង្គ គាត់នឹងឈប់ធ្វើពេទ្យភ្លាម ។ សុខុម តវ៉ាជាច្រើនលើកច្រើនសារហូតដល់ប្រធានភូមិយល់ព្រមឲ្យម្តាយរបស់គាត់ធ្វើការនៅក្នុងភូមិដដែល ។

នៅឆ្នាំ១៩៧៧ ប្រធានមន្ទីរពេទ្យបានដាក់ទិសឲ្យគាត់រៀបការជាមួយ សម្បត្តិ ជាកម្មាភិបាលពេទ្យព្យាបាលកុមារនៅក្នុងស្រុកកោះធំ ។ សុខុម បានប្រកែកមិនព្រមរៀបការ ។ គាត់បានសម្រេចចិត្តរត់ទៅធ្វើកងទ័ពនៅសមរភូមិមុខដោយបានប្រាប់ឪពុកមាជីដូនមួយរបស់គាត់ឲ្យមកទទួលគាត់ចេញពីមន្ទីរពេទ្យឃុំផង ។ ប៉ុន្តែ ឪពុកមាជីដូនមួយរបស់ សុខុម ខកខានមិនបានមកតាមពេលវេលាដែលបានណាត់ទេ ដូច្នេះ សុខុម គ្មានផ្លូវណាគេចវេះក្រៅពីការរៀបការជាមួយ សម្បត្តិ ឡើយ ។ ពិធីរៀបការប្រព្រឹត្តទៅនៅរោងបាយសហករណ៍ ដោយមានការចូលរួមពីសំណាក់ប្រធានភូមិ ប្រធានសហករណ៍និងយុទ្ធជន-យុទ្ធនារីចំនួន ១៨គូ ប៉ុន្តែគ្មានវត្តមានឪពុកម្តាយផងទេ ។ ប្រធានសហករណ៍បានឲ្យ សុខុម និង សម្បត្តិ ឡើងប្តេជ្ញាព្រមទទួលយកគ្នាជាប្តីប្រពន្ធអស់មួយជីវិត ។

ក្រោយពី សុខុម រៀបការហើយ សមាជិក៨នាក់នៅក្នុងអង្គភាពរបស់គាត់បានចោទប្រកាន់គាត់ថាមានពាក់ព័ន្ធសីលធម៌បុរស-នារី ។ ពេលនោះ សុខុម ហៀបតែត្រូវប្រធានមន្ទីរពេទ្យបញ្ជូនទៅមន្ទីរឃុំឃាំងនៅពោធិទន្លេ ប៉ុន្តែគាត់តវ៉ាយ៉ាងខ្លាំងរហូតទាល់តែប្រធានមន្ទីរពេទ្យដោះលែងគាត់មកវិញ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំ សុខុម និង សម្បត្តិនៅតែរស់នៅជាមួយគ្នាជាប្តីប្រពន្ធនិងមានកូន៧នាក់ ។ អ្នកទាំងពីរបានប្រកបរបរធ្វើស្រែចម្ការនៅក្នុងស្រុកកោះធំ ខេត្តកណ្តាលដដែល ។ មួងម្កាល សុខុម បានយកវិជ្ជាពេទ្យដែលគាត់ចេះពីរបបខ្មែរក្រហម មកអនុវត្តព្យាបាលសមាជិកគ្រួសាររបស់គាត់និងជួយបង្កើតកូនឲ្យអ្នកជិតខាងដែរ ប៉ុន្តែគាត់មិនហ៊ានយកទៅប្រើធំដុំទេ ព្រោះខ្លាចមានគ្រោះថ្នាក់ ។

**ប៉ាង ពីច័ន**

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ះ៣០-៣ះ៤៥នាទី តាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**




អ្នកទោសមន្ទីរស-២១



«ប៊ូ ម៉េង ក្រោយពួកវាធ្វើទារុណកម្មយ៉ាងឃោរឃៅ បែកដំបៅពេញខ្លួន»
វិចិត្រករ : ប៊ូ ម៉េង (អតីតជនរងគ្រោះនៅមន្ទីរស-២១)

# ធ្វើផែនទីវាលពិឃាតៈ

## ប្រព័ន្ធកំណត់ភូមិសាស្ត្រតាមពត៌មានវិទ្យា

## ក្នុងការស្ដាបនាឡើងវិញនូវហាយនភាពជាប្រវត្តិសាស្ត្រនៅកម្ពុជា





វាលពិឃាតជើងឯកស្ថិតក្នុងសហគមន៍ប្រកបរបរកសិកម្ម មានចម្ងាយប្រមាណ១៥គីឡូម៉ែត្រភាគនិរតីរាជធានីភ្នំពេញ ព័ទ្ធជុំវិញវិហារចំណាស់មួយដែលមានរចនាប័ទ្មបែបចិន ។ ជើងឯកគឺជាបូជនីយដ្ឋានសម្រាប់អ្នកស្រុកអ្នកភូមិជាពុទ្ធបរិស័ទទៅគោរពបូជាទៅតាមប្រពៃណីព្រះពុទ្ធសាសនាអស់ជាច្រើនជំនាន់មកហើយ ។ ទីនោះមើលទៅមិនសមជាកន្លែងដែលខ្មែរក្រហមប្រព្រឹត្តឧក្រិដ្ឋកម្មដ៏យង់ឃ្នងនៅក្នុងប្រវត្តិសាស្ត្រទំនើបសោះ ប៉ុន្តែបដិវត្តន៍ខ្មែរក្រហមបានប្រែក្លាយទឹកដីជើងឯកដែលជាបូជនីយដ្ឋានឲ្យទៅជា «វាលពិឃាត» ធំជាងគេបង្អស់នៅក្នុងប្រទេសកម្ពុជា ។ នៅចន្លោះឆ្នាំ១៩៧៧-១៩៧៩ «ខ្មាំង»របស់បក្សកុម្មុយនិស្តកម្ពុជា ចំនួនជាង១៦០០០នាក់ ត្រូវបាននាំពីគុកទួលស្លែងមកសម្លាប់នៅទីនេះបន្ទាប់ពីធ្វើទារុណកម្មនិងសួរចម្លើយរួច ។ ខ្មែរក្រហមដឹកអ្នកទោសទាំងឡានៗមកជើងឯកជារៀងរាល់ថ្ងៃ បន្ទាប់មកច្រានទម្លាក់មកដី ហើយបណ្តើរទាំងខ្សែៗឲ្យលុតជង្គង់ចុះនៅមាត់រណ្តៅរង់ចាំព្រនង់ភ្លៅរទេះផ្តាច់ជីវិត ។ ក្រោយពីសម្លាប់រួចហើយ អ្នកទោសត្រូវរុញទម្លាក់ចូលទៅក្នុងរណ្តៅកប់ចោលតែម្តង ។ មិនយូរប៉ុន្មាន សាកសពរាប់ពាន់ដែលកប់មិនបានត្រឹមត្រូវបានបង្ហើរក្លិនអសោចសាយភាយពាសពេញទីនោះ ។

ជើងឯកមានលក្ខណៈមិនខុសគ្នាអំពីវាលកប់ខ្មោចរាប់ពាន់រណ្តៅដែលនៅរាយប៉ាយពាសពេញជនបទនៃប្រទេសកម្ពុជានោះទេ ។ ក្នុងរយៈពេលមិនដល់បួនឆ្នាំផង ប្រជាជនប្រមាណពីរលាននាក់បានស្លាប់បាត់បង់ជីវិតដោយរបបខ្មែរក្រហម គឺស្មើនឹង១ភាគ៤នៃប្រជាជនកម្ពុជាទាំងអស់ ។ ប្រវត្តិវិទូនិងសាធារណជនទូទៅយល់ស្របគ្នាថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានការកាប់សម្លាប់មនុស្សជាទ្រង់ទ្រាយធំ ដោយគ្មានការជំនុំជម្រះក្តីតាមផ្លូវច្បាប់ឡើយ ។ ផ្អែកតាមការរៀបរាប់របស់សាក្សីដ៏ច្រើនអនេក និងភ័ស្តុតាងរូបវិន្តដ៏សន្ធឹកសន្ធាប់ បានធ្វើឲ្យសេចក្តីសន្និដ្ឋាននេះមានទម្ងន់ខ្លាំងណាស់ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ប្រវត្តិវិទូនៅមានការខ្វែងគំនិតគ្នាអំពីវិធីបកស្រាយទៅលើការធ្វើទុក្ខទោសនានា ដែលកើតឡើងក្នុងរបបប៉ុលពត ។ ប្រវត្តិវិទូខ្លះអះអាងថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជារៀបចំនិងធ្វើមជ្ឈការអំណាចទៅលើផែនការប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងគោលបំណងឈានទៅសម្រេចឲ្យបាននូវបរិសុទ្ធភាពនិងមនោគមវិជ្ជា ។ ចំណែកប្រវត្តិវិទូផ្សេងទៀតអះអាងថា ការធ្វើទុក្ខទោសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបណ្តាលមកពីភាពឥតរបៀបរៀបរយ តាមមូលដ្ឋាននិងការសងសឹក ជាជាងការវាយប្រហារដែលរៀបចំឡើងដោយអំណាចកណ្តាល ។ បញ្ញាជនក៏បានបញ្ជាក់ដែរអំពីលក្ខណៈផ្សេងៗគ្នានៃលក្ខខណ្ឌរស់នៅប្រចាំថ្ងៃរបស់ប្រជាជនពីតំបន់មួយទៅតំបន់មួយ ។

ការពិភាក្សាតទល់គ្នានេះមានសារសំខាន់ទាំងខាងលក្ខណៈប្រវត្តិសាស្ត្រនិងលក្ខណៈច្បាប់ ។ ដើម្បីស្វែងយល់អំពីថាតើហាយនភាពនៅកម្ពុជាកើតឡើងដោយរបៀបណា ដើម្បីទប់ស្កាត់មិនឲ្យមានការធ្វើទុក្ខទោសនៅថ្ងៃអនាគត និងដើម្បីកំណត់ការទទួលខុសត្រូវតាមផ្លូវច្បាប់ សំខាន់គឺត្រូវយល់ដឹងអំពីតួនាទីនានារបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា និងកម្មាភិបាលខ្មែរក្រហមនៅតាមមូលដ្ឋាន នៅក្នុងការប្រព្រឹត្តអំពើឃោរឃៅនៅក្នុងតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ។ ទោះបីជាមានប្រភពភស្តុតាងជាច្រើនសម្រាប់ប្រវត្តិវិទូនិងអ្នកច្បាប់ក៏ដោយ ប៉ុន្តែវគ្គនេះផ្តោតសំខាន់ទៅលើវិធីនានាដែលប្រព័ន្ធព័ត៌មានវិទ្យាកំណត់ទីតាំងភូមិសាស្ត្រ រួមទាំងបច្ចេកវិទ្យាកំណត់កូអរដោនេភូមិសាស្ត្រផង អាចចូលរួមផ្តល់នូវការស្វែងយល់កម្រិតខ្ពស់ថែមទៀតអំពីរបបខ្មែរក្រហម ។ ជាបឋម យើងរៀបរាប់អំពីទិដ្ឋភាពទូទៅនិងការធ្វើទុក្ខទោសរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ទីពីរ គឺយើងពិពណ៌នាអំពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រើបច្ចេកវិទ្យាក្នុងការផលិតចេញជាផែនទី«វាលពិឃាត» រួមទាំងគុកនិងបូជនីយដ្ឋានប្រល័យពូជសាសន៍ដែលកសាងឡើងដោយជនរងគ្រោះដែលមានវាសនារស់រានមានជីវិតចាកផុតពីរបបប៉ុលពត ។ ទីបី គឺយើងបន្តសង្កត់ធ្ងន់ទៅលើសារសំខាន់នៃព័ត៌មានដែលបានមកពីប្រព័ន្ធព័ត៌មានវិទ្យា *GIS* ក្នុងការស្ថាបនាឡើងវិញនូវប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ និងការកំណត់ការទទួលខុសត្រូវជាលក្ខណៈគតិយុត្តិរបស់មេដឹកនាំនៃរបបខ្មែរក្រហម ។

## សម័យភេរវកម្មនៅកម្ពុជាឆ្នាំ១៩៧៥-១៩៧៩

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម បានចូលកាន់កាន់ទីក្រុងភ្នំពេញ ប្រកាសជ័យជម្នះបដិវត្តន៍និង បញ្ចប់សង្គ្រាមស៊ីវិលដែលអូសបន្លាយអស់រយៈពេល៥ឆ្នាំ ។ ស្ថិតក្នុងសម្លៀកបំពាក់ខោអាវពណ៌ខ្មៅ បង់កក្រមាក្រឡាស-ខ្មៅ ជាលក្ខណៈប្រជាកសិករ កងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្លាមក៏ ទទួលបាននូវការស្វាគមន៍ដោយសម្រែកជយឃោសយ៉ាងកងរំពង ពីប្រជាជនដែលជិនណាយនឹងសង្គ្រាម ។ ប៉ុន្មានម៉ោងក្រោយមក អ្នកស្រែកអបអរបែរជាស្ងាត់មាត់ឈឹងនៅពេលដែលខ្មែរក្រហម ចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុង និងបង្ខំឲ្យប្រជាជន ទីក្រុងប្រមាណពីរលាននាក់ឲ្យចេញដំណើរទៅកាន់កន្លែងដែល មិនស្គាល់និងគ្មានទិសដៅច្បាស់លាស់ នៅតាមជនបទចុងកាត់ មាត់ញក ដោយវេចរបស់របរផ្សេងៗជាបង្វេចដែលអាចយក តាមខ្លួនបានតែប៉ុណ្ណោះ ។ នៅពេលប្រជាជនទាំងហ្វូងៗសម្រុក ចាកចេញពីទីក្រុង កម្មាភិបាលបដិវត្តបានបង្កើតប៉ុស្តិ៍ត្រួតពិនិត្យ ជាច្រើននៅតាមមាត់ច្រកចេញចូលរបស់ទីក្រុង ។ អ្នកមានបណ្តា សក្តិធំៗនិងទាហាននៃរបបសាធារណរដ្ឋដឹកនាំដោយ លន់ ណុល ដែលត្រូវបណ្តេញចេញពីអំណាច ត្រូវបានចាប់ខ្លួន ខ្លះនាំទៅ កន្លែងដែលមិនឲ្យដឹងមុន ហើយអ្នកខ្លះទៀតត្រូវយកទៅសម្លាប់ ចោលដោយគ្មានការជម្រះក្តី ។

ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញគឺជាជំហានទីមួយ នៅក្នុងកម្មវិធី "ឆ្នាំសូន្យ" ដោយលុបបំបាត់នូវប្រវត្តិសាស្ត្រ និងឥទ្ធិពលបរទេសទាំងអស់ដែលកងទ័ពរ៉ាឌីកាល់ទាំងនេះចោទថា បានដាក់ទណ្ឌកម្មមកលើប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា ។ "ការ បោសសម្អាត"របស់កម្ពុជាប្រជាធិបតេយ្យមានន័យថា កម្ចាត់ ឲ្យអស់នូវរាល់ស្លាកស្នាមបន្សល់ទុកពីរបបមុន កម្ទេចវណ្ណៈសក្តិភូមិ ម្ចាស់ដី ជំនួសវិញដោយសង្គមបរិសុទ្ធបែបម៉ៅនិយម រស់នៅ ស្មើៗគ្នាគ្មានអ្នកមានគ្មានអ្នកក្រ ។ ដោយសម្រេចឲ្យបាននូវ នយោបាយ "មហាលោតផ្លោះមហាអស្ចារ្យ" ខ្មែរក្រហមបាន សន្យាធ្វើឲ្យប្រទេសកម្ពុជាមានលក្ខណៈខ្លួនទីពឹងខ្លួន និងឯករាជ្យ ម្ចាស់ការ ជៀសផុតពីអំពើអយុត្តិធម៌ក្នុងសង្គម និងការជិះជាន់ របស់បរទេស ។ ក្រុមមេដឹកនាំដែលមិនដែលចេញមុខដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ម៉ុក, និង ខៀវ សំផន បានដឹកនាំ របបថ្មីមួយជាសម្ងាត់ ដោយដាក់ឈ្មោះខ្លួនឯងថា "អង្គការ" ។

ក្នុងគោលដៅលុបបំបាត់រចនាសម្ព័ន្ធសង្គមនិងរបៀប របបរស់នៅតាមលក្ខណៈប្រពៃណី ខ្មែរក្រហមបានពង្រាយ ប្រជាជនតាមភូមិឃុំតាមជនបទចុងកាត់មាត់ញក ឲ្យប្រកបរបរ កសិកម្មក្នុងលក្ខណៈតឹងរ៉ឹងបំផុត ។ នៅទីជនបទ ទាំងប្រជាជនចាស់ ទាំងប្រជាជនថ្មី ត្រូវឆ្លងកាត់នូវកម្មវិធីអប់រំដ៏តឹងតែងដែល រៀបចំឡើងដើម្បីកែចិត្តកែគំនិតឲ្យស្អាតស្អំ ដែលអង្គការចាត់ទុក ថាជាការនាំដល់ការបញ្ចូលមនោគមវិជ្ជា ។ បញ្ញវន្ត ជនជាតិ ភាគតិច ព្រះសង្ឃ និងបុគ្គលផ្សេងៗទៀតដែលត្រូវបានចាត់ទុក ជាខ្មាំងរបស់បដិវត្តន៍ បានស្ថិតនៅក្រោមមុខសញ្ញានៃការធ្វើ ទុក្ខទោស ។ គ្រួសារជាច្រើនត្រូវបានបំបែកចេញពីគ្នាក្នុងគោល បំណងឲ្យមានភក្តីភាពស្មោះស្ម័គ្រជាមួយបដិវត្តន៍ ។ ចំណែកឯ សិទ្ធិជឿជំនឿសាសនាត្រូវបានកាត់ផ្តាច់ទាំងស្រុង ។ ក្រដាស ប្រាក់ត្រូវបានលុបបំបាត់ ហើយទំនាក់ទំនងជាមួយពិភពខាង ក្រៅត្រូវបញ្ឈប់ជាបណ្តោះអាសន្ន ។ កំហុសបន្តិចបន្តួចដូចជា លួចបាយហូបកុំឲ្យដាច់ពោះស្លាប់ ក៏ត្រូវទទួលទណ្ឌកម្មឃុំឃាំងឬ យកទៅសម្លាប់ដែរ ។ ក្នុងខណៈដែលអង្គការកំពុងប្រកាសតាម វិទ្យុក្រុងភ្នំពេញអំពីជ័យជម្នះរបស់ខ្លួន ប្រជាជនកម្ពុជានិងជន បរទេសដែលស្នាក់នៅក្នុងប្រទេសកម្ពុជាក៏កំពុងស្លាប់ក្នុងសន្ទុះ យ៉ាងលឿនដោយសារការសម្លាប់ស្រេចតែទំនើងចិត្ត ការបង្អត់ អាហារ និងកង្វះថ្នាំសង្កូវ ។

សូម្បីតែក្រុមសិល្បៈក៏មានវាសនាដូចគ្នា ។ ការភ័យខ្លាច មានការប្រឆាំងផ្ទុះឡើងពីផ្ទៃក្នុង ព្រមទាំងការជ្រៀតចូលរបស់ វៀតណាម សូវៀត និងអាមេរិកាំង ធ្វើឲ្យមានការបោសសម្អាត នៅក្នុងជួរបក្សថែមទៀត ។ គិតមកដល់ឆ្នាំ១៩៧៩ កម្មាភិបាល មួយចំនួនធំរបស់បក្ស ត្រូវបានចាប់ដាក់គុក ធ្វើទារុណកម្ម និងយកទៅសម្លាប់ចោល ។ មនុស្សស្លាប់គរលើគ្នានៅក្នុងរណ្តៅ សាកសពរួមនៅដើងឯក ។ អ្នកខ្លះទៀតស្លាប់នៅក្នុងរណ្តៅនៅ តាមវាលពិឃាតផ្សេងៗទៀតពាសពេញប្រទេសកម្ពុជា ។

## ការធ្វើផែនទីអំពីការធ្វើទុក្ខទោសនៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ

ចាប់តាំងពីការចាប់បដិសន្ធិនៅឆ្នាំ១៩៩៥ មជ្ឈមណ្ឌល

ឯកសារកម្ពុជាបានខិតខំពុះពារយ៉ាងសកម្មក្នុងការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ។ តាមរយៈកិច្ចសម្ភាសន៍និងការរុករកជាក់ស្តែងនៅទូទាំងប្រទេស មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញរណ្តៅសាកសពរួមគ្នាចំនួន ១៩ ៤៧១ កន្លែង ។ វាលកប់ខ្មោចទាំងនេះភាគច្រើនផ្ទុក (ឬធ្លាប់ផ្ទុក) អដ្ឋិធាតុមនុស្សរាប់រយពាន់នាក់ ។ រណ្តៅសាកសពរួមស្ថិតនៅរាយប៉ាយក្នុងស្រុកចំនួន១៧០ទូទាំងប្រទេសកម្ពុជា ហើយចំនួននេះនឹងកើនឡើងច្រើនជាងនេះនៅពេលដែលតំបន់មួយចំនួនទៀតត្រូវបានក្រុមផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅស្រាវជ្រាវបន្ថែម ។ មិនតែប៉ុណ្ណោះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញអតីតមន្ទីរសន្តិសុខរបស់បក្សកុម្មុយនិស្តចំនួន១៨៥កន្លែង ។ ជាទូទៅ មន្ទីរសន្តិសុខទាំងនោះគឺជាគុកផងនិងជាកន្លែងសួរចម្លើយផង ។ មន្ទីរសន្តិសុខជាច្រើនក៏មានកន្លែងសួរចម្លើយដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជារកឃើញបូជនីយដ្ឋានចំនួន៧៧កន្លែងដែលស្ថាបនាឡើងដោយអ្នកមានវាសនារួចចាកផុតពីសេចក្តីស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឧទ្ទិសទៅដល់ជនទាំងឡាយដែលបានលាចាកលោកទៅ ។ ដូចគ្នានឹងរណ្តៅសាកសពរួមដែរ មន្ទីរសន្តិសុខរបស់បក្សកុម្មុយនិស្តកម្ពុជានិងបូជនីយដ្ឋានគឺមាននៅរាយប៉ាយពាសពេញប្រទេសកម្ពុជា ភាគច្រើននៅតំបន់ដែលមានប្រជាជនរស់នៅកកកុញ ដូចជាជុំវិញបឹងទន្លេសាបនិងផ្លូវទឹកសំខាន់ៗរបស់កម្ពុជា គឺទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ។

មានការងារជាច្រើនទៀតដែលក្រុមផែនទីត្រូវបង្ហើយដើម្បីធ្វើផែនទីវាលពិឃាតមួយដែលមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ ។ ខេត្តខ្លះដែលបានចុះស្រាវជ្រាវរួចហើយក៏នៅមានឃុំមួយចំនួនមិនទាន់ចុះទៅដល់ ។ មិនតែប៉ុណ្ណោះ ក្រុមផែនទីនៅមិនទាន់បានចុះទៅពិនិត្យដល់កន្លែងនានានៃខេត្តព្រះវិហារ ឧត្តរមានជ័យ និងសៀមរាប នៅឡើយទេ ។ នៅក្នុងឃុំជាច្រើនដែលមិនទាន់រុករកដល់ មានពត៌មានថាមានរណ្តៅសាកសពរួមនៅទីនោះ ។ ប៉ុន្តែទីតាំងដែលយើងមិនទាន់ទៅដល់ភាគច្រើនជាតំបន់ដាច់ស្រយាលចុងកាត់មាត់ញកដែលមិនអាចចូលទៅដល់ ។ នៅតំបន់ដែលមានដង់ស៊ីតេប្រជាជនរស់នៅតិចពិសេសនៅតំបន់ខ្ពង់រាបភាគឦសាននិងភាគនិរតីនៃប្រទេសកម្ពុជា មានការលំបាកមិនទាន់អាចទៅដល់ដោយសារបញ្ហាគ្រាប់មីន ព្រៃតំបន់ជំងឺគ្រុនចាញ់ និងមិនសូវមានផ្លូវធ្វើដំណើរ ។ តំបន់មួយចំនួនទៀតមានគ្រោះថ្នាក់ដោយសារចោរព្រៃនិងក្រុមអតីតទ័ពព្រៃខ្មែរក្រហមថែមទៀត ដែលជួនកាលពួកនេះអាចរារាំងដល់ការស្រាវជ្រាវលើប្រធានបទនេះ ។ ផ្លូវចុងក្រោយដែលក្រុមផែនទីត្រូវធ្វើដំណើរពិតជាពិបាកជាងគេបង្អស់ ។ ជាការពិតណាស់ តំបន់ដែលពិបាកចូលឲ្យដល់នេះគឺពិតជាមានរណ្តៅសាកសពរួម គុក និងបូជនីយដ្ឋាន បន្ថែមពីលើពត៌មានដែលយើងទទួលបានជាមិនខាន ។

នៅពេលរកឃើញទីតាំងទាំងនេះ យើងប្រើប្រាស់ម៉ាស៊ីនអេឡិចត្រូនិចកំណត់កូអរដោនេភូមិសាស្ត្រ (GPS) ដែលផលិតដោយភ្នាក់ងារធ្វើផែនទីការពារជាតិរបស់សហរដ្ឋអាមេរិកនៅឆ្នាំ ១៩៨៤ ។ ម៉ាស៊ីននេះកំណត់កូអរដោនេភូមិសាស្ត្រនៃតំបន់នោះរួចហើយបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យភូមិសាស្ត្រកម្ពុជា (CGEO) ដែលជាប្រព័ន្ធទិន្នន័យប្រើលេខរៀបរៀងឡើងតាមរយៈកម្មវិធី CDS/ISIS for Window ។ បន្ទាប់មកទិន្នន័យនេះបង្កើតចេញជាផែនទីបង្ហាញទីតាំងនានាដែលបានរកឃើញរួចហើយ ។ ដោយមានកម្មវិធី Arc View ប្រព័ន្ធទិន្នន័យភូមិសាស្ត្រកម្ពុជាអាចបង្ហាញជូននូវផែនទីប្រទេសកម្ពុជា ឬផែនទីខេត្តស្រុក ឬភូមិនានា ។ ផែនទីប្រទេសកម្ពុជានៅខាងដើមអត្ថបទនេះបង្ហាញអំពីទិដ្ឋភាពទូទៅនៃរបកគំហើញជាលក្ខណៈប្រវត្តិសាស្ត្រដូចជាគុកខ្មែរក្រហមនិងទីតាំងសម្លាប់មនុស្ស ។

កម្មវិធី Arc View អាចផលិតចេញជាផែនទីលម្អិតអំពីតំបន់នានានៅទូទាំងប្រទេស ព្រមទាំងអាចឲ្យអ្នកប្រើប្រាស់កម្មវិធីនេះបញ្ចូលបន្ថែម ឬដកចេញ នូវទីតាំងទន្លេ ផ្លូវគមនាគមន៍ ផែនទីរដ្ឋបាល និងទីតាំងការិយាល័យនយោបាយទៀតផង ។ តម្រុយទាំងនេះបង្ហាញនូវទីតាំងជាក់លាក់នៃវាលកប់ខ្មោចរួម គុក ឬបូជនីយដ្ឋាន ។

នៅពេលដែលការស្រាវបន្តដំណើរទៅមុខ ប្រព័ន្ធទិន្នន័យភូមិសាស្ត្រកម្ពុជានឹងបន្តលូតលាស់ និងបង្ហាញនូវការធ្វើទុក្ខទោសនៅតាមតំបន់នានារបស់បក្សកុម្មុយនិស្តកម្ពុជា កាន់តែ

សុក្រឹតឡើងទៀត ។ ទិន្នន័យ GIS នេះគឺជាប្រភពដ៏សំបូរបែប បង្ហាញអំពីភស្តុតាងរូបវន្តនៃអំពើឃោរឃៅប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យ ។ វគ្គបន្ទាប់ទៀតនេះនឹងនិយាយអំពីមូលហេតុដែលនាំឲ្យប្រព័ន្ធទិន្នន័យភូមិសាស្ត្រកម្ពុជាមានសារសំខាន់ក្នុងការស្ថាបនាឡើងវិញនូវប្រវត្តិសាស្ត្រកម្ពុជាអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដោយកំណត់ច្បាស់នូវការទទួលខុសត្រូវអំពីការធ្វើទុក្ខទោសរបស់របបនេះ និងការរក្សានូវការចងចាំអំពីសោកនាដកម្មរបស់កម្ពុជា ។

### ការពិភាក្សាជាលក្ខណៈប្រវត្តិសាស្ត្រៈ ជាភេរវកម្មអនាធិបតេយ្យ ឬដោយមានការចាត់តាំងច្បាស់លាស់?

ទោះបីជាអំពើឃោរឃៅកើតឡើងនៅកម្ពុជាគ្មានអ្វីគួរឲ្យសង្ស័យក៏ដោយ ប៉ុន្តែមានការខ្វែងគំនិតគ្នាទៅលើការបកស្រាយភស្តុតាងប្រវត្តិសាស្ត្រដែលមានសព្វថ្ងៃ ។ ការខ្វែងគំនិតគ្នានេះ បង្ហាញអំពីការលំបាកក្នុងការទទួលយកនូវពត៌មានដែលសុក្រឹតទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការពិភាក្សានេះក៏បង្ហាញជូនដែរនូវអង្គហេតុដែលថាអ្នកវិភាគទៅលើសម័យប៉ុលពតត្រូវបានបែងចែកជាក្រុមទៅតាមការបកស្រាយទិន្នន័យដែលមាន ។ នយោបាយក្តៅគគុកនិងការរំជួលចិត្តជុំវិញបញ្ហាសង្គ្រាមឥណ្ឌូចិន បានត្រឹមតែប្រមូលផ្តុំជម្លោះផ្នែកទ្រឹស្តីតែប៉ុណ្ណោះ ។ វគ្គនេះពិពណ៌នាអំពីថាតើបច្ចេកវិទ្យា GIS និងទិន្នន័យផែនទីអាចជួយដោះស្រាយបញ្ហាប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួនយ៉ាងដូចម្តេចខ្លះ ។

### ចំនួនមនុស្សស្លាប់

ប្រវត្តិវិទូបានពិភាក្សាយ៉ាងផុលផុសទៅលើបញ្ហាជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ ក្នុងនោះរួមមានបញ្ហាជាក់ស្តែងបំផុតមួយចំនួនផង ។ ដូចជាថា មានការវែកញែកតាមបែបសិក្សាស្រាវជ្រាវអំពីចំនួនមនុស្សស្លាប់នៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ លោក ម៉ៃឃើល វីកឃ័រី ប៉ាន់ស្មានថា មានមនុស្សប្រមាណ ៧៥០០០០ នាក់ បានស្លាប់បាត់បង់ជីវិត ចំណែកអ្នកក្រៅពីនោះ គឺស្លាប់ដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិកនិងសង្គ្រាមស៊ីវិលឆ្នាំ១៩៧០-១៩៧៥ ។ លោក ដេវីដ ឆេនដល័រ ប៉ាន់ស្មានថា មានមនុស្សមួយលាននាក់បានស្លាប់បាត់បង់ជីវិត ។ ចំណែកឯ ប៊ែន ឃៀរនិន, ស៊ីវ ហេដឌ័រ, ដូឌីត ប៊ែននីស៊័រ, និង ដេច ចនសុន ប៉ាន់ស្មានថា ចំនួនមនុស្សស្លាប់នៅកម្ពុជាមានចំនួនចន្លោះពី១,៥លានទៅ១,៨លាននាក់ ។ លោក ក្រេច អេចឆេសាន់ ផ្តល់នូវតួលេខខ្ពស់ជាងគេ ដោយអះអាងថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានមនុស្សស្លាប់ចំនួនជាង៣លាននាក់ ។ ប្រព័ន្ធទិន្នន័យភូមិសាស្ត្រកម្ពុជាមិនអាចសម្រេចទៅតាមការពិភាក្សាគ្នាដែលមិនទាន់ចប់នេះឡើយ ប៉ុន្តែវាអាចផ្តល់នូវការប៉ាន់ស្មានមួយដែលមានលក្ខណៈច្បាស់លាស់ជាងនេះ ។ ដោយយកមកផ្តុំគ្នានូវកិច្ចសម្ភាសន៍ជាងមួយពាន់ ការវិភាគលើឯកសារ និងការវិភាគតាមកោសល្យវិច័យដែលកំពុងតែធ្វើឡើងទៅលើទីតាំងរណ្តៅសាកសព និងគ្រោងអដ្ឋិធាតុ ទិន្នន័យផែនទីបង្ហាញថា យ៉ាងហោចណាស់មានមនុស្ស ២០៣៨៧៣៥ នាក់ ស្លាប់ក្រោមរបបប៉ុលពត ។

### កម្រិតនៃការរៀបចំផែនការនិងគ្រប់គ្រងថ្នាក់កណ្តាល

ការវែកញែកខុសៗគ្នាទៅលើចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្រាន់តែជាផ្នែកមួយនៃការបកស្រាយអំពីបញ្ហាប្រវត្តិសាស្ត្រតែប៉ុណ្ណោះ ។ អ្នកវិភាគទាំងឡាយក៏មានការយល់ឃើញផ្សេងៗគ្នាទៅលើសារជាតិនិងគោលដៅនៃការដឹកនាំប្រទេសរបស់របបខ្មែរក្រហមដែរ ។ យោងតាមអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលសរសេរសៀវភៅនៅអំឡុងពេលនិងក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំបន្តិចឃើញថា របបប៉ុលពតមានអំណាចកណ្តាលខ្លាំង និងមានការគ្រប់គ្រងដ៏មានអំណាចមកលើស្ទើរគ្រប់តំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ឃៀរនិន យល់ស្របច្រើនទៅលើដំហរនេះ ។ ឃៀរនិន សង្កត់ធ្ងន់ទៅលើ “មនោគមវិជ្ជាប្រកាន់ពូជសាសន៍” របស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា និងការបញ្ជាប្រកបដោយភាពដាច់ណាត់ឲ្យមានការវាយប្រហារមកលើជនជាតិចាម ព្រះសង្ឃ ជនជាតិ វៀតណាម កុលសម្ព័ន្ធរស់នៅតាមតំបន់ភ្នំ និងជនជាតិភាគតិច ក៏ដូចជាអ្នកកាន់សាសនាភាគតិចផ្សេងៗទៀត ។

ចំណែកលោក ឆេនដល័រ មានទស្សនៈផ្សេងពីនេះ ដោយ

អះអាងថា គោលដៅកុម្មុយនិស្តនិងជាតិនិយមដាច់ខាតនិងផងដើល របស់របបកម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យមានអំពើឃោរឃៅ ជាផនយោបាយ "ប្រកាន់ពូជសាសន៍" ឬប្រល័យពូជសាសន៍ទៅទៀត ។ ឆេនដល័រ សន្និដ្ឋានថា ការស្លាប់ភាគច្រើនបណ្តាលមកពីការទទួលអាហារមិនគ្រប់គ្រាន់ ជំងឺតម្កាត់ និងការបាក់កម្លាំង ដែលជាលទ្ធផលនៃកម្មវិធីប្រែក្លាយកម្ពុជាឲ្យទៅជាសង្គមបរិសុទ្ធដែលមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាគិតថានឹងអាចសម្រេចបានដោយចំណាយតិចបំផុត ។ ប៉ុងចូត ផ្តល់នូវទស្សីករណ៍ប្រហាក់ប្រហែលគ្នានេះដែរ ដោយហៅការធ្វើទុក្ខទោសទាំងឡាយប្រព្រឹត្តឡើងដោយបក្សកុម្មុយនិស្តកម្ពុជាថាជាការអនុវត្តឥតខ្ចោះទៅលើមនោគមវិជ្ជាមួយដែលត្រូវបានជម្រុញឲ្យទៅឆ្ងាយហួសពីតក្កភាពផ្ទៃក្នុងរបស់ខ្លួនទៅទៀត ។ ដូចជា ឃៀរនិន ដែរ ចំណុចទាំងនេះបញ្ជាក់អំពីធាតុផ្សំដ៏សំខាន់នៃការរៀបចំផែនការពីអំណាចកណ្តាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែអ្នកស្រាវជ្រាវទាំងនេះមានគំនិតផ្ទុយគ្នាទៅលើកម្រិតនៃមនុស្សឃាតចេញពីគោលនយោបាយរៀបចំទុកជាមុន ។

វីកយ័ររី បានបកស្រាយបន្ថែមទៀតទៅលើអ្វីដែលនិយាយរួចមកហើយ ដោយចាត់ទុកថា បដិវត្តខ្មែរក្រហមគឺជាការបះបោរចេញពីប្រជាកសិករប្រឆាំងនឹងវណ្ណៈគហបតីជិះជាន់ ។ លោកទាញហេតុផលថា ការធ្វើទុក្ខទោសដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាលទ្ធផលចេញពីបដិវត្តកើតចេញពីប្រជាកសិករប្រឆាំងនឹងវណ្ណៈគហបតីដ៏រឹងមាំមិនងាយគាស់រំលើង ។ "ជាតិនិយម ប្រជាជននិយម និង ប្រជាកសិករនិយម ពិតជាជម្នះបាននូវលទ្ធិកុម្មុយនិស្ត" ហើយអំពើឃោរឃៅចេញពីមេដឹកនាំមានតិចជាងបដិវត្តន៍ប្រជាកសិករទេ ដែលធ្វើឲ្យប្រជាកសិករធ្វើ "នូវអ្វីដែលប្រជាកសិករបះបោរចង់ធ្វើកាលពីមុនចំពោះខ្មាំងទីក្រុងរបស់ខ្លួន" ។ លោក វីកយ័ររី ផ្តល់យោបល់ថា កម្មាភិបាលមូលដ្ឋានមានការទទួលខុសត្រូវច្រើនណាស់ចំពោះអំពើឃោរឃៅ ដោយទាញហេតុផលថា ការធ្វើទុក្ខទោសធ្ងន់ធ្ងរបំផុតជាទូទៅគឺខុសពីគោលនយោបាយជាជាងខុសពីគោលបំណង" ។

វីកយ័ររី ក៏បានអះអាងទៀតថា មានតំបន់ជាច្រើនមានការធ្វើទុក្ខទោសតិចតួចនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ "អង្គការ" បានពុះចែកប្រទេសកម្ពុជាឲ្យទៅជាតំបន់រដ្ឋបាលពីរ (ប្រហែលជា ក្រចេះ និង ភ្នំពេញ) ព្រមទាំងភូមិភាគចំនួនប្រាំពីររួមមាន ភូមិភាគបូព៌ា ភូមិភាគឦសាន ភូមិភាគឧត្តរ ភូមិភាគកណ្តាល ភូមិភាគពាយ័ព្យ ភូមិភាគបស្ចិម និងនិរតី ។ ភូមិភាគនីមួយៗត្រូវចែកជាតំបន់ ស្រុក ឃុំ និងសហករណ៍ភូមិ ។ ខ្សែសង្វាក់បញ្ជាលាតសន្ធឹងតាមរយៈខ្សែបណ្តោយចាប់ពីបក្សកុម្មុយនិស្តកម្ពុជារហូតដល់ភូមិភាគនិងអង្គភាពរដ្ឋបាលតូចៗបន្តទៀត ។ លោក វីកយ័ររី អះអាងថា ភូមិភាគពាយ័ព្យ និងផ្នែកមួយចំនួនទៀតនៃភូមិភាគឧត្តរនិងភូមិភាគកណ្តាលមានអំពើឃោរឃៅច្រើនជាងគេ ។ លោកសន្និដ្ឋានថា ភូមិភាគនិរតីដែលគ្រប់គ្រងដោយជនដៃដល់ដែលពិការជើងម្ខាងឈ្មោះ "តាម៉ុក" គឺជាភូមិភាគគំរូរបស់កម្ពុជាប្រជាធិបតេយ្យ ។

ទាំង វីកយ័ររី និង ហេដឌ័រ អះអាងថា ភូមិភាគបូព៌ាមានអ្វីម្យ៉ាងមានលក្ខណៈពិសេសនៅក្នុងកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចណាស់នៅក្រោយឆ្នាំ១៩៧៧ នៅពេលដែលការវាយប្រយុទ្ធគ្នាជាមួយអ្នកបះបោរគាំទ្រដោយវៀតណាមមានកម្រិតកាន់តែធ្ងន់ធ្ងរឡើងៗ ។ ឃៀរនិន បង្ហាញនូវការ បោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ា ដែលជាផ្នែកមួយនៃគោលនយោបាយប្រល័យពូជសាសន៍ដ៏ធំ ។ ចំណែកឯ វីកយ័ររី និង ហេដឌ័រ ចាត់ទុកភូមិភាគបូព៌ាជាតំបន់មួយដែលចេះតែញាំញីដោយសង្គ្រាមមិនចេះដាច់ ។ សំពោង ពៅ និង សែកត្បូង បានផ្តល់គំនិតជាទូទៅ ហើយចាត់ទុករបបកម្ពុជាប្រជាធិបតេយ្យជាការតស៊ូប្រជាជននិងអសន្តិសុខក្នុងប្រទេស ។ ពៅ កត់សម្គាល់ឃើញថា អំពើឃោរឃៅភាគច្រើននៃរបបកម្ពុជាប្រជាធិបតេយ្យគឺជាវិធានការសន្តិសុខ "ទុកជាមុន" ហើយអះអាងថា ថ្នាក់ដឹកនាំបក្ស "បានធ្វើការប៉ុនប៉ងជាច្រើនតែមិនបានសម្រេចក្នុងការកម្រិតការកាប់សម្លាប់នេះ" ។ សែកត្បូង យល់ស្របស្ទើរតែទាំងស្រុង ដោយចាត់ទុករបបកម្ពុជាប្រជាធិបតេយ្យថា ជារបបមួយដែលមិនដែល "ឯករាជ្យម្ចាស់ការ" ហើយវាយប្រយុទ្ធឥតឈប់ឈរជាមួយក្រុមប្រឆាំងនានាដើម្បីស្តារសណ្តាប់ធ្នាប់របៀបរៀបរយនៅកម្ពុជាឡើងវិញ ។

អ្នកនិពន្ធទាំងពីររូបចង់បញ្ជាក់ថាមនុស្សឃាតបណ្តាលមកពីភាពឥតរបៀបរៀបរយនិងការធ្វើហួសបញ្ជាច្រើនជាងបណ្តាលមកពីមានផែនការគ្រោងទុកជាមុន និងដែលធ្វើឡើងតាមអំណាចកណ្តាល ។

នៅក្នុងការវិភាគថ្មីៗនេះដែលមានលក្ខណៈស្ទើរតែល្អិតល្អន់ លោក ហេដឌ័រ បង្ហាញនូវការសិក្សាមួយដែលមានលក្ខណៈព្រលាំមិនសូវច្បាស់ទៅលើតួនាទីរបស់កម្មាភិបាលជាន់ខ្ពស់និងកម្មាភិបាលថ្នាក់មូលដ្ឋានរបស់បក្សកុម្មុយនិស្តកម្ពុជា ។ លោក ហេដឌ័រ រិះគន់ បៀរនិន និងអ្នកដទៃទៀត ថាបាននិយាយលើសអំពីការគ្រប់គ្រង និងការរៀបចំផែនការដោយអំណាចកណ្តាលរបស់កម្ពុជាប្រជាធិបតេយ្យ និងរបបប៉ុលពតដែលធ្វើតាមណាហ្ស៊ី ។ បៀរនិន ទទួលស្គាល់ថា ខ្សែសង្វាក់នៃការបញ្ជានិងប្រព័ន្ធធ្វើការតាមបែបប្រជុំនិងរាយការណ៍ធ្វើឲ្យថ្នាក់ដឹកនាំនៅភ្នំពេញមានសមត្ថភាពក្នុងការផ្តង់ទៅលើព្រឹត្តិការណ៍នានាដែលកើតឡើងនៅតាមបណ្តាខេត្ត ប៉ុន្តែផ្អែកលើការស្រាវជ្រាវតាមកិច្ចសម្ភាសន៍ លោកអះអាងថា មេបញ្ជាការនៅតាមមូលដ្ឋានតែងតែរំលោភអំណាច ដោយប្រព្រឹត្តនូវអំពើឃោរឃៅដែលគ្មានការអនុញ្ញាតដែលថ្នាក់ដឹកនាំមជ្ឈិមគ្មានលទ្ធភាពត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ។

ម្យ៉ាងទៀត បច្ចេកវិទ្យា **GIS** មិនអាចផ្តល់នូវដំណោះស្រាយចំពោះការពិភាក្សាជាលក្ខណៈប្រវត្តិសាស្ត្រដ៏ស្មុគ្រស្មាញបានទេ ប៉ុន្តែវាអាចផ្តល់នូវការយល់ដឹងកាន់តែសុក្រឹតថែមមួយកម្រិតទៀត ។ ប្រសិនបើរបបខ្មែរក្រហមប្រើអំណាចកណ្តាលខ្លាំងនិងអនុវត្តតាមគោលនយោបាយដូចៗគ្នាតាំងពីលើដល់ក្រោមនោះ គេអាចរំពឹងទុកថានឹងមានទីតាំងរណ្តៅសាកសពរួមនិងទីតាំងគុកមានល្បាយស្មើៗគ្នាគ្រប់ទីប្រជុំជននៅទូទាំងប្រទេសមិនខាន ។ ផ្ទុយមកវិញ ប្រសិនបើកម្មាភិបាលថ្នាក់មូលដ្ឋានទទួលខុសត្រូវចំពោះឃាតកម្មភាគច្រើននោះគេ អាចបង្កើតហេតុផលបានថាតំបន់ខ្លះនឹងទទួលរងនូវការរំលោភអំណាចជាងកន្លែងផ្សេងទៀតជាមិនខាន ។ វានឹងក្លាយជាការចែងឲ្យវិសាមញ្ញមួយ ប្រសិនបើកម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនិស្តកម្ពុជានៅគ្រប់តំបន់នៃរបបកម្ពុជាប្រជាធិបតេយ្យធ្វើលើសពីអំណាចរបស់ខ្លួនក្នុងកម្រិតប្រហាក់ប្រហែលករណីនេះ ។

ទន្នន័យការធ្វើផែនទីគាំទ្រទស្សនៈនីមួយៗតាមរយៈការប្រើបច្ចេកវិទ្យា **GIS** មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើផែនទីទីតាំងនានានៅគ្រប់ភូមិនិងសង្កាត់ទាំងអស់ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅដល់កាលពីប៉ុន្មានឆ្នាំកន្លងមក ។ កិច្ចសម្ភាសន៍នានាបានបង្ហាញថា ភាគច្រើននៃភូមិនិងសង្កាត់ដែលមានចំនួនរហូតដល់រាប់ពាន់នោះត្រូវបានប្រជាជនតាំងទីលំនៅក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ ការធ្វើផែនទីទៅលើទីតាំងនៃភូមិនិងសង្កាត់ទាំងនោះមិនបានផ្តល់នូវចំនួនដង់ស៊ីតេប្រជាជនពិតប្រាកដនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែវាផ្តល់នូវការប៉ាន់ស្មានជាក់ស្តែងមួយ ។ ដោយយកការធ្វើផែនទីភូមិ-ឃុំដាក់លើទីតាំងរណ្តៅសាកសពនិងគុកគេអាចមើលឃើញ “ដង់ស៊ីតេ” នៃអំពើគួរឲ្យព្រឺព្រួចរបស់ខ្មែរក្រហមទូទាំងទីប្រជុំជននានា ។ មកទល់នឹងពេលនេះ ផែនទីធ្វើតាមបច្ចេកវិទ្យា **GIS** បង្ហាញអំពីភាពដូចៗគ្នាគួរឲ្យចាប់អារម្មណ៍ទូទាំងតំបន់ភាគច្រើនដែលត្រូវបានចុះសិក្សាជាក់ស្តែង ។

ជាយូរលង់ណាស់មកហើយ ប្រជាជនកម្ពុជាភាគច្រើនបានរស់នៅលើទឹកដីទំនាបដ៏មានជីវជាតិជុំវិញបឹងទន្លេសាបនិងទន្លេសំខាន់ៗរបស់ប្រទេសកម្ពុជា ។ តំបន់ដែលមានភូមិមួយចំនួនតូចដែលមិនទាន់ទៅស្រាវជ្រាវដល់មានពីរប្រភេទ ។ ភាគច្រើននៃតំបន់ទាំងនោះមានដង់ស៊ីតេប្រជាជនរស់នៅតិច ។ ឧទាហរណ៍ នៅតំបន់ជួរភ្នំក្រវាញនៅភាគបស្ចិម និងព្រៃស្បាត នៅភាគឧត្តរនិងភាគឦសាន ។ តំបន់ដល់ដទៃទៀតដែលមិនទាន់ចុះស្រាវជ្រាវដល់ គឺតំបន់ដែលមានគ្រាប់មីនមិនទាន់ផ្ទុះ ផ្លូវលំបាកធ្វើដំណើរនិង (រហូតមកដល់ឆ្នាំ១៩៩៩) មានក្រុមបះបោរខ្មែរក្រហម ។ តំបន់ទាំងនេះមួយចំនួននឹងអាចចូលទៅស្រាវជ្រាវបាននៅក្នុងអំឡុងពេលប៉ុន្មានខែ-ឆ្នាំខាងមុខនេះ ហើយវានឹងផ្តល់ជាទិន្នន័យសំខាន់ៗបន្ថែមទៀត ។

គេអាចឃើញថាទីតាំងរណ្តៅសាកសពរួមមានលក្ខណៈស្មើៗគ្នានៅតាមសហគមន៍ដែលបានស្រាវជ្រាវរួចហើយ ដែលបង្ហាញឲ្យឃើញថាជាតំបន់ដែលមានប្រជាជនរស់នៅច្រើន ។ ការស្រាវជ្រាវតាមរយៈកិច្ចសម្ភាសន៍ដ៏ច្រើនសន្ធឹកសន្ធាប់

បញ្ជាក់ថា ភាគច្រើននៃទីតាំងកប់ខ្មោចទាំងនេះត្រូវបានលុបនៅរវាងឆ្នាំ១៩៧៥-១៩៧៩ ។ ផែនទីតាមបច្ចេកវិទ្យា GIS បង្ហាញដោយត្រង់ៗថា គ្មានតំបន់ណាមួយរបស់កម្ពុជាប្រជា-ធិបតេយ្យដែលគ្មានឃាតកម្មទ្រង់ទ្រាយធំទេ ។ ទិន្នន័យនេះមិនបង្ហាញថា ឃាតកម្មភាគច្រើនបណ្តាលមកពីនយោបាយរៀបចំឡើងពីមជ្ឈិមនោះទេ ប៉ុន្តែវាផ្តល់នូវភ័ស្តុតាងប្រយោលថាមានការរៀបចំពីមជ្ឈិម ។ មានតែតំបន់ដាច់ស្រយាលមួយចំនួននៅទិសឧត្តរនិងឦសានប៉ុណ្ណោះ ដែលអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញនូវតំបន់ដែលមានប្រជាជនរស់នៅច្រើនប៉ុន្តែគ្មានទីតាំងរណ្តៅសាកសពរួម ។

ទិន្នន័យនេះបង្ហាញឲ្យឃើញថាឃាតកម្មភាគច្រើនគឺកើតឡើងដោយសារការចាត់វិធានការប្រឆាំងនឹងការបះបោរ ឬការធ្វើជ្រុលហួសរបស់កម្មាភិបាលមូលដ្ឋាន ។ របបកម្ពុជាប្រជាធិបតេយ្យមិនទទួលនូវការគំរាមកំហែងធ្វើការបះបោរនៅគ្រប់ទីប្រជុំជននៅទូទាំងប្រទេសនោះទេ ។ ហើយក៏មិនទំនងជាថាកម្មាភិបាលថ្នាក់មូលដ្ឋានចេះតែធ្វើហួសពីបញ្ជាថ្នាក់លើឲ្យសម្លាប់ក្នុងទ្រង់ទ្រាយធំនោះដែរ ។ ប្រសិនបើរដ្ឋាភិបាលកណ្តាលគ្មានអំណាចបញ្ឈប់នូវការធ្វើហួសបញ្ជា ហើយប្រសិនបើថ្នាក់ដឹកនាំភូមិភាគឬកម្មាភិបាលថ្នាក់មូលដ្ឋានប្រតិបត្តិការដោយឯករាជ្យរៀងៗខ្លួននោះ ម៉្លេះមានការខុសប្លែកគ្នាច្រើនពីភូមិភាគមួយទៅភូមិភាគមួយ ពីតំបន់មួយទៅតំបន់មួយ និងពីស្រុកមួយទៅស្រុកមួយ ។ បច្ចេកវិទ្យា GIS បង្ហាញជូននូវរូបភាពខុសប្លែកពីគ្នា ហើយផ្តល់នូវតួនាទីដ៏សំខាន់សម្រាប់រដ្ឋាភិបាលកណ្តាល ។

ទស្សនៈនេះគាំទ្រដោយការជាប់ទាក់ទងគ្នារវាងទីតាំងរណ្តៅសាកសពរួម និងអតីតមន្ទីរសន្តិសុខបក្សកុម្មុយនិស្តកម្ពុជា ។ រណ្តៅសាកសពជាច្រើនស្ថិតនៅជាប់ទៅនឹងមន្ទីរសន្តិសុខតែម្តង ដែលជាទីតាំងរដ្ឋបាលដ៏សំខាន់សម្រាប់គ្រប់គ្រងប្រព័ន្ធព្រហ្មទណ្ឌនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បច្ចេកវិទ្យា GIS ធ្វើឲ្យការជាប់ទាក់ទងគ្នាមានលក្ខណៈច្បាស់លាស់ដូចខាងក្រោម÷

ប្រសិនបើកម្មាភិបាលថ្នាក់មូលដ្ឋានសម្លាប់មនុស្សច្រើនដោយគ្មានការអនុញ្ញាត ហើយរិះរកមធ្យោបាយលាក់បាំងកុំឲ្យអ្នកគ្រប់គ្រងដឹង គេអាចរំពឹងថារណ្តៅសាកសពរួមច្បាស់ជាត្រូវលាក់បាំងដោយសមហេតុផល ។ ការរាយរណ្តៅសាកសពរួមនៅជុំវិញមន្ទីរសន្តិសុខបក្សកុម្មុយនិស្តកម្ពុជាអាចសមហេតុផលបន្តិចបន្តួច ។ មន្ទីរទាំងនេះគឺស្ថិតនៅក្នុងចំណោមទីដែលតម្រង់ទៅសម្រាប់កម្មាភិបាលសន្តិសុខជាន់ខ្ពស់ ។ នៅជុំវិញមន្ទីរដែលមានរណ្តៅសាកសពរួម អាចបញ្ជាក់ថា ការរំលោភហួសបញ្ជានៅតាមមូលដ្ឋានអាចនឹងត្រូវបានកត់សម្គាល់និងរាយការណ៍ ។

តាមការសន្និដ្ឋានអាចទាញបានថា ការធ្វើទុក្ខទោសនានាបានកើតឡើងនៅតាមគុកទូទាំងប្រទេស ហើយថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាគ្មានអំណាចក្នុងការបញ្ឈប់អំពើទាំងនោះ ។ ក៏ប៉ុន្តែ ដូចដែលបានទាញជាទឡ្ហីករណ៍ខាងលើរួចមកហើយថា វាមានលក្ខណៈហួសពីធម្មតាដែលកម្មាភិបាលសន្តិសុខនៅតំបន់ផ្សេងៗគ្នារំលោភអំណាចរបស់ខ្លួនរហូតទៅដល់កម្រិតធ្ងន់ធ្ងរបែបនេះ ។ ស្ទើរតែគ្រប់មន្ទីរសន្តិសុខបក្សសុទ្ធតែមានរណ្តៅសាកសពនៅក្បែរនោះ ។ ប្រហែលជាថា មានរណ្តៅសាកសពរួមមួយចំនួនតូចនៅតាមតំបន់នានាឆ្ងាយពីមន្ទីរសន្តិសុខបក្សកុម្មុយនិស្តកម្ពុជា ។ ប្រការនេះបង្ហាញជាភ័ស្តុតាងឯកសារនិងសក្ខីកម្មថា មន្ទីរសន្តិសុខបក្សកុម្មុយនិស្តកម្ពុជាគឺជាទីឋានសម្រាប់ការសម្លាប់មនុស្សជាច្រើន ។

វាជាការពិបាកណាស់ក្នុងការធ្វើឲ្យស៊ីគ្នារវាងទិន្នន័យចេញពីបច្ចេកវិទ្យា GIS ទៅនឹងរូបភាពរបស់រដ្ឋនៅក្នុងភាពជ្រួលច្របល់នៅតាមថ្នាក់មូលដ្ឋាន ។ ទោះបីជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យគ្មានអំណាចក្នុងការទប់ស្កាត់ឃាតកម្មនៅគ្រប់ទីកន្លែងក៏ដោយ ក៏មេដឹកនាំទាំងនោះមានលទ្ធភាពគ្រប់គ្រងសភាពការណ៍តាមតំបន់នានាទូទាំងប្រទេសប្រសើរជាងតំបន់ផ្សេងៗទៀតដែរ ។ ទិន្នន័យនេះបង្ហាញនូវដង់ស៊ីតេនៃការធ្វើទុក្ខទោសស្មើៗគ្នានៅក្នុងមន្ទីរសន្តិសុខនៅទូទាំងប្រទេសកម្ពុជា ។ ប្រការនេះបញ្ជាក់ច្បាស់ថាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមានតួនាទីយ៉ាងសំខាន់នៅក្នុងការបង្គាប់បញ្ជា ឬយ៉ាងហោចណាស់បណ្តោយឲ្យមានអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំកើតឡើងនៅតាមមូលដ្ឋាន ។

**ការពិភាក្សាផ្នែកច្បាប់ៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ ឃាតកម្មទ្រង់ទ្រាយធំ?**

បញ្ហានានាដែលពិភាក្សាខាងលើមិនមែនមានសារសំខាន់សម្រាប់ប្រវត្តិសាស្ត្រតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការពាក់ព័ន្ធទៅនឹងផ្នែកច្បាប់ទៀតទេ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំយុត្តិធម៌ចំពោះការធ្វើទុក្ខទោសដែលប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីមានការចរចាមួយរយៈធំមក អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងថ្មីៗនេះក្នុងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ តុលាការនេះមានអំណាចបើកសវនាការកាត់សេចក្ដីករណីនានាប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវខ្ពស់បំផុតពីបទប្រព្រឹត្តអំពើឃោរឃៅនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ចុងចោទប្រហែលជាអាចទទួលរងការចោទប្រកាន់អំពីបទល្មើសជាច្រើនទៀត រួមទាំងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទិន្នន័យផលិតចេញដោយបច្ចេកវិទ្យា *GIS* មិនអាចបង្ហាញជាភ័ស្តុតាងឲ្យបានច្រើនណាស់ណាអំពីឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងច្បាប់ឡើយ ។ ប៉ុន្តែដូចដែលរៀបរាប់ខាងក្រោមនេះវាអាចជួយបង្ហាញធាតុផ្សំសំខាន់មួយចំនួនតូចនៃបទល្មើសដ៏សំខាន់ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

## ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាបទល្មើសឧក្រិដ្ឋមួយប្រភេទក្នុងចំណោមបទល្មើសឧក្រិដ្ឋដ៏ឃោរឃៅបំផុតប្រឆាំងនឹងច្បាប់អន្តរជាតិ ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ហៅកាត់ថា "ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម" បានកំណត់នូវនិយមន័យរួមទៅលើបទល្មើសនេះថា: "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដែលជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ។

ទង្វើជាក់ស្ដែងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដូចជាមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត ។

មានហេតុផលដ៏មានទម្ងន់ក្នុងការធ្វើឲ្យជឿថា មេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប៉ុន្តែដើម្បីវិនិច្ឆ័យថា ចុងចោទបក្សកុម្មុយនិស្តកម្ពុជាមានកំហុសព្រហ្មទណ្ឌត្រូវតែបញ្ជាក់ធាតុផ្សំជាច្រើនឲ្យបានច្បាស់ជាមុនសិន ។ ទីមួយ គឺចុងចោទនោះត្រូវតែបានអនុវត្តបានបញ្ជា បានជួយជ្រោមជ្រែងនិងជំរុញឬសម្រុះសម្រួលទៅតាមការប្រព្រឹត្តអំពើដូចជាការធ្វើមនុស្សឃាត ទារុណកម្ម និងការបង្ខាំងមនុស្សដោយគ្មានការកាត់សេចក្ដីត្រឹមត្រូវ ។ ទីពីរ គឺការវាយប្រហារទាំងនោះត្រូវតែធ្វើឡើង"មកលើជនស៊ីវិល" ។ ទីបី គឺការវាយប្រហារត្រូវតែធ្វើឡើងដោយហេតុផលជាតិសាសន៍ ជនជាតិជាតិពន្ធុ សាសនា ឬនិន្នាការនយោបាយរបស់ជនរងគ្រោះ ។ ទីបួន គឺអំពើឃោរឃៅត្រូវតែមានការពាក់ព័ន្ធជាមួយនឹងចំណាត់ការរបស់រដ្ឋ ។ ចំណុចចុងក្រោយគឺ អំពើឃោរឃៅទាំងនោះត្រូវតែធ្វើឡើងក្នុងលក្ខណៈ "ទ្រង់ទ្រាយធំឬប្រព័ន្ធ" ។

បច្ចេកវិទ្យា *GIS* អាចផ្ដល់នូវជំនួយមួយចំនួនដល់អត្ថិភាពឬអវត្តមាននៃធាតុផ្សំនីមួយៗនៃធាតុផ្សំទាំងបីខាងដើម ។ ទិន្នន័យផែនទីអាចបង្ហាញនូវលក្ខណៈក្រាហ្វិកដ៏ច្បាស់លាស់ថាឃាតកម្ម និងការដាក់គុកពិតជាកើតឡើងនៅក្នុងតំបន់ដែលប្រជាជនស៊ីវិលរស់នៅទូទាំងប្រទេស ។ មកដល់បច្ចុប្បន្ន ទិន្នន័យ *GIS* បញ្ជាក់ច្បាស់ថា ការធ្វើទុក្ខទោសបានកើតឡើងនៅទូទាំងតំបន់នានា ដែលមានប្រជាជនរស់នៅជាក្រុមជាតិសាសន៍ ជនជាតិជាតិពន្ធុ និងក្រុមសាសនា ។ ប្រការនេះបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទំនងជាត្រូវបានប្រព្រឹត្តឡើងដោយហេតុផលនយោបាយ ។ សម្មតិកម្មនេះគាំទ្រដោយភ័ស្តុតាងឯកសារ និងសក្ខីកម្មដ៏ច្រើនសន្ធឹកសន្ធាប់ដែលបញ្ជាក់អំពីការប្រើប្រែងរបស់បក្សកុម្មុយនិស្តកម្ពុជា ក្នុងការ "កម្ទេច" ឬ "បោសសម្អាត" ខ្មាំងនយោបាយរបស់បដិវត្តន៍ ។ ខ្មាំងបដិវត្តន៍រួមបញ្ចូលទាំងសមាជិករដ្ឋាភិបាលលន់ណុល និងអ្នកដែលចាត់ទុកថាជាអ្នកគាំទ្រ

"ចក្រពត្តិនិយម" "អ្នកសើរើ"សូវៀត និង "អនុត្តរភាពនិយម" វៀតណាម ។

ក៏ប៉ុន្តែ ទិន្នន័យផែនទី GIS មិនរួមបញ្ចូលផងទេនូវលទ្ធភាព ដែលថាក្រុមដែលទទួលបានការគាំពារ ជួនកាលត្រូវបានដៅជាមុខសញ្ញាវាយប្រហារដោយផ្អែកលើមូលហេតុសាសនាឬជាតិពន្ធុ ។ នៅពេលយកមកដាក់ពីលើទិន្នន័យភូមិសាស្ត្រ ផែនទីចេញពីបច្ចេកវិទ្យា GIS នេះក៏អាចផ្តល់នូវការបង្ហាញតាមរយៈរូបភាពជាក់ស្តែងនិងស្ថិតិទាក់ទងទៅនឹងឥទ្ធិពលវិសមាមាត្រនៃការសម្លាប់ នៅតាមតំបន់នានាដែលមានជនជាតិភាគតិចរស់នៅ ។ ឧទាហរណ៍ ដូចជា ការរកឃើញថ្មីៗនេះបង្ហាញថា តំបន់មួយចំនួនទៅខេត្តកំពង់ចាម ផ្ទុកទៅដោយរណ្តៅសាកសពរួមមួយចំនួនធំ ។ ដោយសារតំបន់ទាំងនោះមានជនជាតិចាមរស់នៅច្រើន ទិន្នន័យនេះគាំទ្រការអះអាងរបស់លោក យៀរនិន ដែលថានៅក្រោមរបបខ្មែរក្រហមជនជាតិចាមនៅភូមិភាគបូព៌ាទទួលរងនូវការធ្វើទុក្ខទោសមិនស្មើគ្នាទេបើផ្អែកទៅតាមស្ថិតិ ។ បណ្តុំរណ្តៅសាកសពរួមប្រហាក់ប្រហែលគ្នានេះមាននៅផ្នែកផ្សេងៗនៃខេត្តព្រៃវែង ស្វាយរៀង និងតាកែវ ដែលមានជនជាតិវៀតណាមរស់នៅនិងនៅជុំវិញទីក្រុងភ្នំពេញដែលមានជាតិពន្ធុរស់នៅច្រើនព្រមទាំងអ្នកគាំទ្ររបស់លន់ណុលដែលត្រូវបានបណ្តេញចេញពីតំណែងផង ។

ការជាប់ទាក់ទងគ្នាជាក់ស្តែង ដែលភ្ជាប់គ្នាជាមួយប្រភពភ័ស្តុតាងផ្សេងៗទៀត និងដែលភ្ជាប់ទៅនឹងការសិក្សាតាមរយៈកោសល្យវិច័យនេះ អាចបញ្ជាក់ថា ក្រុមជនជាតិភាគតិចមួយចំនួនបានទទួលរងនូវការកាប់សម្លាប់ច្រើនជាងក្រុមជនជាតិភាគច្រើន ។ ឥទ្ធិពលវិសមាមាត្រនេះមិនអាចបង្ហាញថា ក្រុមមួយចំនួនត្រូវបានក្លាយជាមុខសញ្ញានៃការធ្វើទុក្ខទោសនោះទេ ប៉ុន្តែវាអាចជាភ័ស្តុតាងប្រយោលទាក់ទងនឹងការដាក់ជាមុខសញ្ញានេះ ។ មិនតែប៉ុណ្ណោះ វាក៏បង្ហាញទៀតថា មានការកើតឡើងនូវអំពើប្រល័យពូជសាសន៍ដែលហាមមិនឲ្យមានការវាយប្រហារដោយផ្អែកលើហេតុផលសាសនា ជាតិសាសន៍ ជនជាតិ ឬជាតិពន្ធុឡើយ ។

### អំពើរបស់រដ្ឋដែលមាន "ទ្រង់ទ្រាយធំ ឬ ជាប្រព័ន្ធ"

ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការសម្លាប់ក៏ត្រូវតែមានលក្ខណៈ "ទ្រង់ទ្រាយធំឬជាប្រព័ន្ធ" ដែរ ហើយអំពើនេះត្រូវតែធ្វើឡើងដោយរដ្ឋ ។ ពាក្យថា "ទ្រង់ទ្រាយធំ" ជាទូទៅចង់សំដៅទៅលើអត្តិភាពជាក់ស្តែងនៃចំនួនជនរងគ្រោះ ។ ចំណែកឯពាក្យ "ជាប្រព័ន្ធ" វិញគឺសំដៅទៅលើការរៀបចំផែនការ និងសំដៅប្រព្រឹត្តមកលើបុគ្គលនៃក្រុមជាក់លាក់ណាមួយ ។ តម្រូវការឲ្យមានទង្វើរបស់រដ្ឋ គឺធម្មតាគេចង់បកស្រាយថា ធ្វើទុក្ខទោសនោះត្រូវតែប្រព្រឹត្តឡើងដោយមានការញុះញង់ឬបណ្តោយឲ្យធ្វើពីសំណាក់អាជ្ញាធររដ្ឋាភិបាល ។

ចំនួនរណ្តៅសាកសពរួមដ៏ច្រើនដែលបង្ហាញតាមរយៈផែនទី GIS សបញ្ជាក់ដោយមិនអាចប្រកែកបានថា ការកាប់សម្លាប់ទាំងនោះគឺធ្វើឡើងដោយ "ទ្រង់ទ្រាយធំ" ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ដែលចូលក្នុងលក្ខខណ្ឌតម្រូវរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលថា "មានទ្រង់ទ្រាយធំ ឬ ជាប្រព័ន្ធ" ។ មានជំនាញការច្បាប់ខ្លះបានទាញហេតុផលថា សូម្បីតែការធ្វើទុក្ខទោសនោះមានចំនួនតិចឬច្រើន វាមានលក្ខណៈជាប្រព័ន្ធស្រេចបាត់ទៅហើយដើម្បីឲ្យចូលទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ដូចដែលបានលើកឡើងខាងដើមរួចមកហើយ វត្តមាននៃរណ្តៅសាកសពរួមដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងតំបន់ជាច្រើនទូទាំងប្រទេសយ៉ាងនេះបញ្ជាក់ថា ភេរវកម្មទាំងនេះគឺពិតជាមានផែនការច្បាស់លាស់ចេញពីរដ្ឋាភិបាលកណ្តាល ។ លើសពីនេះទៀត ការដែលរណ្តៅសាកសពជាច្រើនស្ថិតនៅកៀកនឹងមន្ទីរសន្តិសុខរបស់បក្សកុម្មុយនិស្តកម្ពុជា បានពង្រឹងបន្ថែមទៅលើភ័ស្តុតាងឯកសារនិងសក្ខីកម្មដែលមានស្រាប់ថា ការសម្លាប់ជាច្រើនដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអនុវត្តជាផ្នែកមួយនៃដំណើរការសកម្មភាព"ជាប្រព័ន្ធ"របស់រដ្ឋ ទាក់ទងទៅនឹងការដាក់គុក ការសួរចម្លើយ និងការសម្លាប់រង្គាល ។

*ហេតុអ្វីបានជាការកំណត់បទល្មើសរបស់ខ្មែរក្រហមមានសារសំខាន់?*

ការកំណត់បទល្មើសនានាប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមមានសារសំខាន់ជាងការសិក្សាតែលើទ្រឹស្តី ។ វាក៏មានសារសំខាន់ជ្រាលជ្រៅខាងផ្នែកនយោបាយ ព្រមទាំងខាងសីលធម៌

ទៀតផង ។ ទោះបីជាអំពើប្រល័យពូជសាសន៍ត្រូវបានចាត់ទុកថាជាបទល្មើសដ៏គួរឲ្យស្អប់ខ្ពើមបំផុតក៏ដោយ ក៏ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមានលក្ខណៈខុសប្លែកគ្នាឆ្ងាយដែរ ។ សាធារណជនចាត់ទុកការសម្លាប់មនុស្សក្នុងចំនួនដ៏ច្រើនខាងលើថាមានលក្ខណៈគ្មានមេត្តា ហើយកំណាចដូចបិសាច ។ ជនរងគ្រោះនៃរបបខ្មែរក្រហមជាច្រើនអាចមិនពេញចិត្តចំពោះការវិនិច្ឆ័យក្តីទៅតាមផ្លូវច្បាប់ទៅលើមេដឹកនាំកម្ពុជាប្រជាធិបតេយ្យថាមានកំហុសពីបទមនុស្សឃាត“ធម្មតា” ។ ទំហំនិងសារជាតិនៃអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាមទារឲ្យមានការកំណត់ក្នុងលក្ខណៈពិសេស ។ ដើម្បីឲ្យមានការបង្រួបបង្រួមជាតិពិតប្រាកដនៅកម្ពុជា សាធារណជនត្រូវតែដឹងដោយវិញ្ញាណថាយុត្តិធម៌ត្រូវតែសម្រេចឲ្យបាន ។ នោះមិនមែនជាហេតុផលក្នុងការសន្និដ្ឋានតាមផ្លូវច្បាប់ទាំងខុសឆ្គងនោះទេ ប៉ុន្តែវាជាហេតុផលមួយក្នុងការប្រើប្រាស់ភស្តុតាងរួមទាំងទិន្នន័យ GIS ដើម្បីបង្ហាញអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឲ្យសមទៅនឹងកម្រិតដែលអំពើនេះត្រូវបានប្រព្រឹត្តជាក់ស្តែង ។

## បច្ចេកវិទ្យា GIS និង ការបង្កើតឲ្យមានការទទួលខុសត្រូវ

តាមរយៈការបង្ហាញជូននូវរណ្តៅសាកសពរួមចំនួនរាប់ពាន់ដែលបានស្រាវជ្រាវរកឃើញ និងចំនួនគុកដែលភាគច្រើនបន្សល់ទុកនូវឧបករណ៍ធ្វើទារុណកម្មផងនោះ គឺជាការរំពុកឲ្យមានការបង្កើតនូវការទទួលខុសត្រូវ ។ បន្ថែមពីលើការបង្ហាញនូវឧទាហរណ៍នៃការសម្លាប់និងអំពើឃោរឃៅផ្សេងទៀតទីតាំងកប់ខ្មោចនិងកន្លែងឃុំឃាំងមិនគួរឲ្យជឿបានថាមេដឹកនាំកម្ពុជាប្រជាធិប-តេយ្យមិនដឹងមិនឮអំពីការប្រព្រឹត្តមនុស្សឃាតក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀតក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ នោះទេ ។ ក្រៅពីនេះទៀតភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់គាំទ្រដល់ការនិយាយយោងថាមេដឹកនាំខ្មែរក្រហមខកខានមិនបានចាត់វិធានការទប់ទល់ឲ្យមានប្រសិទ្ធភាព ។ ការរួមផ្សំគ្នារវាងចំណេះដឹងជាក់ស្តែងនិងការចូលដៃក្នុងបទល្មើសវាមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញអំពីកំហុសរបស់មេដឹកនាំខ្មែរក្រហម តាមរយៈគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើដែលយកមកអនុវត្តដោយតុលាការនៅនូរិមប៊ឺកនិងតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ។

កាន់តែមានទម្ងន់ជាងនេះទៅទៀតនោះ គឺទីតាំងរណ្តៅសាកសពរួមនិងគុកនានា ផ្តល់នូវភស្តុតាងប្រយោលមានទម្ងន់ថាអំពើឃោរឃៅប្រព្រឹត្តឡើងដោយបក្សកុម្មុយនិស្តកម្ពុជាគឺជាផ្នែកមួយនៃផែនការចេញពីរដ្ឋាភិបាលមជ្ឈិមដែលចេញបញ្ជានិងត្រួតត្រាជ្រែងនិងជម្រុញដោយមេដឹកនាំកម្ពុជាប្រជាធិប-តេយ្យ ។ សភាពគុកនិងរណ្តៅសាកសពរួម និងសាក្សីដែលផ្តល់សក្ខីកម្មប្រហាក់ប្រហែលគ្នាពីតំបន់ផ្សេងៗគ្នានិងមិនដែលទាក់ទងគ្នាសោះនោះ គឺបញ្ជាក់យ៉ាងច្បាស់ថាការសម្លាប់ក្នុងទ្រង់ទ្រាយធំដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យមិនមែនជាការចៃដន្យនោះទេ ។ ការរៀបចំនិងការកំណត់ទិសដៅរបស់មេដឹកនាំរដ្ឋាភិបាលកណ្តាលឲ្យប្រព្រឹត្តបទឧក្រិដ្ឋកម្ម ធ្វើឲ្យសារសំខាន់នៃការទទួលខុសត្រូវតាមផ្លូវច្បាប់កាន់តែខ្លាំងឡើង ។ មន្ត្រីអង្គការសហប្រជាជាតិនិងមន្ត្រីកម្ពុជាគួរតែចាត់ទុកគំនរភស្តុតាងដ៏ច្រើននិងកំពុងតែពុកផុយជាការលើកទឹកចិត្តជាលក្ខណៈសីលធម៌និងការអនុវត្តជាក់ស្តែងដើម្បីឈានទៅបង្កើតយន្តការនានាទាក់ទងនឹងនីតិវិធីដែលនឹងកសាងនូវនីតិរដ្ឋនៅកម្ពុជា ព្រមទាំងផ្តល់នូវយុត្តិធម៌ដែលអាចជឿទុកចិត្តបានដល់អ្នកដែលរស់រានមានជីវិតពីរបបប៉ុលពត ។

## សេចក្តីសន្និដ្ឋានៈ ថែរក្សាការចងចាំជាប្រវត្តិសាស្ត្រ

ដូចដែលបានពិភាក្សាខាងដើមស្រាប់ បច្ចេកវិទ្យា GIS អាចជួយដល់ការបង្កើនឲ្យមានការយល់ដឹងអំពីប្រវត្តិសាស្ត្រនិងការបង្កើតការទទួលខុសត្រូវឲ្យកាន់តែសុក្រឹតឡើងទាក់ទងនឹងការរំលោភបំពានរាប់មិនអស់ប្រព្រឹត្តឡើងនៅក្នុងរបបប៉ុលពត ។ ប៉ុន្តែបច្ចេកវិទ្យានេះដើរតួនាទីចុងក្រោយនិងសំខាន់ណាស់ ។ បច្ចេកវិទ្យានេះជួយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សព្វផ្សាយជាសាធារណៈនូវផ្នែកមួយនៃប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងតម្លៃសមរម្យនិងអាចរកមើលបានដោយងាយ ។ ការថែរក្សាការចងចាំអំពីបក្សកុម្មុយនិស្តកាន់តែមានសារសំខាន់ទៅៗនៅខណៈដែលពេលវេលាចេះតែកន្លងផុត ។ ដោយសារភស្តុតាងរូបវ័ន្តនៃរណ្តៅសាកសពរួមនិងមន្ទីរសន្តិសុខចេះតែមានលក្ខណៈទ្រុឌទ្រោមទៅៗ ការថែរក្សា ការចងចាំអំពីរបបប៉ុលពតរបស់

សាធារណជន គឺពិតជាមានសារសំខាន់ ។ មិនតែប៉ុណ្ណោះសោកសោកនាដកម្មនៃសម័យដ៏ខ្មៅងងឹត ប្រសិនបើបំភ្លេចចោលគឺជាការល្អបំផុត ។ ប្រជាជនកម្ពុជានិងអ្នកដទៃទៀតអាចទប់ស្កាត់កុំឲ្យមានការកើតឡើងវិញនូវការរំលោភសិទ្ធិមនុស្សតាមរយៈការចងចាំ ស្វែងយល់ និងដោះស្រាយកេរដំណែលដ៏ពិបាក ដែលបន្សល់ទុកដោយអតីតកាល ។

ការសិក្សាអំពីប្រវត្តិសាស្ត្រមានសារប្រយោជន៍ណាស់ ប្រសិនបើការសិក្សាទាំងនេះត្រូវបានយកមកចែករំលែកប្រកបដោយប្រសិទ្ធភាព ហើយបើតាមពាក្យចាស់លោកពោលថា "ឮគេនិយាយមួយពាន់ដងមិនស្មើនឹងឃើញផ្ទាល់ភ្នែកម្តង" ។ អំណាចនៃការមើលឃើញផ្ទាល់នឹងភ្នែកមិនអាចមើលស្រាលបានឡើយ នៅក្នុងការថែរក្សាចងក្រងជាប្រវត្តិសាស្ត្រអំពីព្រឹត្តិការណ៍និងសម័យកាលដែលកន្លងផុតទៅ ។ ទោះជាតាមរយៈប័ណ្ណប្រកាស រូបថតនៅលើទំព័រទស្សនាវដ្តី និងសារពត៌មាន ឬតាមរយៈទំព័រអ៊ីនធើណេតក្តី បច្ចេកវិទ្យា GIS ធ្វើឲ្យលទ្ធផលនៃគម្រោងផែនទីមានលក្ខណៈងាយស្រួលក្នុងការបង្ហាញ ។ ផែនទីនេះបង្ហាញជូនជាក់ស្តែងអំពីភេរវកម្មបន្តឡើងដោយភេរវកម្មបក្សកុម្មុយនិស្តកម្ពុជា ហើយមានលក្ខណៈងាយយល់សម្រាប់អ្នកមើលគ្រប់វ័យ និងទាំងអ្នកបានរៀនសូត្រនិងមិនបានរៀនសូត្រ ។ ប្រការនេះធ្វើឲ្យបច្ចេកវិទ្យា GIS មានសារប្រយោជន៍ខ្លាំងណាស់ ពោលគឺវាជាមធ្យោបាយក្នុងការថែរក្សាការចងចាំនៃសោកនាដកម្មនៅកម្ពុជា ។ ផែនទីដែលមានទំហំធំជាងគេសព្វថ្ងៃនេះដាក់តាំងនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញ ។ ផែនទីជាច្រើនផ្ទាំងទៀតត្រូវបានចែកចាយទៅដល់ភូមិស្រុកនានាទូទាំងប្រទេសនិងបុគ្គលរស់នៅបរទេសមួយចំនួនដែលមានចំណាប់អារម្មណ៍លើបញ្ហានេះ ។ ដូចនេះបច្ចេកវិទ្យា GIS ជួយធានាបានថា ការពិតអំពីទំហំនៃការធ្វើទុក្ខទោសរបស់កម្ពុជាប្រជាធិបតេយ្យ អាចឮសុសសាយទៅដល់ប្រជាជនកម្ពុជានិងពិភពលោកទាំងមូលទៀតផង ។

ផលប្រយោជន៍ចុងក្រោយមួយទៀតគឺ GIS អាចជួយរក្សាការចងចាំអំពីសម័យប៉ុលពត តាមរយៈការជួយឲ្យអ្នកដែលមានចំណាប់អារម្មណ៍មកទស្សនាបូជនីយដ្ឋានជាច្រើននៅក្នុងប្រទេសកម្ពុជា ។ មានតែបូជនីយដ្ឋានមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានផ្សព្វផ្សាយទៅដល់សាធារណជន ប៉ុន្តែប្រការនេះមានសារសំខាន់ដែលថា បូជនីយដ្ឋានទាំងនេះមិនត្រូវបានមើលរំលង ។ ផែនទី GIS អាចបង្ហាញអំពីទីតាំងផ្លូវទៅកាន់បូជនីយដ្ឋានទាំង៧៨កន្លែងដែលស្រាវជ្រាវរកឃើញមកដល់បច្ចុប្បន្ន ។ ផែនទីនេះបង្កការងាយស្រួលដល់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងសាធារណជនឲ្យមកទស្សនាទីតាំងទាំងនេះ ។

ផែនទី GIS ដែលបង្ហាញពីបូជនីយដ្ឋានប្រល័យពូជសាសន៍នៅទូទាំងប្រទេសបង្ហាញអំពីដំណើរការបង្រួបបង្រួមផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។ ក្រៅពីរណ្តៅសាកសពរួមនិងគុកដែលបង្ហាញអំពីបទឧក្រិដ្ឋដែលមិននឹកស្មានដល់ប្រព្រឹត្តឡើងដោយបក្សកុម្មុយនិស្តកម្ពុជា គេអាចមើលឃើញនូវសក្ខីកម្មបញ្ជាក់អំពីភាពក្លាហាន និងការងាប់ងើបឡើងវិញរបស់អ្នកដែលរស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ការថែរក្សានូវការចងចាំអំពីការឈឺចាប់របស់អ្នកទាំងនេះ និងការរស់ឡើងវិញ នឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជានៅថ្ងៃអនាគត ពោលគឺសម្រាប់ប្រវត្តិវិទូស្ថាបនាឡើងវិញនូវអតីតកាលដែលមានបញ្ហារបស់ប្រទេសកម្ពុជា ។

**ចន ឆរឆីអារី និង ផេង ពង្សរ៉ាសុី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# តុលាការពិសេសនៅប្រទេសសេរ៉ាឡេអូន

## ទិដ្ឋភាពទូទៅ

ចាប់តាំងពីឆ្នាំ១៩៩១មក សង្រ្គាមស៊ីវិលដ៏ឃោរឃៅបានយាយីប្រទេសសេរ៉ាឡេអូន។ សង្រ្គាមនេះកើតឡើងរវាងរដ្ឋាភិបាលនិងរណសិរ្សរួបរួមបដិវត្ត។ ដំនោរសន្តិភាពហាក់ដូចជាចេញជារូបរាងឡើងនៅពេលដែលភាគីទាំងពីរនៅក្នុងជម្លោះចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩។ ក្រៅពីការបញ្ឈប់ការបាញ់គ្នាជាទូទៅមួយ កិច្ចព្រមព្រៀងនេះបានផ្តល់នូវការលើកលែងទោសដល់មេដឹកនាំខុទ្ទាមរណសិរ្សរួបរួមបដិវត្តឈ្មោះ ហ្វូដេ សានកូស ហើយកូនចៅរបស់គាត់បានតែងតាំងគាត់ជាអនុប្រធានាធិបតី ព្រមទាំងគាត់តែងច្បាប់សម្រាប់បង្កើតនីតិវិធីស្វែងរកការពិតនិងការបង្រួបបង្រួមជាតិផង។ នៅពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិបានបន្ថែមនូវសេចក្តីថ្លែងការណ៍មួយថា អង្គការសហប្រជាជាតិយល់ថា បញ្ញត្តិដែលចែងអំពីការលើកលែងទោសនៅក្នុងកិច្ចព្រមព្រៀងនេះមិនអាចអនុវត្តបានឡើយ។ ឧក្រិដ្ឋកម្មអន្តរជាតិដែលចែងមានដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្រ្គាម និងរាល់ការរំលោភធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ។ មិនយូរប៉ុន្មានបេសកកម្មរបស់អង្គការសហប្រជាជាតិនៅប្រទេសសេរ៉ាឡេអូនត្រូវបានបង្កើតឡើងដើម្បីប្រត្តិបត្តិកិច្ចព្រមព្រៀងសន្តិភាព ព្រមទាំងដកអាវុធ រំសាយទ័ព និងដំណើរការសមាហរណកម្ម។ “ក៏ប៉ុន្តែការវាយប្រយុទ្ធគ្នារវាងរដ្ឋាភិបាល និងកងទ័ពពួកខុទ្ទាមបន្តការរំលោភទៅលើកិច្ចព្រមព្រៀងនេះ។ រណសិរ្សរួបរួមបដិវត្តបានវាយប្រហារមកលើកងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ជាពិសេសបានចាប់ពង្រត់កងរក្សាសន្តិភាពចំនួនប្រាំរយនាក់ ហើយប្រការនេះបានពង្រឹងដំហរសហគមន៍អន្តរជាតិ និងជំរុញបន្ថែមទៀតឲ្យមានការស្តារឡើងវិញនូវធម្មាធិបតេយ្យនៅក្នុងប្រទេសសេរ៉ាឡេអូនតាមរយៈមធ្យោបាយនៃការប្រើយុត្តិធម៌បែបព្រហ្មទណ្ឌ។ ក្រោយពីមានការសុំជំនួយពីសំណាក់រដ្ឋាភិបាលសេរ៉ាឡេអូនក្នុងការកាត់ទោសជនទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានដាក់សំណើទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិឲ្យចរចាជាមួយសេរ៉ាឡេអូន ក្នុងគោលបំណងឈានដល់កិច្ចព្រមព្រៀងមួយក្នុងការបង្កើតតុលាការពិសេសដើម្បីកាត់សេចក្តីអំពើឃោរឃៅ» ។

## ការចរចាអំពីការបង្កើតតុលាការពិសេស

ច្បាប់របស់ប្រទេសសេរ៉ាឡេអូនមិនបញ្ចូលឧក្រិដ្ឋកម្មអន្តរជាតិទេ ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម ហើយក្រោយពីមានជម្លោះប្រដាប់អាវុធអស់មួយទសវត្សរ៍មក ប្រទេសសេរ៉ាឡេអូនគ្មានថវិកាគ្រប់គ្រាន់ក្នុងការបង្កើតតុលាការមួយដើម្បីកាត់សេចក្តីនិងអនុវត្តច្បាប់ទៅតាមបទដ្ឋានអន្តរជាតិឡើយ។ ដូចនេះប្រទេសសេរ៉ាអេឡូនត្រូវការជំនួយពីអន្តរជាតិដើម្បីធានាឲ្យប្រាកដនូវភាពត្រឹមត្រូវនិងភាពគួរឲ្យទុកចិត្តបាននៃដំណើរការនីតិវិធីជំនុំជម្រះក្តី។ ប៉ុន្តែសហគមន៍អន្តរជាតិមានភាពស្ទាក់ស្ទើរមិនចង់បង្កើតតុលាការពិសេសមួយទៀតដោយសារត្រូវចំណាយថវិកាច្រើន។

នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០០ អគ្គលេខាធិការអង្គការសហប្រជាជាតិបានរាយការណ៍ជូនក្រុមប្រឹក្សាសន្តិសុខអំពីការចរចារបស់លោកជាមួយរដ្ឋាភិបាលសេរ៉ាឡេអូន ហើយភ្ជាប់មកជាមួយនូវសេចក្តីព្រាងច្បាប់មួយ (សេចក្តីព្រាងច្បាប់តុលាការពិសេស) និងកិច្ចព្រមព្រៀងជាមួយប្រទេសសេរ៉ាឡេអូន។ ក្រុមប្រឹក្សាសន្តិសុខទទួលយកនូវសំណើនេះមួយភាគធំ ប៉ុន្តែស្នើឲ្យមានការផ្លាស់ប្តូរមួយចំនួនទាក់ទងនឹងយុត្តាធិការលើរូបបុគ្គលនៃអង្គតុលាការ ទំហំតុលាការ និងការទ្រទ្រង់ថវិកាសម្រាប់ចំណាយ។ ជាលទ្ធផល ទស្សនៈថ្មីៗនេះដែលចង់ឲ្យមានតុលាការ

គឺចង់ឲ្យមានតុលាការដែលមានលក្ខណៈអន្តរជាតិ ស្ថិតនៅដាច់ពីប្រព័ន្ធតុលាការសេរ៉ាឡេអូន ដែលតុលាការទាំងពីរនេះនឹងត្រូវគ្រប់គ្រងដោយអង្គការសហប្រជាជាតិផង និងប្រទេសសេរ៉ាឡេអូនផង ។ ផ្អែកតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១៣១៥ អនុម័តនៅឆ្នាំ២០០០ លក្ខន្តិកៈច្បាប់នេះកំណត់កាត់សេចក្តីទៅលើជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុត ជាពិសេសមេដឹកនាំ (បានប្រព្រឹត្តឧក្រិដ្ឋកម្ម) ដែលគំរាមកំហែងដល់ការបង្កើតនិងប្រតិបត្តិនូវដំណើរការសន្តិភាពនៅប្រទេសសេរ៉ាអេឡូន ។ គេរំពឹងថាតុលាការនេះនឹងវិនិច្ឆ័យទោសបុគ្គលដែលមានការទទួលខុសត្រូវខ្ពស់បំផុតតែពី២៥ទៅ៣០នាក់ប៉ុណ្ណោះ រួមទាំងយុវជននិងមនុស្សពេញវ័យ ។ តាមការវិវឌ្ឍន៍ថ្មីៗនេះបង្ហាញថា តុលាការនេះមានយុត្តាធិការដោះស្រាយ "រាល់ការប្រព្រឹត្តហួសព្រំដែនមកលើកងរក្សាសន្តិភាព និងបុគ្គលិកដែលមានភារកិច្ចប្រហាក់ប្រហែលនេះនៅក្នុងប្រទេសសេរ៉ាឡេអូន" នៅក្នុងករណីដែលរដ្ឋបញ្ជូនបុគ្គលិកមកនោះ គ្មានឆន្ទៈឬពិតជាគ្មានលទ្ធភាពធ្វើការស៊ើបអង្កេត ។ កិច្ចព្រមព្រៀងទទួលស្គាល់ការទទួលខុសត្រូវជាចម្បងរបស់រដ្ឋដែលបញ្ជូនបុគ្គលិកមកឲ្យអប់រំកងរក្សាសន្តិភាពរបស់ខ្លួន ចំណែកឯការអនុវត្តទៅតាមយុត្តាធិការរបស់តុលាការពិសេសត្រូវតែទទួលការអនុញ្ញាតពីក្រុមប្រឹក្សាសន្តិសុខតាមសេចក្តីស្នើរបស់រដ្ឋណាមួយ ។

តុលាការពិសេសនេះមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភធ្ងន់ធ្ងរទៅលើមាត្រា៣ និងពិធីសារបន្ថែមទីII ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងបទបញ្ញត្តិមួយចំនួន សម្រាំងចេញពីច្បាប់របស់ប្រទេសសេរ៉ាឡេអូនផ្ទាល់ ។ តុលាការនេះមានចៅក្រមនិងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ ។ យុត្តាធិការមានវិសាលភាពទៅលើឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តចាប់តាំងពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដែលជាពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង *Abidjan Accords* ដែលជាកិច្ចព្រមព្រៀងសន្តិភាពទូលំទូលាយមុនដំបូងគេបង្អស់រវាងរដ្ឋាភិបាលសេរ៉ាឡេអូននិងរណសិរ្សរួបរួមបដិវត្ត ។ ដោយសារជម្លោះកំពុងតែបន្តទៅមុខនាំឲ្យកាលបរិច្ឆេទនៅជាប់ៗគ្នា គ្មានដាច់ ។

តុលាការពិសេសនេះមានយុត្តាធិការស្របគ្នាជាមួយនិងមានសិទ្ធិទៅលើតុលាការសេរ៉ាឡេអូន ។ តាមមាត្រា៨(២) តុលាការនេះមានអំណាចធ្វើសេចក្តីស្នើឲ្យតុលាការជាតិសេរ៉ាឡេអូនព្រមតាមដែនសមត្ថកិច្ចរបស់ខ្លួននៅរាល់ដំណាក់កាលជំនុំជម្រះក្តីណាមួយ ។ ឧបសគ្គចំពោះការវិនិច្ឆ័យក្តីដែលបង្កឡើងដោយបទបញ្ញត្តិដែលចែងអំពីការលើកលែងទោសនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពនោះត្រូវបានដកចេញដោយសាររដ្ឋាភិបាលសេរ៉ាឡេអូនបានព្រមព្រៀងទៅលើបញ្ញត្តិមួយនៅក្នុងច្បាប់នោះដែលថាការលើកលែងទោសបែបនេះមិនរារាំងដល់ដំណើរការកាត់សេចក្តីឡើយ ។

នេះគឺជាតុលាការអន្តរជាតិដែលនឹងបង្កើតឡើងនៅពេលមានថវិកាគ្រប់គ្រាន់ដែលត្រូវផ្តល់ដោយថវិកាវិភាគទានស្ម័គ្រចិត្ត ។ បើផ្អែកទៅលើការចូលរួមវិភាគទានពីសំណាក់រដ្ឋនីមួយៗដើម្បីបង្កើតនិងដំណើរការតុលាការទាំងមូលគឺជាការប្រថុយប្រថាន ហើយអាចនឹងធ្វើឲ្យមានគ្រោះថ្នាក់ដល់ការបង្កើតតុលាការនេះផង ។ ជាលទ្ធផលនៃការសម្របសម្រួលរវាងក្រុមប្រឹក្សាសន្តិសុខនិងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានផ្តល់អនុសាសន៍ថាតុលាការនេះនឹងត្រូវផ្តល់ថវិកាដោយផ្អែកទៅលើការវាយតម្លៃជាក់ស្តែងនោះ កិច្ចព្រមព្រៀងនេះនឹងមិនចូលជាធរមានឡើយលុះត្រាណាតែអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិបានទទួលនូវវិភាគទានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ការបង្កើតតុលាការនេះនិងគ្រប់គ្រាន់សម្រាប់ដំណើរការប្រព្រឹត្តិទៅសម្រាប់រយៈពេល១២ខែ ក៏ដូចជាការសន្យានានាដែលមានតម្លៃស្មើនឹងការចំណាយដែលគ្រោងទុកសម្រាប់ដំណើរការ២៤ខែក្រោយមកទៀត ។ ថវិកាប៉ាន់ស្មានសម្រាប់ដំណើរការតុលាការពិសេសនេះសម្រាប់រយៈពេលជាង៣ឆ្នាំ គឺមានចំនួន១១៤លានដុល្លារអាមេរិកដែលឥឡូវនេះត្រូវបន្ថយមកត្រឹម១៦,៨លានតែប៉ុណ្ណោះសម្រាប់ការបង្កើតនិងដំណើរការប្រព្រឹត្តិទៅក្នុងឆ្នាំដំបូងនិង៤០លានដុល្លារសម្រាប់ពីរឆ្នាំបន្ទាប់មកទៀត ។

### រចនាសម្ព័ន្ធរបស់តុលាការពិសេស

តុលាការពិសេសរបស់សេរ៉ាឡេអូនត្រូវបានបង្កើតឡើង

ដោយសន្និសញ្ញារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលសេរ៉ាឡេអូន ។ តុលាការនេះមិនចូលក្នុងប្រព័ន្ធយុត្តិធម៌ដែលមានស្រាប់របស់ប្រទេសសេរ៉ាឡេអូនដែលជាផ្នែកមួយនៃបេសកកម្មថែរក្សាសន្តិភាព ហើយក៏មិនមែនបង្កើតឡើងជាស្ថាប័នក្រោមចំណុះរបស់អង្គការសហប្រជាជាតិដែរ ។ ផ្ទុយមកវិញ តុលាការនេះគឺជា “តុលាការពិសេសដែលផ្អែកលើសន្និសញ្ញាដែលមានយុត្តាធិការនិងសមាសភាពចម្រុះ” ។ ផលប្រយោជន៍ជាក់ស្តែងភ្លាមៗនៃយុត្តាធិការនិងសមាសភាពបែបនេះគឺចៀសវាងបញ្ហានានាបណ្តាលមកពីប្រព័ន្ធយុត្តិធម៌ដែលមានលក្ខណៈទន់ខ្សោយ ។

តុលាការពិសេសនេះមានចៅក្រមយ៉ាងតិចចំនួន៨រូប (យ៉ាងច្រើន១១រូប ប្រសិនបើតម្រូវឲ្យមានអង្គជំនុំជម្រះទីពីរទៅតាមករណីជាក់ស្តែង) ដែលចៅក្រមទាំងនេះជាចៅក្រមអង្គុយនៅអង្គជំនុំជម្រះនិងសាលាឧទ្ធរណ៍ ។ មាត្រា២០ មានបំណងធានាឲ្យមានការអនុវត្តដូចគ្នាទៅនឹងករណីយុត្តិសាស្ត្រ ដោយតម្រូវឲ្យសាលាឧទ្ធរណ៍ពិចារណានូវករណីយុត្តិសាស្ត្រនៃសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌពិសេសអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ។ គ្រប់អង្គជំនុំជម្រះដំបូងមានចៅក្រមបីរូប ដែលពីររូបតែងតាំងដោយអគ្គលេខាធិការដែលផ្តោតសំខាន់ទៅលើចៅក្រមមកពីប្រទេសជាសមាជិកនៃសហគមន៍សេដ្ឋកិច្ចនៃបណ្តារដ្ឋនៅអាហ្វ្រិកខាងលិច និងរដ្ឋស្ថិតក្រោមអាណានិគមអង់គ្លេស ។ ចៅក្រមដទៃទៀតតែងតាំងដោយរដ្ឋាភិបាលសេរ៉ាឡេអូនដែលមិនតម្រូវថា សេរ៉ាឡេអូនត្រូវតែតែងតាំងចៅក្រមជាជនជាតិរបស់ខ្លួននោះទេ ។ សាលាឧទ្ធរណ៍មានចៅក្រមប្រាំរូបដែលពីររូបតែងតាំងដោយសេរ៉ាឡេអូនបីរូបតែងតាំងដោយអគ្គលេខាធិការ ។ ដូចនេះតុលាការពិសេសនេះគ្រប់គ្រងដោយអង្គការសហប្រជាជាតិ ។

ព្រះរាជអាជ្ញានៃតុលាការពិសេសត្រូវតែងតាំងដោយអគ្គលេខាធិការ ចំណែកឯរដ្ឋាភិបាលសេរ៉ាឡេអូនត្រូវតែងតាំងព្រះរាជអាជ្ញារង ដោយមានការពិគ្រោះពិភាក្សាជាមួយអង្គការសហប្រជាជាតិ ។ ដូចគ្នានេះដែរ ក្រឡាបញ្ជីត្រូវមានសញ្ជាតិអន្តរជាតិ ។

**ច្បាប់សារធាតុ**

មាត្រា២ចែងអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានធាតុផ្សំដូចដែលមានចែងនៅក្នុងច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ប៉ុន្តែមានលក្ខណៈប្លែកៗគ្នានៅពេលតែមួយ ។ ឧទាហរណ៍តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដាចែងថា “បទល្មើសរំលោភ” គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏ធ្ងន់ធ្ងរមួយ ។ មាត្រា២នៃច្បាប់របស់តុលាការពិសេសមានលក្ខណៈកណ្តាលរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងពីរនិងតុលាការព្រហ្មទណ្ឌអន្តរជាតិអាយ.ស៊ី.ស៊ី ហើយចាត់ទុក “បទល្មើសរំលោភ ទាសភាពខាងផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការបង្ខំឲ្យមានផ្ទៃពោះ និងអំពើហិង្សាខាងផ្លូវភេទ”ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏ធ្ងន់ធ្ងរ ។ មិនដូចជាច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាយ.ស៊ី.ស៊ីនោះទេ “ទម្រង់ផ្សេងៗទៀតនៃអំពើហិង្សាខាងផ្លូវភេទ”នៅទីនេះមិនចាំបាច់មានភាពធ្ងន់ធ្ងរដូចជាបទឧក្រិដ្ឋដែលរាយនៅខាងដើមនោះទេហើយ“អំពើអមនុស្សធម៌ផ្សេងទៀត”ក៏មិនចាំបាច់មានលក្ខណៈធ្ងន់ធ្ងរដូចជាបទល្មើសដែលលើកយកមកនេះដែរ ។ បទឧក្រិដ្ឋ“ដែលមិនឃើញលើកឡើង”ដូចជាការធ្វើឲ្យលែងមានកូនដោយបង្ខំ ការជម្លៀសប្រជាជនដោយបង្ខំ និងការបំបាត់សិទ្ធិសេរីភាពដែលជាការរំលោភទៅលើវិធានជាសារវន្តនៃច្បាប់អន្តរជាតិ ដូចដែលចែងនៅក្នុងច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនោះ អាចត្រូវបានលើកជាឧទាហរណ៍ថាត្រូវបានក្តោបដោយប្រជុំសព្ទបច្ចេកទេសដែលពង្រីកន័យកាន់តែទូលំទូលាយទៅលើពាក្យថា “រាល់ទម្រង់ផ្សេងៗទៀតនៃអំពើហិង្សាខាងផ្លូវភេទ” ឬ “អំពើអមនុស្សធម៌ផ្សេងៗទៀត” ។ ជាការស្របទៅនឹងសភាពបច្ចុប្បន្ននៃច្បាប់ទម្លាប់អន្តរជាតិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលែងតម្រូវឲ្យមានធាតុផ្សំសម្ព័ន្ធភាពប្រដាប់អាវុធ ឬធាតុផ្សំនៃការរើសអើងទៀតហើយ ។

ដោយធ្វើការប្រៀបធៀបជាមួយនឹងមាត្រា៨នៃច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា នោះឃើញថា មាត្រា៣បានចែងឲ្យមានការកាត់សេចក្តីទៅលើការរំលោភនានាទៅលើមាត្រា៣រួម និងពិធីសារបន្ថែមII ។ របាយការណ៍

របស់សេរ៉ាឡេអូនបានបញ្ចូលទាំងមាត្រា៣និងមាត្រា៤នៃពិធីសារបន្ថែម II នៅពេលដែលប្រព្រឹត្តឡើងនៅក្នុងពេលមានជម្លោះមិនមានចរិតជាអន្តរជាតិ ដូចដែលបានចាត់ទុកជាយូរណាស់មកហើយថាជាច្បាប់ទម្លាប់អន្តរជាតិ ហើយចាប់តាំងពីពេលបង្កើតឡើងមក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដាត្រូវបានទទួលស្គាល់ថាវាតម្រូវជាលក្ខណៈប្រពៃណីឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ។ គួរកត់សម្គាល់ថាបទល្មើសនានាដែលបានលើកយកមកនិយាយពេលនេះមិនទូលំទូលាយទេ ហើយឧក្រិដ្ឋកម្មផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងប្រទេសសេរ៉ាឡេអូន ដូចជាការធ្វើឲ្យទៅជាទាសករនោះមិនត្រូវបានបដិសេធដោយមាត្រា៣ឡើយ ។

មាត្រា៤មានលក្ខណៈមិនធម្មតា ។ មានបទឧក្រិដ្ឋបីតែប៉ុណ្ណោះដែលស៊ីគ្នាទៅនឹងសភាពការណ៍ជាក់ស្តែងរបស់សេរ៉ាឡេអូននឹងត្រូវវិនិច្ឆ័យក្តីថាជា«ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ» ជាជាងថា ជាច្បាប់ដែលត្រូវបានប្រើប្រាស់ជាទម្លាប់និង (ឬ) ទម្លាប់នៃការធ្វើសង្គ្រាមដែលការកាត់សេចក្តីជាអន្តរជាតិទៅលើឧក្រិដ្ឋកម្មសង្គ្រាមនៅរូវិមបឹកត្រូវបានយកជាមូលដ្ឋានៈ ក) ការវាយប្រហារមកលើប្រជាជនស៊ីវិលជារួមឬជាបុគ្គលដែលមិនចូលរួមដោយផ្ទាល់នៅក្នុងជម្លោះ ។ ខ) ការវាយប្រហារមកលើបុគ្គលិកថែរក្សាសន្តិភាព ដែលចូលរួមនៅក្នុងការផ្តល់ជំនួយមនុស្សធម៌ឬបេសកកម្មថែរក្សាសន្តិភាព ដរាបណាអ្នកទាំងនោះមានសិទ្ធិទទួលការគាំពារដូចដែលជនស៊ីវិលមានក្រោមច្បាប់អន្តរជាតិទាក់ទងនឹងជម្លោះប្រដាប់អាវុធ ។ គ) កំណែន ឬបញ្ចូលកុមារក្រោមអាយុ១៥ឆ្នាំ ឲ្យចូលបម្រើកងទ័ពឬក្រុមនានា ឬប្រើប្រាស់កុមារទាំងនោះឲ្យចូលរួមយ៉ាងសកម្មនៅក្នុងជម្លោះ ។

របាយការណ៍របស់សេរ៉ាឡេអូនបាននិយាយដល់កម្រិតមួយ ដើម្បីឲ្យហេតុផលសម្រាប់បញ្ចូលការវាយប្រហារមកលើកងរក្សាសន្តិភាពនិងការប្រើកុមារធ្វើជាយុទ្ធជន ប៉ុន្តែមិនបានពន្យល់អំពីការមិនរាប់បញ្ចូលនូវការរំលោភផ្សេងៗទៀតដែលទទួលស្គាល់ថាមានលក្ខណៈជាទម្លាប់ ហើយដែលប្រព្រឹត្តយ៉ាងច្រើននៅក្នុងប្រទេសសេរ៉ាឡេអូន ដូចជាការរំលោភលើផ្លូវភេទនិងទាសភាព ។ ទស្សនាទានដែលយល់ឃើញថា ការវាយប្រហារមកលើកងកម្លាំងថែរក្សាសន្តិភាពថាជាឧក្រិដ្ឋកម្មអន្តរជាតិគឺបានមកពីអនុសញ្ញាឆ្នាំ១៩៩៤ស្តីអំពីសុវត្ថិភាពរបស់អង្គការសហប្រជាជាតិនិងបុគ្គលិកនៅក្រោមបង្គាប់ ហើយត្រូវបានកំណត់ថាមានទោសនៅក្នុងមាត្រា៨២(ខ) (iii) នៃច្បាប់របស់តុលាការ


«ពួកឧក្រិដ្ឋជនវាទាំ នឹងជម្លៀសពួកខ្ញុំចេញនៅថ្ងៃ៧ មករា ៧៩ តាមបំការវដូងឆ្លងកាត់គ្រាប់ផ្លោង»
វិចិត្រករ ៖ ប៊ូ ម៉េង (អតីតជនរងគ្រោះនៅមន្ទីរស-២១)

ព្រហ្មទណ្ឌអន្តរជាតិអាយ.ស៊ី.ស៊ី ។ កងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសសេរ៉ាឡេអូនត្រូវបានវាយប្រហារជាញឹកញាប់ ហើយត្រូវបានចាប់ជាចំណាប់ខ្មាំងថែមទៀត ។ យោងតាមលោកអគ្គលេខាធិការកងកម្លាំងរក្សាសន្តិភាពត្រូវបានគាំពារជាស្រេចទៅហើយ ដោយច្បាប់ទម្លាប់អន្តរជាតិដែលមានស្រាប់ដែលហាមប្រាមរាល់ការវាយប្រហារមកលើជនស៊ីវិលនិងជនដែលនៅក្រៅវង្វង់ការប្រយុទ្ធ ។ ការហាមប្រាមនេះមានសុពលភាពចាប់តាំងពីការអនុម័តច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិអាយ.ស៊ី.ស៊ីមកម្ល៉េះ ។ លោកអគ្គលេខាចាត់ទុកកងកម្លាំងថែរក្សាសន្តិភាពថាជាជនស៊ីវិលមិនមែនជាកងកម្លាំងប្រដាប់អាវុធឡើយ ។ ការវាយតម្លៃរបស់លោកអគ្គលេខាគឺថាកងរក្សាសន្តិភាពនៅប្រទេសសេរ៉ាឡេអូន ត្រូវបានចាត់ទុកថា "ជាក្រុមស្ថិតនៅជាមួយក្រុមស៊ីវិលដែលត្រូវច្បាប់គាំពារជាទូទៅដែលដោយសារតែបេសកកម្មមនុស្សធម៌ ឬរក្សាសន្តិភាព សមតែទទួលបាននូវការគាំពារពិសេស... (ប៉ុន្តែប្រការនេះ) មិនមានន័យថា ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាងជនស៊ីវិលនៅក្នុងកាលៈទេសៈស្រដៀងគ្នា ហើយមិនគួរតម្រូវឲ្យមានទោសបញ្ញត្តិធ្ងន់ធ្ងរជាងគ្នាឡើយ" ។

មានទិដ្ឋភាពពីរទាក់ទងនឹងការជ្រើសរើសនិងប្រើកុមារជាកងទ័ព គឺលក្ខណៈគួរឲ្យខ្លាចនៃការវាយប្រយុទ្ធគ្នានៅសេរ៉ាឡេអូនដែលជាកិច្ចការត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហាកុមារដែលត្រូវបានបង្ខឹកឲ្យប្រព្រឹត្តអំពើឃោរឃៅទៅលើអ្នកផ្សេងទៀត ហើយចំណុចទីពីរគឺកិច្ចការដោះស្រាយជាមួយអ្នកដែលបង្ខឹកកុមារឲ្យឃោរឃៅតាមរយៈការចាប់ពង្រត់ឬការកេណ្ឌទាហានដោយបង្ខំ រួចហើយប្រែក្លាយកុមារទាំងនោះជាម៉ាស៊ីនសម្លាប់មនុស្ស ។ បញ្ហាដែលថាយុទ្ធជនវ័យក្មេងមានទោសផងនិងជាជនរងគ្រោះផងនោះ ត្រូវបានចែងនៅក្នុងច្បាប់តុលាការពិសេសនេះដែលនឹងលើកយកពិភាក្សានៅខាងក្រោម ទាក់ទងនឹងការទទួលខុសត្រូវជាបុគ្គល ។ ជោគជ័យមួយក្នុងចំណោមជោគជ័យដែលសម្រេចបានដោយច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺការចាត់ទុកជាឧក្រិដ្ឋសង្គ្រាមនូវការ "កេណ្ឌឬយកចូលជាកងកម្លាំងប្រដាប់អាវុធជាតិ ចំពោះបុគ្គលដែលមានអាយុក្រោម១៥ឆ្នាំ និងការប្រើកុមារទាំងនោះឲ្យចូលរួមយ៉ាងសកម្មនៅក្នុងជម្លោះនានា ។ សេចក្តីព្រាងដំបូងបង្អស់របស់លោកអគ្គលេខាធិការដែលផ្អែកលើចម្ងល់របស់លោកថាតើវាជាអំពើដែលទទួលស្គាល់ថាជាឧក្រិដ្ឋកម្មសង្គ្រាមដែលនាំឲ្យមានការទទួលខុសត្រូវជាបុគ្គលឬយ៉ាងណានោះបានតម្រូវថាកុមារអាយុក្រោម១៥ឆ្នាំត្រូវតែទទួលរងនូវការចាប់ពង្រត់និងចាប់ឲ្យបម្រើគោលដៅចូលរួមដោយសកម្មដោយការបង្ខំនៅក្នុងជម្លោះនានា ។ ក្មេងស្រីដែលត្រូវចាប់ពង្រត់ និងឲ្យធ្វើជាទាសករទោះជាឲ្យបម្រើការសប្បាយរបស់ទាហាន ឬទុកសម្រាប់បម្រើកិច្ចការប្រចាំថ្ងៃ ដូចជាកុមារដែលត្រូវបានប្រើឲ្យធ្វើទង្វើមានគ្រោះថ្នាក់ ប៉ុន្តែមិនមែនមែនជាតួនាទីយោធាដូចជាការលីសែងអាវុធគ្រាប់រំសេវជាដើមគឺមិនត្រូវបានរាប់បញ្ចូលនៅក្នុងនិយមន័យនេះឡើយ ។ ក្រុមប្រឹក្សាសន្តិសុខបានផ្លាស់ប្តូរចំណុចនេះដើម្បីឲ្យស្របទៅតាមអ្វីដែលខ្លួនចាត់ទុកថាជា "ទន្ឡ្ញឹករណ៍ច្បាប់ដែលនៅជាធរមានក្នុងឆ្នាំ១៩៩៦ ហើយដែលបានទទួលយកដោយសហគមន៍អន្តរជាតិ ។ ជាលទ្ធផលមាត្រា៤(គ) ឥឡូវនេះអនុញ្ញាតឲ្យមានការកាត់សេចក្តីទៅលើជនទាំងឡាយដែលកេណ្ឌកុមារក្រោមអាយុ១៥ឆ្នាំឬយកកុមាចូលធ្វើជាកងប្រដាប់អាវុធឬក្រុមប្រដាប់អាវុធឬប្រើប្រាស់កុមារទាំងនោះឲ្យចូលរួមយ៉ាងសកម្មនៅក្នុងជម្លោះ ។

បណ្តុំបទល្មើសចុងក្រោយដែលអាចកាត់សេចក្តីបាននៅតុលាការពិសេស គឺជាឧក្រិដ្ឋកម្មទាំងឡាយស្ថិតនៅក្រោមច្បាប់របស់សេរ៉ាឡេអូន ពោលគឺបទល្មើសរំលោភលើផ្លូវភេទមកលើស្ត្រីវ័យក្មេង ដែលទាញចេញមកពីច្បាប់ឆ្នាំ១៩២៦ ស្តីអំពីការទប់ស្កាត់អំពើឃោរឃៅមកលើកុមារ ព្រមទាំងបទល្មើសទាំងឡាយដែលពាក់ព័ន្ធទៅនឹងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយឥតគិតក្រែងក្រោមច្បាប់ស្តីអំពីការបង្កព្យសនកម្មដោយគំនិតព្យាបាទតាក់តែងនៅឆ្នាំ១៨៥១ ។ ការងាកមករកច្បាប់ក្នុងស្រុកគឺជាអនុសាសន៍របស់ក្រុមប្រឹក្សាសន្តិសុខតាមរយៈសេចក្តីសម្រេចលេខ១៣១៥ ដើម្បីគ្របដណ្តប់លើស្ថានការណ៍ដែលអាចមានលក្ខណៈគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់តាមច្បាប់អន្តរជាតិ ។

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្រោមច្បាប់របស់តុលាការពិសេស ដែលមានចែងនៅត្រង់មាត្រា៦

មានលក្ខណៈដូចគ្នាបេះបិទទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៃច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីដែរ ។ មានលក្ខណៈដូចគ្នាដែរគឺបទបញ្ញត្តិនានារបស់តុលាការយូហ្គោស្លាវីស្តីអំពីសមត្ថកិច្ចរបស់មន្ត្រីការទទួលខុសត្រូវជាលក្ខណៈទទួលបទបញ្ជាពីថ្នាក់លើការមិនជម្រះទោសពីរដងលើបទល្មើសតែមួយ និងសិទ្ធិរបស់ជនជាប់ចោទ ។ ប៉ុន្តែតាមរយៈការដកស្រង់ពីច្បាប់របស់ប្រទេសសេរ៉ាឡេអូន ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលទាក់ទងនឹងបទឧក្រិដ្ឋទាំងនោះគឺត្រូវសម្រេចដោយអនុលោមទៅតាមច្បាប់ជាតិ ។ មិនដូចជាគោលការណ៍ "បទល្មើសធ្ងន់ធ្ងរនិងអង្គជំនុំជម្រះវិសាមញ្ញ"ទេ នៅទីនេះគឺគេទទួលស្គាល់យ៉ាងត្រឹមត្រូវថាការអនុវត្តប្រព័ន្ធច្បាប់ទាំងពីរនេះតម្រូវថាធាតុផ្សំនៃបទល្មើសត្រូវគ្រប់គ្រងដោយអង្គច្បាប់ពីរ ហើយថាប្រការនេះក៏គួរតែមានចែងនៅក្នុងវិធាននៃនីតិវិធីផង ។ ហេតុដូចនេះទោះបីជាវិធាននៃនីតិវិធីនិងវិធាននៃភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវអនុវត្តដោយមានការកែប្រែតាមការចាំបាច់ចំពោះនីតិវិធីជាក់ស្តែងនៅតុលាការពិសេសក៏ដោយ ក៏ចៅក្រមមានអំណាចធ្វើវិសោធនកម្ម ឬអនុម័តយកនូវវិធាននានាទៅតាមតម្រូវការចាំបាច់របស់តុលាការ ហើយអាចដកទៅប្រើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៦៥របស់សេរ៉ាឡេអូនដែរ ។

ដោយសារមានអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំដែលប្រព្រឹត្តឡើងដោយយុទ្ធជនស្ថិតក្នុងវ័យកុមារ ច្បាប់នេះមានចែងនូវបញ្ញត្តិជាច្រើនទាក់ទងនឹងយុត្តិធម៌សម្រាប់យុទ្ធជនវ័យក្មេង ។ យោងតាមលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានឲ្យដឹងថាច្បាប់របស់តុលាការពិសេសចាំបាច់ត្រូវតែតម្រូវទៅតាមបំណងប្រាថ្នាជាក់លាក់របស់រដ្ឋាភិបាលសេរ៉ាឡេអូននិងសង្គមស៊ីវិលទាក់ទងនឹងយុទ្ធជនវ័យក្មេងដែលត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនជាមួយនឹងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិដែលបានជំទាស់ទៅនឹងការដាក់ឲ្យទទួលខុសត្រូវតាមផ្លូវតុលាការសម្រាប់កុមារក្រោមអាយុ១៨ឆ្នាំ ដោយខ្លាចក្រែងថាដំណើរការប្តឹងពីបទអាជ្ញានេះជាការប្រថុយគ្រោះថ្នាក់ប៉ះពាល់ដល់កម្មវិធីស្តារនីតិសម្បទារបស់យុទ្ធជនស្ថិតក្នុងកុមារភាព ។ មានជម្រើសមួយចំនួនត្រូវបានយកមកពិចារណាទាក់ទងនឹងយុត្តិធម៌សម្រាប់យុទ្ធជនវ័យក្មេង ប៉ុន្តែជម្រើសមួយដែលត្រូវបានអនុម័តយកដោយតុលាការពិសេសនេះផ្តល់នូវយុត្តាធិការទៅលើយុវជនវ័យក្មេងក្នុងចន្លោះអាយុពី១៥ឆ្នាំទៅ១៨ឆ្នាំ ។ ដូចនេះមានតែក្នុងករណីធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់តែប៉ុណ្ណោះដែលយុទ្ធជនវ័យ ក្មេងនោះត្រូវរួមបញ្ចូលទៅក្នុងក្របខ័ណ្ឌដែលច្បាប់កំណត់ថា "មានការទទួលខុសត្រូវខ្ពស់បំផុត" ចំពោះការសម្លាប់រង្គាលនៅសេរ៉ាឡេអូន ។ គេមានជំនឿថាប្រសិនបើមានគឺមានតែយុទ្ធជនវ័យក្មេងតែមួយចំនួនប៉ុណ្ណោះដែលនឹងប្រឈមមុខនឹងការចោទប្រកាន់និង ជំនុំជម្រះក្តីនៅមុខតុលាការ ។ ក្រុមប្រឹក្សាសន្តិសុខបានសង្កត់ធ្ងន់ថា ស្ថាប័នផ្សេងទៀតដូចជាគណៈកម្មាធិការស្វែងរកការពិតជាដើមគឺមានលក្ខណៈស័ក្តិសមនឹងធ្វើការដោះស្រាយបញ្ហាយុវភាពនេះ ។

នៅពេលមានការកាត់សេចក្តី ទៅលើយុទ្ធជនវ័យក្មេង មាត្រា៧តម្រូវថា បញ្ហានេះត្រូវដោះស្រាយទៅតាមលក្ខណៈកុមារ ដោយអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិជាពិសេសសិទ្ធរបស់កុមារ ។ ព្រះរាជអាជ្ញាមានភារកិច្ចធានាឲ្យប្រាកដថាកម្មវិធីស្តានីតិសម្បទាកុមារមិនត្រូវឲ្យមានការប៉ះពាល់ឡើយ ហើយថា នៅពេលមានលក្ខណៈសមរម្យ គួរតែមានជម្រើសដែលសមស្រប ពោលគឺដកទៅរកយន្តការស្វែងរកការពិតនិងផ្សះផ្សា ។ យុវជនវ័យក្មេងនឹងមិនត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារទេ ប្រសិនបើរកឃើញថាមានកំហុសប៉ុន្តែអាចត្រូវទទួលរងនូវវិធានការផ្សេងៗដូចជាដីកាអប់រំនិងគ្រប់គ្រងដីកាសេវាកម្មសហគមន៍ដីកាប្រឹក្សាយោបល់និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ អង្គជំនុំជម្រះពិសេសមួយដោះស្រាយចំពោះបញ្ហាយុវជនវ័យក្មេងនេះក៏ត្រូវបង្កើតឡើងជាមួយនឹងចៅក្រមអង្គយយ៉ាងហោចណាស់មួយរូបនិងចៅក្រមជំនួសមួយរូបដែលមានជំនាញឯកទេសលើបញ្ហានេះ ។ អាចថាអង្គជំនុំជម្រះនេះអាចប្រព្រឹត្តទៅតាមនីតិវិធីផ្សេងៗគ្នា ដែលយកយុត្តិធម៌សម្រាប់យុវជនវ័យក្មេងមកគិតជាធំ ។ អ្នកដែលមានជំនាញឯកទេសពិតប្រាកដត្រូវតែជ្រើសរើសឲ្យមកធ្វើការវិនិច្ឆ័យក្តីបែបនេះ ។ **ស៊ូហ្សាណា លីនតុន**

# ក្នុងការធ្វើដំណើរឆ្ពោះទៅមុខ ត្រូវខាកមើលក្រោយ



គ្រួសារប្រជាជនមូលដ្ឋាននៅក្នុងតំបន់២៥ ឆ្នាំ១៩៧៧

ក្រោយពេលដែលជម្លោះ អំពើហិង្សា និងការរំលោភទៅលើសិទ្ធិមនុស្សស្ងប់ស្ងាត់ទៅ មនុស្សគ្រប់គ្នាតែងតែចង់ឲ្យអ្នកដែលស្រលាញ់សន្តិភាពឱបក្រសោបយកនូវគំនិតនៃការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ទំនោរបែបនេះបានក្លាយទៅជាការទាស់ទែងខ្វែងគំនិតគ្នានៅក្នុងតំបន់មួយចំនួន មិនមែនមកអំពីមូលហេតុនៃអត្ថន័យពិតប្រាកដនៃសម្តីខាងលើទេ ប៉ុន្តែដោយសារវាត្រូវបានប្រើប្រាស់ដោយជនដែលមានគំនិតមិនល្អនិងអតីតកាលដ៏ខ្មៅងងឹត ។ មេដឹកនាំនៃរបបហិង្សាយោធានៅអាមេរិកឡាទីន និងអាមេរិកកណ្តាលបានចាត់ទុកការផ្សះផ្សាបង្រួបបង្រួមជាតិជា “ការអនុគ្រោះនិងការបំភ្លេចអតីតកាល” ។ ការបង្ខំឲ្យបំភ្លេចចោលអតីតកាលដែលក្លែងបន្លំជាការផ្សះផ្សាបង្រួបបង្រួមជាតិនេះប្រាកដណាស់គួរតែត្រូវបដិសេធចោលដោយជនណាដែលព្យាយាមកសាងនូវសន្តិភាពយូរអង្វែង ។

ផ្ទុយទៅវិញ ការយល់ដឹងដ៏ត្រឹមត្រូវនិងការអនុវត្តនូវទ្រឹស្តីការផ្សះផ្សាបង្រួបបង្រួមជាតិគឺមានសារសំខាន់ណាស់ចំពោះការប្រឈមមុខនឹងអតីតកាលបែកបាក់និងអំពើហិង្សា ។ ការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដតម្រូវឲ្យមានការត្រួតពិនិត្យដោយស្មោះត្រង់ទៅលើប្រវត្តិសាស្ត្រ ដើម្បីលាតត្រដាងនិងកត់សម្គាល់ឧក្រិដ្ឋកម្មពីអតីតកាល ។ ជំនួសឲ្យការបំបិទមាត់ជនរងគ្រោះមិនឲ្យនិយាយ និងការមិនគិតគូរចំពោះជនរងគ្រោះ យើងត្រូវធ្វើយ៉ាងណាឲ្យសំឡេងរបស់ជនរងគ្រោះត្រូវគេស្តាប់ ហើយការឈឺចាប់របស់ជនរងគ្រោះត្រូវគេដឹងពុ ។

ប្រធានាធិបតីថ្មីរបស់ប្រទេសអាហ្សង់ទីនឈ្មោះ នេស្តូ ខឺចនើ្ន បានបញ្ជាក់យ៉ាងក្បោះក្បាយនូវចំណុចនេះនៅក្នុងពិធីឡើងកាន់អំណាចរបស់លោកថា គាត់មានគោលបំណង “ដឹកនាំដោយគ្មានការគុំកួន ប៉ុន្តែដើម្បីការចងចាំ” ។ យុត្តិធម៌និងការទទួលខុសត្រូវគឺជាធាតុចម្បងនៃការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដ ។ ការផ្សះរបួសឡើងវិញគួរតែត្រូវបានផ្តល់ទៅឲ្យជនរងគ្រោះ មិនមែនក្នុងគោលបំណងធ្វើជាសំណងសម្រាប់ការបាត់បង់និងទុក្ខវេទនាដែលជនរងគ្រោះបានទទួលនោះទេ ប៉ុន្តែដើម្បីបង្ហាញថាមនុស្សជាតិមិនអាចទទួលយកនូវអំពើហិង្សាបានតទៅទៀតឡើយ ។

បើគ្មានការពិត យុត្តិធម៌ និងតម្លៃតបស្នង ជនរងគ្រោះនិង

សង្គម ជនរងគ្រោះនឹងយល់ថារបបថ្មីកំពុងតែធ្វើអ្វីដែលប្រាសចាកទៅនឹងគោលបំណងរបស់ខ្លួនគេហើយ ។ ជនរងគ្រោះនៅតែជាជនរងគ្រោះដដែល ។ ដោយសារការទទួលរងនូវឋានៈជាជនរងគ្រោះមិនឈប់ឈរដូចនេះ ជនរងគ្រោះទាំងនេះងាយស្រួលនឹងធ្លាក់ទៅក្រោមការគាបសង្កត់របស់មេដឹកនាំដែលព្យាយាមកេងប្រយោជន៍ពីកំហឹងនិងភាពមិនកក់ក្ដៅរបស់ជនរងគ្រោះ ។ ទាំងប្រទេសរ៉្វាន់ដានិងអតីតប្រទេសយូហ្គោស្លាវី បានបង្ហាញនូវឥទ្ធិពលដ៏ឈឺចាប់នៃការអនុញ្ញាតឲ្យអារម្មណ៍ទុក្ខសោកអំពីប្រវត្តិសាស្ត្រស្ថិតក្រោមការកែច្នៃរបស់អ្នកនយោបាយស្នេហាជាតិនិងប្រកាន់ពូជសាសន៍ ។ ដោយគ្មានការផ្សះផ្សាបង្រួបបង្រួមជាតិដ៏ពិតប្រាកដ ជនរងគ្រោះកាលពីម្សិលមិញអាចនឹងក្លាយទៅជាជនដៃដល់នៅថ្ងៃនេះយ៉ាងងាយស្រួលបំផុត ។ ការសុំទោសនិងការទទួលកំហុសក្នុងពេលថ្មីៗនេះរបស់លោក ប៊ីលហ្សាណា ផ្លាវស៊ីក អតីតមេដឹកនាំម្នាក់របស់ជនជាតិស៊ែប៊ី ក្នុងប្រទេសបូស្នៀ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបំបាត់ចោលនូវការយល់ឃើញគ្មានហេតុផលដែលថាជនជាតិស៊ែប៊ី គ្រាន់ជាជនរងគ្រោះតែប៉ុណ្ណោះ ហើយជនជាតិនេះមិនទទួលខុសត្រូវចំពោះជម្លោះបច្ចុប្បន្នឡើយ ។ ដោយទទួលនូវការដាក់ទណ្ឌកម្មនិងបញ្ឈាក់នូវភាពសោកស្ដាយ ផ្លាវស៊ីក បានបើកទូលាយឲ្យមានការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដនៅក្នុងតំបន់ ។ ការផ្សះផ្សាបង្រួបបង្រួមជាតិតម្រូវឲ្យមានការផ្លាស់ប្ដូរនូវគំនិតចាស់ ។ នៅក្នុងប្រទេសដែលមេដឹកនាំពុករលួយបានបង្កើតនូវស្ថាប័នហិង្សាចាក់ឫសគល់ទៅក្នុងសង្គមសន្តិភាពយូរអង្វែងនឹងមិនលេចចេញឡើយ លុះត្រាណាតែស្ថាប័ននគរបាល យោធា តុលាការ និងអង្គភាពផ្សេងៗទៀតនៃរដ្ឋាភិបាល ឆ្លងកាត់នូវកំណែទម្រង់ជាមូលដ្ឋានគ្រឹះមួយ ។ ដើម្បីឲ្យល្បាយដែលងាយនឹងផ្ទុះជាសង្គ្រាមរវាងជនជាតិនិងសាសនាផ្សេងៗគ្នានៅក្នុងប្រទេសអ៊ីរ៉ាក់ក្រោយសង្គ្រាមរួមផ្គុំគ្នាជាធុងមួយបាន លុះត្រាណាមានការបង្កើតឡើងនូវស្ថាប័នជាតិដែលអាចលុបបំបាត់ចោលទាំងស្រុងនូវការគាបសង្កត់និងការបែងចែកនិយមនៃអតីតកាល ។

ជាការពិតណាស់ គម្លាតដ៏ធំផ្នែកទ្រព្យសម្បត្តិនិងអំណាចមានឫសគល់ចេញមកអំពីជម្លោះ ។ ជនដែលបន្តក្ដោបក្ដាប់នូវអភ័យឯកសិទ្ធិលើសលប់ក្រោយពេលមានជម្លោះ តែងតែមិនយល់ថា ការផ្សះផ្សាបង្រួបបង្រួមជាតិមិនឋិតថេរបានទេនៅក្នុងវិសមភាពនៃសិទ្ធិដែលចេះតែបន្ត ។

គ្មានអ្វីដែលអាចអត់ឱនឲ្យមេដឹកនាំដែលមិនខ្វាយខ្វល់ចំពោះលទ្ធផលនៃទង្វើរបស់ខ្លួនទេ ។ នយោបាយគ្មានឧត្ដមគតិនិងមិនបម្រើសង្គមរបស់ប្រធានាធិបតី រ៉ូប៊ឺត មូហ្គាប៊ី នៅក្នុងប្រទេសហ្ស៊ីមបាវេ នឹងត្រូវទទួលយកបានតិចជាងនេះ ប្រសិនបើបន្ទាប់ពីទទួលបានឯករាជ្យជនជាតិស្បែកសប្រកាន់យកទ្រឹស្ដីទំនើបជាងបច្ចុប្បន្នចំពោះការបែងចែកទ្រព្យសម្បត្តិដីស្មើភាពគ្នាមួយ ។

ក្នុងករណីនេះ គួរឲ្យអស្ចារ្យណាស់ដែលប្រទេសអាហ្វ្រិកខាងត្បូងបានធ្វើដំណើរឆ្ពោះទៅមុខយ៉ាងឆ្ងាយក្នុងការកសាង “ជាតិឥន្ទធនូ” (ប្រទេសដែលលាយជាតិសាសន៍ច្រើន) មួយដែលប្ដូរផ្ដាច់ចំពោះការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ប៉ុន្តែប្រទេសហ្ស៊ីមបាវេគួរតែក្លាយទៅជាមេរៀនមួយសម្រាប់ជនជាតិស្បែកសដែលនៅតែបន្តគ្រប់គ្រងទ្រព្យសម្បត្តិភាគច្រើនរបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ ការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដតម្រូវឲ្យមានការលះបង់ខ្ពស់ ដែលរួមទាំងការព្យាយាមលុបបំបាត់ចោលនូវភាពមិនស្មើគ្នាដែលចេះតែបន្តកើតមាននៅពេលដែលការប្រយុទ្ធគ្នាត្រូវបានបញ្ចប់ ។

ការផ្សះផ្សាបង្រួបបង្រួមជាតិយូរអង្វែងតម្រូវឲ្យមានកំណែទម្រង់ច្បាប់ នយោបាយ និងសេដ្ឋកិច្ច ជាទ្រង់ទ្រាយធំ ។ ប៉ុន្តែធ្វើដូច្នេះបានអាស្រ័យទៅលើសកម្មភាពរបស់មេដឹកនាំដែលមានតួនាទីសំខាន់នៅក្នុងជម្លោះ ។ មេដឹកនាំដែលមានចក្ខុវិស័យខ្ពស់ដូចជា នែលសុន ម៉ែនដឺឡា និង អង់សាន ស៊ូជី បានបញ្ឈាក់នូវចិត្តទូលំទូលាយ ទោះជាមេដឹកនាំទាំងពីរនេះមានឱកាសទាមទារនូវការសងសឹកវិញក៏ដោយ ។ ប៉ុន្តែការកើនឡើងនៃភាពស្និទ្ធស្នាលគ្នានឹងមិននាំទៅរកការផ្សះផ្សាបង្រួបបង្រួមជាតិទេ លុះត្រាណាតែចិត្តសប្បុរសនេះត្រូវបានតបស្នងវិញដោយការព្យាយាមព្យាបាលរបួសចាស់នៃជម្លោះដោយជនដែលបានប្រព្រឹត្ត ។

**អាឡិច បូរេន និង ប៉ូល ម៉ាន់ហ្ស៊ីលអ៊ីត**

# របាយការណ៍ស្តីអំពីកិច្ចពិភាក្សា រវាងគណៈប្រតិភូអង្គការសហប្រជាជាតិ និង គណៈកម្មាធិការនៃជនរងគ្រោះដោយរបបខ្មែរក្រហម




គណៈកម្មាធិការយល់ឃើញថា ការស្វែងរកយុត្តិធម៌ជូនចំពោះជនរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ ហៅថាខ្មែរក្រហម គឺជាកាតព្វកិច្ចមួយជាការចាំបាច់ដែលខ្មែរគ្រប់រូបត្រូវតែធ្វើ គឺប្រៀបដូចជាបុគ្គលដែលត្រូវការខ្យល់អុកស៊ីសែនដើម្បីដកដង្ហើមដូច្នោះដែរ ។

គណៈកម្មាធិការដែលជាសមាគមស្របច្បាប់បារាំងបានចាប់ផ្តើមសកម្មភាពពីឆ្នាំ១៩៩៩ ហើយមានចម្ងល់ច្រើនទៅលើបេសកកម្មថ្មីដែលលោកអគ្គលេខាអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានទទួលអំពីមហាសន្និបាតនៃអង្គការសហប្រជាជាតិ ដែលបានអនុម័តសេចក្តីសម្រេចមួយចុះថ្ងៃទី១៨ ធ្នូ ២០០២ បញ្ជាឲ្យលោក កូហ្វី អាណាន់ បន្តបេសកកម្មស្វែងរករូបមន្តជាមួយរដ្ឋាភិបាលខ្មែរ ដើម្បីធ្វើការកាត់ទោសបណ្តាមេខ្មែរក្រហមដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មកំពូល គឺការសម្លាប់រង្គាលនូវជនជាតិរបស់ឯងអស់ចំនួនពីរលាននាក់ ។

ការជួបពិភាក្សាប្តូរយោបល់ដែលគណៈកម្មាធិការយើងខ្ញុំបានធ្វើជាមួយប្រតិភូនៃអង្គការសហប្រជាជាតិកាលពីថ្ងៃចន្ទទី១៤ មេសា ឆ្នាំ២០០៣ នៅក្រុងញូវយ៉កនេះ មានលក្ខណៈជាផ្លូវការ ហើយមានកម្រិតជាឯកទេសដោយយោលទៅលើសមាសភាពនៃប្រតិភូអង្គការសហប្រជាជាតិដឹកនាំដោយលោក ហេន កូរ៉ែល អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកច្បាប់ និងជាទីប្រឹក្សាច្បាប់របស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិផង ។ សហការីរបស់លោក កូរ៉ែល ចំនួនបីនាក់បានចូលរួមក្នុងអង្គជំនុំនេះដែរគឺ ÷

- លោក ដាវីដ អ៊ុតឈីងសុន មន្ត្រីផ្នែកច្បាប់
- លោកស្រី អេលីន អាល់វ៉ាឌី មន្ត្រីផ្នែកនយោបាយតំបន់អាស៊ីនិងប៉ាស៊ីហ្វិក
- និង លោក ហ្គូរ៉ូ អូណូជីម៉ា មន្ត្រីផ្នែកសិទ្ធិមនុស្ស

លោក កូហ្វី អាណាន់ បានចាត់តាំងលោក ហេន កូរ៉ែល ជាប្រធានគណៈប្រតិភូក្នុងការចរចាជាមួយនឹងរាជរដ្ឋាភិបាលខ្មែរអំពីការកាត់ទោសខ្មែរក្រហម ។ ស្តីអំពីការពិភាក្សារវាងគណៈប្រតិភូលោក ហេន កូរ៉ែល និងគណៈកម្មាធិការនៃជនរងគ្រោះដោយខ្មែរក្រហមវិញ យើងធ្វើការដកស្រង់ខ្លឹមសារនៃការ

ពិភាក្សាគ្នាអស់រយៈពីរម៉ោងដូចតទៅនេះ ÷

**១) លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដឹកនាំអង្គការនីតិប្រតិបត្តិរបស់អង្គការសហប្រជាជាតិ**

មហាសន្និបាតនៃអង្គការសហប្រជាជាតិដែលជាទីលានប្រជុំនិងអនុម័តរបស់បណ្តាប្រទេសជាសមាជិកអង្គការសហប្រជាជាតិ គឺជាអង្គជំនុំសម្រេចសេចក្តីដាក់បេសកកម្មឲ្យលោក កូហ្វី អាណាន់ អាស្រ័យហេតុនេះហើយទើបលោក ហេន កូរ៉ែល សង្កត់លើចំណុចមួយដែលគណៈកម្មាធិការនៃជនរងគ្រោះលើកមកពិភាក្សា គឺការបង្កើតតុលាការអន្តរជាតិនៅប្រទេសខ្មែរ គាត់បានរំឭកបញ្ជាក់ថា អ្នកឯកទេសច្បាប់របស់អង្គការសហប្រជាជាតិបានធ្វើសំណើកាលពីឆ្នាំ១៩៩៩មកម៉្លេះថា ដើម្បីធ្វើការកាត់ទោសខ្មែរក្រហមឲ្យមានប្រសិទ្ធភាពគេត្រូវបង្កើតតុលាការមួយនៅក្រៅប្រទេសខ្មែរ ក៏ប៉ុន្តែក្នុងពេលបច្ចុប្បន្ន ទោះចង់ឬមិនចង់ក្តី បេសកកម្មនៃអគ្គលេខាដែលទទួលបញ្ជាអំពីមហាសន្និបាតឲ្យធ្វើការចរចាម្តងទៀតជាមួយរដ្ឋាភិបាលខ្មែរ គឺជាបេសកកម្មដើរតាមខ្សែបន្ទាត់ដែលគូសទុករួចមកហើយក្នុងច្បាប់ខ្មែរឆ្នាំ២០០១ ស្តីអំពីការកាត់ទោសខ្មែរក្រហម ។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញដែលច្បាប់ខ្មែរ ឆ្នាំ២០០១បានបង្កើតភ្ជាប់ទៅនឹងចង្កោមសាលាកាត់ក្តីខ្មែរ ។ គឺបានសេចក្តីថា ចៅក្រមនិងព្រះរាជអាជ្ញានឹងធ្វើការស៊ើបអង្កេតកាត់ទោសខ្មែរក្រហមទៅតាមបញ្ញត្តិច្បាប់ខ្មែរឆ្នាំ២០០១ និងច្បាប់អន្តរជាតិថែងក្នុងសន្ធិសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៨ ដែលប្រទេសខ្មែរបានទទួលស្គាល់ និងដែលមានសភាជាតិព្រមទទួលចុះសច្ចាប័ន ។ យើងចោទសួរថា ការអនុវត្តន៍ច្បាប់ខ្មែរនេះនឹងមានប្រសិទ្ធភាពឬទេក្នុងការកាត់ទោសខ្មែរក្រហម ។

**២) អំពីការអនុវត្តន៍ច្បាប់និងគម្រោងកិច្ចព្រមព្រៀងរវាងលោកអគ្គលេខា កូហ្វី អាណាន់ និងរាជរដ្ឋាភិបាលខ្មែរ**

លោក ហេន កូរ៉ែល បានរំឭកថា បុព្វហេតុចម្បងមួយដែលជំរុញឲ្យមានការផ្តាច់ស្ពានចរចានៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ គឺរាជរដ្ឋាភិបាលខ្មែរបន្ទាប់ពីបានអនុម័តច្បាប់កាត់ទោសខ្មែរក្រហមជាធរមានហើយ ក៏បានប្រកាន់គោលការណ៍ថា មានតែច្បាប់នេះទេដែលតុលាការត្រូវយកជាបានការ គឺមិនមែនកិច្ចព្រមព្រៀង (Memorandum of understanding) រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលទេ ។

ម្តងនេះទៀតគឺជាលើកទី២ហើយដែលរាជរដ្ឋាភិបាលបានចរចាជាមួយនឹងអង្គការសហប្រជាជាតិ លើសំណៅកិច្ចព្រមព្រៀង១ដែលធ្វើជាថ្នាលនៃគោលការណ៍ធំៗ ដើម្បីកាត់ទោសខ្មែរក្រហម ។ លោក កូរ៉ែល បានសង្កត់លើចំណុចមួយគឺកិច្ចព្រមព្រៀងចុងបញ្ចប់ដែលនឹងកើតមានឡើងនៅពេលខាងមុខឆាប់ៗនេះ នឹងត្រូវចាត់ទុកតាមផ្លូវច្បាប់ថាជាអនុសញ្ញាអន្តរជាតិ (International treaty) រវាងអង្គការសហប្រជាជាតិនិងកម្ពុជា បានសេចក្តីថា អនុសញ្ញានេះនឹងទទួលបញ្ញត្តិផ្សេងៗដែលមានចែងទុកក្នុងសន្ធិសញ្ញាក្រុងវីយែនឆ្នាំ១៩៦៨ ដែលជាសសរទ្រូងនៃអនុសញ្ញាទាំងឡាយ ។

បញ្ញត្តិទាំងនេះគឺ ÷

១) លើកតម្កល់អនុសញ្ញាក្នុងការកាត់ទោសខ្មែរក្រហមនៅថ្នាក់លើខ្ពស់ជាងច្បាប់ក្នុងប្រទេស មានច្បាប់កាត់ទោសខ្មែរក្រហមឆ្នាំ២០០១ជាអាទិ៍ ។

២) ហាមមិនឲ្យកម្ពុជាយកច្បាប់ណាមួយរបស់រដ្ឋមករាំងខ្ទប់ការអនុវត្តអនុសញ្ញាកាត់ទោសខ្មែរក្រហម ។

៣) ការអនុវត្តអនុសញ្ញានេះនឹងត្រូវប្រតិបត្តិឡើងដោយគុនធម៌ គឺសុចរិតធម៌ គ្មានការបន្លំបញ្ឆោត ។

៤) អង្គការសហប្រជាជាតិនឹងដកខ្លួន គឺឈប់បង់ថវិកាសម្រាប់តុលាការកាត់ទោសខ្មែរក្រហម ល្អិកណាមានការរាំងស្ទះ គឺមិនគោរពកិច្ចព្រមព្រៀងនេះ តាមរយៈកត្តាណាមួយ ឧទាហរណ៍គឺការបង្កើតច្បាប់ថ្មីឯណាផ្សេងទៀតដែលមានលក្ខណៈខុសឆ្គងលើកិច្ចព្រមព្រៀងនេះ ។

**៣) អំពីការកាត់ទោសខ្មែរក្រហមនៅប្រទេសខ្មែរ ឬនៅក្រៅប្រទេសខ្មែរ**

ការស្វែងរកយុត្តិធម៌មិនមែនជាល្បែងគំនិតបញ្ញាគ្មានការដាក់ស្តែងនោះទេ ។ មានមតិមួយចំនួនយល់ថា ការកាត់ទោសនៅប្រទេសខ្មែរជាការប្រសើរ ដោយហេតុថា ប្រជាពលរដ្ឋខ្មែរនឹងមានការជ្រួតជ្រាបអំពីយុត្តិធម៌ដែលសង្គមខ្មែរស្រេកឃ្លានជាយូរមកហើយ ។ ប៉ុន្តែគេភ្លេចគិតថា ទោះបីនៅទីណាក៏ដោយ

យុត្តិធម៌ដែលបានមកអំពីការសម្រុះសម្រួលឬការយោគយល់គ្នាក្នុងផ្នែកមិត្តភាពឬនយោបាយ ។ល ។ ឧទាហរណ៍គឺការលើកលែងទោសឲ្យឧក្រិដ្ឋជនខ្មែរក្រហមដោយសម្អាងលេសថានេះជាការបង្រួបបង្រួមជាតិ យុត្តិធម៌បែបនេះដែលមិនយកច្បាប់ជាធំគឺជាយុត្តិធម៌ក្លែងក្លាយ ។ អាស្រ័យហេតុនេះហើយទើបគណៈ-កម្មាធិការនៃជនរងគ្រោះដោយរបបខ្មែរក្រហមលើកយកចំណុចតែមួយមកបកស្រាយ ÷ យុត្តិធម៌នៅទីក្រុងភ្នំពេញដែលមានមេអតីតខ្មែរក្រហមធំៗ នៅកាន់អំណាចព្រមទាំងមានសេរីភាពគ្រប់បែបយ៉ាងនោះ ជាយុត្តិធម៌ស្របច្បាប់ឬទេ ។ លោក កូរ៉ែល ក៏បានបញ្ជាក់រំឭកដល់គណៈកម្មាធិការថា អ្នកឯកទេសជំនាញការក្នុងផ្នែកច្បាប់នៃអង្គការសហប្រជាជាតិបានយល់ឃើញដូចយើងដែរថា ការកាត់ទោសខ្មែរក្រហមនៅក្រៅប្រទេសខ្មែរ វាមានលក្ខណៈប្រសើរជាងនៅទីក្រុងភ្នំពេញ ។ គោលជំហរនេះមានចែងក្នុងរបាយការណ៍របស់អ្នកជំនាញការនាឆ្នាំ១៩៩៩ នោះមកម៉្លេះ ។ បញ្ហាអសន្តិសុខនិងការខ្វះខាតគ្រប់បែបយ៉ាងនៃចង្ក្រាមតុលាការឬអង្គជំនុំជម្រះខ្មែរទាំងផ្នែកសិក្សាអប់រំផ្លូវច្បាប់និងក្នុងវិស័យសុចរិតយុត្តិធម៌នៃសុភាចារបុរសផង គឺកត្តាទាំងឡាយនេះហើយដែលឆ្លុះបញ្ចាំងនូវសភាពការណ៍សើៗខ្វះការជាក់ស្តែង ប្រសិនបើមានការកាត់ទោសខ្មែរក្រហមនៅប្រទេសខ្មែរ ។

យើងបានបញ្ជាក់រួចមកហើយថា ការកាត់ទោសនេះប្រៀបបានដូចជាខ្យល់ដកដង្ហើមសម្រាប់បុគ្គល គឺជាការចាំបាច់ដែលត្រូវតែមានជាដាច់ខាត ។ ក៏ប៉ុន្តែខ្យល់អុកស៊ីសែនឬខ្យល់យុត្តិធម៌នៅទីក្រុងភ្នំពេញជាខ្យល់ពុល សណ្តំ សម្ងាប់សម្បជញ្ញៈជាតិនិងយុត្តិធម៌ពិតៗកុំឲ្យកើតមានឡើង ។ ទោះជាយ៉ាងនេះឬយ៉ាងណាផ្សេងទៀតក្តី គណៈកម្មាធិការត្រូវតែតាមដានដឹកឬសគល់ឲ្យឃើញជាក់ស្តែង ។ យើងនឹងធ្វើសហការជាមួយលោកអគ្គលេខានៃអង្គការសហប្រជាជាតិ ក្នុងការស្វែងរកយុត្តិធម៌ពិតប្រាកដនេះ ដោយលាក់ទុកនូវសេចក្តីសង្ឃឹមយ៉ាងតូចមួយថា ក្នុងនាមជាខ្មែរ ទោះបីបុគ្គលនោះនៅក្នុងគណបក្សនយោបាយណាមួយក្តី គប្បីគេប្រមើលឃើញអរិយធម៌ដ៏ត្រចះត្រចង់របស់ខ្មែរបុរាណ ដែលធ្លាប់រស់នៅដីត្រជាក់ត្រជុំមូលផ្តុំសាមគ្គីគ្នានៅនាសុវណ្ណភូមិ ត្បិតប្រជាពលរដ្ឋ រាស្ត្រតូចធំបានទទួលការការពារនិងយុត្តិធម៌ពីសំណាក់អ្នកគ្រប់គ្រងប្រទេសដែលមានការគោរពច្បាប់និងប្រពៃណីខ្មែរ ខុសអំពីទមិឡដួជាតិប្រល័យសាសន៍ឯង ។

សហការដែលគណៈកម្មាធិការមានលទ្ធភាពធ្វើជាមួយអង្គការសហប្រជាជាតិ គឺស្ថិតនៅក្នុងសភាពវ៉ាងវៃជានិច្ចគឺមិនបណ្តោយឲ្យមានការឃុបឃិតសមគំនិតជាមួយឧក្រិដ្ឋជនឬជនខ្វះសុចរិតនិងសីលធម៌នោះឡើយ ។ យើងប្រកាន់យកគោលការណ៍ច្បាប់ជាធំ គឺល្អិកណារាជរដ្ឋាភិបាលបង្វែរបញ្ហាការអនុវត្តច្បាប់អន្តរជាតិនិងកិច្ចព្រមព្រៀងជាមួយនឹងអង្គការសហប្រជាជាតិតាមប្រការណាមួយ ដរាបនោះយើងនឹងដកខ្លួនថយជាបន្ទាន់គឺមិនទុកឱកាសឲ្យគេយកយើងធ្វើជាឈ្នាន់បានឡើយ ។

### ៤) អំពីសកម្មភាពដែលគណៈកម្មាធិការនឹងអាចធ្វើបាន

ដោយយោលទៅលើការពិសោធន៍របស់យើងក្នុងផ្នែកច្បាប់ និងការជួយដាក់ពាក្យបណ្តឹងឲ្យជនរួមជាតិយើងដែលបានរស់ជីវិតអំពីការពិឃាតរង្គាលនិងការប្រល័យពូជសាសន៍ពីសំណាក់ទមិឡខ្មែរក្រហម គណៈកម្មាធិការមានជំនឿយ៉ាងមុតមាំថាតទៅអនាគត យើងនឹងធ្វើសហការជាមួយនឹងមជ្ឈមណ្ឌលស្រាវជ្រាវឯកសារនៅទីក្រុងភ្នំពេញ ដឹកនាំដោយលោក ឆាំង យុ បន្ថែមនិងការទាក់ទងផ្តល់ជំនួយជាមេធាវី ។ល ។ ចំពោះជនរួមជាតិទាំងឡាយណាដែលប្រឈមមុខប្តឹងមេខ្មែរក្រហមធំៗ នៅចំពោះមុខតុលាការនៅក្រុងភ្នំពេញ ។ អ្នកឯកទេសជំនាញការបរទេសនឹងអាចពឹងផ្អែកលើគណៈកម្មាធិការដែលមានកម្រិតជំនាញផ្លូវការច្បាប់គ្រប់គ្រាន់ ហើយមានការពិសោធន៍ក្នុងពិភពច្បាប់ទាំងពីរគឺនៅលើផ្ទៃរាបអន្តរជាតិ និងនៅក្នុងសង្គមខ្មែរនោះផង ។

រីឯបញ្ហាភាសាដែលជាដួងចៃក្នុងវិស័យច្បាប់និងយុត្តិធម៌នេះ យើងក៏បានបញ្ជាក់និងរំឭកលោក ហេន កូរ៉ែល ថា គណៈ-កម្មាធិការយើងដែលតាមពិតគឺមានសមាជិកជាខ្មែរចេះភាសានិងសរសេរខ្មែរយ៉ាងជ្រៅជ្រះ មិនបារម្ភចំពោះការបកប្រែបង្វែរឃ្លាពីភាសាខ្មែរទៅជាភាសាបារាំងឬអង់គ្លេសនោះឡើយ ។ ចំណុចនេះមានសារសំខាន់ជាកំពូល ដោយហេតុថាគេបានចារក្នុងសំណៅកិច្ចព្រមព្រៀងថា ភាសាខ្មែរជាភាសាប្រើផ្លូវការក្នុង

អង្គជំនុំជម្រះវិសាមញ្ញ ។

អាស្រ័យហេតុនេះ យើងបានស្នើទៅលោក ហេន កូវ៉ែល ឲ្យមានធ្វើការបង្រៀននិងអប់រំសម្បជញ្ញៈអ្នកឯកទេសបកប្រែពីខ្មែរទៅបារាំងឬអង់គ្លេស ឲ្យស្គាល់តម្លៃមុខងាររបស់ខ្លួនដែលមានកាតព្វកិច្ចជួយជំរុញការកាត់ទោសខ្មែរក្រហមឲ្យមានលក្ខណៈយុត្តិធម៌ ត្បិតអយុត្តិធម៌ក៏អាចកើតមានឡើងអំពីការបកប្រែភាសាបំផ្លើសឬបញ្ចុះន័យដើមរបស់អ្នកនិយាយដែរ ។

ការបង្វែរបន្តយុត្តិធម៌និងសុចរិតធម៌ នឹងអាចស្ថិតនៅក្នុងការភ័យខ្លាចនៃបណ្តាសាក្សីឬអ្នកដើមចោទទាំងឡាយទៀតផង ។

## ៥) ត្រូវតែមានការការពារសាក្សី អ្នកដើមចោទ ឬ មេធាវី

លោក កូវ៉ែល បានបង្ហាញទ្រឹស្តីរបស់លោកមួយចំនួនដូចជាការយកឯកសារឬសេចក្តីថ្លែងការណ៍នៃជនរងគ្រោះដែលបានចុះផ្សាយក្នុងសារពត៌មានឬព្រឹត្តិប័ត្រផ្សេងៗ មកធ្វើជាភ័ស្តុតាងចំពោះមុខតុលាការ ដោយពុំចាំបាច់ឲ្យមានការបង្ហាញខ្លួនផ្ទាល់នៃបណ្តាជនទាំងនោះទេ ។

នេះជាវិធីមួយប្រសើរដែរ ក៏ប៉ុន្តែគណៈកម្មាធិការយើងបានកត់សម្គាល់ថា ការឈមមុខរវាងជនរងគ្រោះនិងមេឃាតករខ្មែរក្រហម វាអាចធ្វើឲ្យដំណើរនៃការកាត់ទោសមានសភាពជាក់ស្តែងផង ហើយក៏អាចជាឱសថផ្សះផ្សាដំបៅផ្លូវចិត្ត និងលើកតម្លៃជនរងគ្រោះឲ្យមានវេទិកាសម្តែងការឈឺចាប់និងថ្លែងការពិតៗឲ្យតុលាការនិងមតិមហាជនបានស្តាប់ឮទៀតផង ។

ដើម្បីឲ្យមានការជាក់ស្តែងនេះ យើងបានស្នើថា គួរតែមានការគ្រោងទុកនូវថវិកាមួយភាគសម្រាប់រៀបចំការការពារបណ្តាជនដែលមកចូលរួមរកយុត្តិធម៌ ឲ្យមានការជម្លៀសទៅបរទេសជិតឆ្ងាយ បន្ទាប់ពីមានថ្លែងការណ៍នៅចំពោះមុខតុលាការ ។ នេះជាវិធានការដែលមានចាត់តាំងឡើងនៅចំពោះមុខតុលាការអន្តរជាតិក្រុងឡាអេជាអាទិ៍ ។

រីឯការសងជំងឺចិត្តដល់ជនរងគ្រោះវិញ យើងបានស្នើថា មហាអំណាចធំៗដូចជាសហរដ្ឋអាមេរិក នឹងអាចធ្វើការរឹបអូសសម្បត្តិធនធានដែលមេខ្មែរក្រហមបានកេងប្រវ័ញ្ចលើភោគសម្បត្តិជាតិ ដូចការកាប់ឈើជីកត្បូងលក់ជាដើម ដើម្បីយកប្រាក់ទាំងនេះមកជូនជនរងគ្រោះ គឺជាការប៉ះប៉ូនរបួសស្នាកស្នាមដំបៅគ្រប់ប្រភេទដែលឧក្រិដ្ឋជនខ្មែរក្រហមបានបន្សល់ទុកខ្មែរក្រហមបានបន្សល់ទុកលើរាងកាយនិងសតិអារម្មណ៍របស់អស់លោកទាំងនោះ គឺជាលទ្ធផលនៃឧក្រិដ្ឋកម្មកំពូលរបស់វាបន្ទាប់ពីប្រល័យពូជពង្សវង្សត្រកូលគ្រួសារខ្មែរស្ទើរផុតពូជគ្រប់ៗគ្នាអស់រយៈពេលជិតបួនឆ្នាំមក ។

ទោះជាមានការសងជាប្រាក់រាប់លានដុល្លារក្តី ក៏វាមិនអាចជំនួសឪពុកម្តាយ មីងមា តាយាយ បងប្អូន កូនក្មួយដែលទមិឡខ្មែរក្រហមបានសម្លាប់រង្គាលនោះទេ ។ ក៏ប៉ុន្តែយុត្តិធម៌ត្រូវតែមាន គឺតាមវិស័យសំណងជំងឺចិត្តនេះផង ។

បន្ទាប់ពីការប្តូរយោបល់គ្នានេះអស់រយៈពីរម៉ោង លោក ហេន កូវ៉ែល និងគណៈប្រតិភូរបស់លោកបីនាក់ទៀត មានសេចក្តីសោមនស្សថតរូបជាអនុស្សាវរីយ៍ នៅមុខសាលាជំនុំជាមួយនឹងប្រតិភូគណៈកម្មាធិការនៃជនរងគ្រោះដោយរបបខ្មែរក្រហមទាំង៦រូប គឺមាន÷

- ◆ ប្រធាន លោក ឆាយ ហុកផេង បណ្ឌិតច្បាប់ និងជាសុភាចារបុរសនៅស្រុកបារាំង

សមាជិកពីស្រុកបារាំង÷

- ◆ លោកស្រី អ៊ឹង ប៊ុនហោ អគ្គលេខាធិការ
- ◆ លោកស្រី ឆាយ អេងលី បណ្ឌិតឱសថការី

សមាជិកមកពីស្រុកអាមេរិក÷

- ◆ លោក គុច ចាន់លី អនុបណ្ឌិតផ្នែកអប់រំ
- ◆ លោក ជិម សុផុន ក្រុមហ៊ុនធានារ៉ាប់រង
- ◆ លោក សុក សាគុន នាយកសហគ្រាស

យើងបានចាកចេញពីក្រុងញូវយ៉កនៅពេលល្ងាចថ្ងៃចន្ទទី១៤ មេសា ឆ្ពោះទៅកាន់ក្រុងវ៉ាស៊ីនតោនឌីស៊ី ដែលមានការបើកប្រជុំប្តូរយោបល់និងពត៌មាននៅថ្ងៃទី១៥ មេសា រៀបចំឡើងដោយលោកវិស្វករ ពៀង ហ្គាហ្វូរ (Peang Gafout) ដែលបានស្ម័គ្រចិត្តទទួលបន្ទុកផ្នែកទំនាក់ទំនងនឹងស្ថាប័នរដ្ឋផ្សេងៗនៅសហរដ្ឋអាមេរិក ដើម្បីជួយជំរុញសកម្មភាពរបស់គណៈកម្មាធិការយើងឲ្យមានសន្ទុះខ្លាំងឡើងៗទៅអនាគត ។

**ឆាយ ហុកផេង**

# ខ្ញុំរងគ្រោះព្រោះមេដឹកនាំអន្យត្ថីរយ៍


សង ហេង

ខ្ញុំឈ្មោះ សង ហេង ហៅ ក្រៅ យូ ហេង កើតនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៦៧ មានស្រុកកំណើតនៅភូមិក្រសាំងជ័យ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ពេលដែលអាមេរិកាំងទម្លាក់គ្រាប់បែកនៅកម្ពុជា គ្រួសារខ្ញុំត្រូវភៀសខ្លួនចេញពីស្រុកកំណើតទៅរស់នៅតំបន់ព្រៃស្រោង គ្រពាំងបុស្សី ក្បាលដំរី ភ្នំដី ។ ដោយមិនអាចទ្រាំទ្រនឹងជំងឺគ្រុនចាញ់បាន គ្រួសារខ្ញុំត្រូវបង្ខំចិត្តវិលត្រឡប់មកភូមិកំណើតវិញ ។ ចុងក្រោយបានមកសង់ខ្ទមតូចមួយនៅឯវាលស្រែខាងលិចភូមិបឹង ។ ប្រជាជនបានមកតាំងទីលំនៅជាបន្តបន្ទាប់នៅទីវាលនេះ ។ មិនយូរប៉ុន្មាន ទីវាលនេះក្លាយទៅជាកូនភូមិតូចមួយឈ្មោះថា ណុងម៉ូវ ដែលជាផ្នែកមួយនៃភូមិបឹងខាងជើង ។

ជាញឹកញាប់ ខ្ញុំឮស្គរសន្ទឹកយន្តហោះទម្លាក់គ្រាប់បែកពិសេសឮពីអ្នកទៅប្រកបរបរត្រីប្រហុកនៅមាត់បឹងទន្លេសាប ។ មានថ្ងៃមួយ ពេលដែលខ្ញុំកំពុងដើរចាប់ក្តាម ខ្ញុំឃើញយន្តហោះបន្ទាបខ្លួនទម្លាក់គ្រាប់បែកយ៉ាងសន្ធោសន្ធៅ ។ ខ្ញុំរត់ទៅពួនអែបគល់ឈើ សម្លឹងមើលព្រឹត្តិការណ៍ដោយក្តីរន្ធត់ ។ គ្រាប់បែកផ្ទុះផ្លូនៗរញ្ជួយប្រឹថពី ។ ផ្សែងខ្មួលខ្មាញ់អណ្តែតពេញអាកាស ។ កប៉ាល់ហោះពីរគ្រឿងបានកម្ទេចស្ពានកំពង់ថ្មត្រង់ស្ទឹងជីនិត និងផ្ទះអ្នកស្រុកនៅក្បែរនោះខ្ទេចខ្ទីក្លាយជាផេះផង់ ។

របបគ្រប់គ្រងនយោបាយមួយដែលខ្ញុំបានរត់គេចលូនក្រាបក្រោមសម្រែកមច្ចុរាជស្លាបដែកបាចរោយគ្រាប់ស្ទើរសុសដី បានផុតរលត់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ របបថ្មីមួយបានមកជំនួស គឺកម្ពុជាប្រជាធិបតេយ្យ ។ ចាប់ផ្តើមនៃរបបនេះ ខ្ញុំមានវ័យជាងប្រាំបីឆ្នាំ ។ ភ្លើងសង្គ្រាមបានរលត់ផុតទៅ ខ្ញុំតែងសង្ឃឹមថាបានសេចក្តីសុខសុភមង្គលក្នុងគ្រួសារក៏ដូចសង្គមជាតិ ប៉ុន្តែអ្វីៗបានប្រែប្រួលយ៉ាងឆាប់រហ័សដែលនឹកស្មានមិនដល់ ។

ខ្ញុំបានឮចាស់ៗនិយាយថាៈ បន្តិចទៀតនឹងឃើញស្រីៗសក់វែងៗ មកនៅជាមួយយើង ។ គេប្រមូលរបស់របរដាក់រួមហូបរួម ធ្វើការរួម ដេករួម ដូចនៅស្រុកចិនកុម្មុយនិស្តអ៊ីចឹង ។ មិនយូរប៉ុន្មាន ដំណឹងនេះប្រាកដមែន ។ ខ្ញុំឃើញប្រជាជនដើរបន្តគ្នារដឹកតាមថ្នល់មុខផ្ទះខ្ញុំ ខ្លះរែក ខ្លះស្ពាយ ខ្លះរុញស៊ីក្លូ ខ្លះបណ្តើរកង់ផ្ទុកបង្ហេចអីវ៉ាន់ ។ ស្ត្រីមានផ្ទៃពោះដើរយ៉ាងលំបាក ខ្លះដឹកដៃកូន មនុស្សចាស់ៗដើរកាន់ឈើច្រត់កោងខ្នងៗ ខ្លះឈប់សម្រាកលើចិញ្ចើមថ្នល់ដេកសន្ធឹងសន្ធៃ ខ្លះអង្គុយឈ្ងោកត្របោមក្បាលជង្គង់ ខ្លះកោសខ្យល់ ចាប់ខ្យល់ ដកសក់ដកស្លឹកត្រចៀក ។ ក្រោយមកទើបខ្ញុំដឹងថាអ្នកទាំងអស់នេះត្រូវអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញ ។ អង្គការបានចេញបញ្ជាឲ្យអ្នកទីក្រុងទាំងនោះ ស្នាក់នៅតាមផ្ទះអ្នកស្រុក ។ ខ្ញុំឃើញក្មេងតូចៗនិងមនុស្សចាស់ជរាដើរសុំម្ហូបអាហារអ្នកស្រុកស្ទើររាល់ថ្ងៃ ។ អង្គការបានហៅអ្នកទាំងនោះថា ប្រជាជនថ្មី ឬប្រជាជនដប់ប្រាំពីរមេសា ។

ខ្ញុំមិនចាំទេថាថ្ងៃណាខែណាដែលអង្គការប្រមូលកម្មសិទ្ធិដាក់ជាសមូហភាព ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៦ ។ ខ្ញុំនៅតែបន្តការរៀនសូត្រនៅសាលាស្វាយអម្ពាខាងកើតភូមិបឹងជាធម្មតា ។ គេមិនឲ្យហៅគ្រូបង្រៀនថា លោកគ្រូ ឬ អ្នកគ្រូ ឡើយ គឺឲ្យហៅថា «បងៗ» ។ ក្រោយពីរកដីសសម្រាប់សរសេរលែងបាន ការសរសេរត្រូវជំនួសដោយធ្យូងវិញ ។ ក្រោយៗមកទៀត ទៅសាលាមិនប្រាកដថាបានរៀននោះទេ ។ ជួនកាលលើករងដំឡូង

ជញ្ជូនអាចម៍គោ ដកស្មៅក្នុងស្រែ អូសកណ្ដាប់ ។ ពេលដកស្មៅខ្ញុំពិបាកណាស់ ព្រោះដើមកក់ដកស្ទើរមិនបាន ពិសេសដើមស្មៅកកិតមុតដៃហើមស្ទើរគ្រប់ម្រាម ។ ខ្ញុំបានឃើញអង្គការថ្នាក់លើចុះមកសាលាពីរលើក ។ លើកដំបូង អង្គការចែកជីសឲ្យកុមារ ។ ពេលអង្គការបើកប្រអប់ ខ្ញុំឃើញជីសរលូនពណ៌ស្អាតៗ ។ ខ្ញុំត្រេកអរណាស់ ។ អង្គការបានកាច់ជីសជាបីៗកំណាត់សម្រាប់ចែកឲ្យកុមារបីៗនាក់ ។ ក្រោយពីចែករួចអង្គការបានពន្យល់ថាៈ *ប្រទេសជាតិយើងនៅក្រដោយសារវណ្ណៈសក្តិភូមិនាយទុន ប្រតិកិរិយា ចក្រពត្តិអាមេរិក វាបឺតជញ្ជក់ឈាមវណ្ណៈកសិករ យើងឲ្យក្រីក្រ...។* ក្រោយមកអង្គការដឹកនាំបានមកម្ដងទៀត ។ ម្ដងនេះខ្ញុំបានទទួលជីសមួយកំណាត់ ខ្មៅដៃមួយកំណាត់ និងសៀវភៅមួយកំណាត់ ។ របស់ទាំងអស់នេះត្រូវកាត់រួចជាស្រេច ។ លើកនេះក៏ដូចលើកមុនដែរ កម្មាភិបាលអង្គការបានប្រាប់ថាៈ *ប្រទេសយើងនៅក្រណាស់ដោយសារវណ្ណៈសក្តិភូមិនាយទុន មូលធន អ្នកមានវាជញ្ជក់ឈាមកេងប្រវ័ញ្ចញើសឈាមវណ្ណៈ កសិករ...។ ចាប់ពីពេលនេះទៅយើងទាំងអស់គ្នាជាម្ចាស់ប្រទេស កុមារត្រូវមានស្មារតីបដិវត្តស្អាតស្អំ មានគោលជំហររឹងមាំលះបង់ខ្ពស់ ត្រូវរាយការណ៍ឲ្យអង្គការចំពោះខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង...។* ខ្ញុំមិនយល់ថាវណ្ណៈសក្តិភូមិនាយទុននោះជាអ្វីទេ គ្រាន់តែដឹងថា អ្នកមានជិះជាន់អ្នកក្រ លោកសង្ឃជាឈ្លើងសង្គម ជាបញ្ញើក្អែក ព្រោះអត់ធ្វើការងារចាំតែស៊ីស្រាប់ៗដូចជ្រូក ។

ការទៅសាលារៀនរបស់ខ្ញុំនៅពេលនេះគ្រាន់តែទៅជួបជុំគ្នាតាមក្រុមនៅសាលាប៉ុណ្ណោះ ។ បន្ទាប់មកយកកញ្ជើឬបង្គីដើរកើបអាចម៍គោយកទៅស្ដុកក្នុងរោងជីរដ៏ធំមួយ ។ ពេលថ្ងៃជិតត្រង់ ខ្ញុំហេវហត់ញ័រដៃជើង ព្រោះពេលព្រឹកមិនមានអាហារស្រស់ស្រូបឡើយ ។ កាលពីដំបូង មានដំណាំដំណោចរបស់របរហូបចុកបន្តិចបន្តួចគ្រាន់ហូបសម្រន់ឃ្លាន ក្រោយមកដាច់សោះតែម្ដង ។ មកដល់ផ្ទះ ជួនកាលចុងភៅមិនទាន់វាយជួងហូបបាយទៀត ខ្ញុំហេវខ្លាំង ញ័រខ្លួន ភ្នែកស្រវាំង បែកញើសជោក ។ មានថ្ងៃមួយកំពុងធ្វើការ ខ្ញុំឃ្លានពេកក៏ដើរទៅរករោងស្ករត្នោតដែលនៅក្បែរនោះ ។ ខ្ញុំយកស្លឹកត្នោតទៅកៀរស្ករដែលរឹកថ្មីៗ ។ កំពុងតែលិទ្ធស្ករ ស្រាប់តែប្រធានរោងស្ករទាញកញ្ឆក់ដៃខ្ញុំយ៉ាងខ្លាំង ធ្វើឲ្យស្ករត្នោតរបូតចេញពីមាត់ធ្លាក់ដល់ដី ។ ប្រធានរោងត្នោតសម្លុតគំរាមរកចង់ស្លាបសេកខ្ញុំ ។ ខ្ញុំយំសំពះអង្វរសុំការលើកលែងទោស ។ ចុងក្រោយ ប្រធានរោងត្នោតវាយខ្ញុំនឹងខ្សែចងបំពង់ទឹកត្នោត ធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង ។ ការរៀនសូត្រត្រូវបញ្ចប់ទាំងស្រុង ដោយបងៗគ្រូតម្រូវឲ្យកុមាររៀបចំសាក់កាដូទៅរើសកក្ដួរស្រូវនៅស្រែក្រោម ។ កុមារដែលមានមាឌធំៗត្រូវធ្វើដំណើរទៅស្រែក្រោមចំណែកកុមារតូចៗដូចខ្ញុំត្រូវធ្វើការនៅក្នុងភូមិដដែល ។


ប្រជាជនជម្លៀស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

បងប្រុសទី១ត្រូវប្រធានភូមិចាប់បង្ខំឲ្យទៅសមរភូមិមុខ ។ ពេលយប់ៗខ្ញុំឃើញអ្នកម្ដាយយំរៀបរាប់យ៉ាងសង្វេគអំពីការព្រាត់កូនជាទីស្រលាញ់ ។ បួនប្រាំខែក្រោយមក បងត្រឡប់មកផ្ទះវិញដោយលួចរត់ចេញពីមន្ទីរពេទ្យ ។ មិនដឹងថាបងប្រុសមានជំងឺអ្វីទេបានជាគាត់ស្លេកស្លាំងយ៉ាងខ្លាំង ។ គ្រួសារយើងបានជួបជុំគ្នាក្នុងសភាពក្រៀមក្រំ ។ មិនបានប៉ុន្មានថ្ងៃផង ប្រធានកងមកចាប់

បងប្រុសខ្ញុំបញ្ជូនទៅសមរភូមិមុខជាលើកទីពីរ ។ ខ្ញុំមិនបានជួបមុខបងនិងជូនដំណើរជាលើកចុងក្រោយឡើយ ព្រោះត្រូវចេញទៅធ្វើការតាំងពីព្រលឹម ។ ដោយក្តីនឹកអាណិតកូន អ្នកម្តាយចុះខ្សោយយ៉ាងខ្លាំង ។ រហូតមកដល់ពេលនេះ បងប្រុសបាត់ដំណឹងសូន្យឈឹង អ្នកម្តាយនៅតែទន្ទឹងរង់ចាំទាំងទឹកភ្នែក ។

វេលាទៀបភ្លឺ ស្នូរកញ្ចែជាសញ្ញាឲ្យកុមារចេញទៅធ្វើការតាមមុខព្រួញ ។ ពេលព្រឹកកាប់ដើមទន្ទ្រានខែត្រប្រមូលចងជាបាច់ទូលទៅស្តុកនៅរោងជី ពេលថ្ងៃហូបបបររួចទៅចិញ្រ្ចាំដើមទន្ទ្រានខែត្រលាយប្រឡប់នឹងអាចម៍គោ ។ ពេលដែលខ្ញុំដើរកាប់ដើមទន្ទ្រានខែត្រតាមវាលស្រែ ខ្ញុំឃើញពុកម៉ែមាមីងសស្រាក់សស្រាំលើកទំនប់ដីកប្រឡាយខ្វាត់ខ្វែង ។ កាលពីដំបូងខ្ញុំឃើញមានមីក្រូចាក់សំឡេងទ្រខ្មែរកំដរការងារ ប៉ុន្តែក្រោយមកពុំមានឮអ្វីក្រៅអំពីផ្លែចបទន្លិចដីតែប៉ុណ្ណោះ ។ មួយថ្ងៃៗមានអ្នកឈឺច្រើននាក់ ពិសេសស្ត្រីភេទ អង្គុយដកសក់ កោសខ្យល់ដកស្លឹកត្រចៀក អ្នកខ្លះផងឹតមុខដួលនៅនឹងកន្លែងដោយពុំមានគ្រូពេទ្យឬថ្នាំព្យាបាលឡើយ ។ នៅពេលដែលឃ្លាំងស្តុកជីពេញត្រូវកើបជញ្ជូនទៅដាក់តាមវាលស្រែទាល់តែអស់ទើបកាប់បញ្ចូលជាថ្មី ។ ពេលកាយជញ្ជូនជីចេញពីស្តុកនេះ មានកុមារខ្យល់ចាប់ផងឹតមុខស្ទើររាល់ថ្ងៃ ដោយសារសុខភាពខ្សោយនិងចំហាយក្តៅភាយចេញពីជីមានក្លិនឆ្អួលអាក្រក់ ពិបាកទ្រាំ ។

នៅតាមផ្ទះស្ងាត់ជ្រងំដូចពាក្យចាស់ថា "មានផ្ទះឥតមនុស្សនៅ មានផ្លូវឥតមនុស្សដើរ" ។ ប្រជាជនទាំងក្មេងទាំងចាស់ចេញទៅធ្វើការតាមមុខព្រួញរៀងខ្លួន ។ ក្រុមគ្រួសារបានជួបគ្នាខ្លះៗតែវេលាយប់ប៉ុណ្ណោះ ។ សមាជិកគ្រួសារខ្ញុំកើតជំងឺស្បែកកមរមាស់និងទឹកស៊ីជើង គ្មានថ្នាំព្យាបាលក្រៅអំពីបូតស្លឹកអំពិលដាំទឹកផ្ងូតនិងរកផ្លែមាក់ក្លឿមកលាបឡើយ ។

ពេលយប់មួយនោះខ្ញុំចាំយ៉ាងច្បាស់ ។ យប់ជ្រៅទៅហើយខ្ញុំនៅតែម្នាក់ឯងគត់ ។ មេឃភ្លៀងផងឹតឈឹង ផ្គរបន្ទោរភ្លែតៗរន្ទះបាញ់ដើមត្នោតវាលស្រែក្រោយផ្ទះលាន់ស្ទើរបែកត្រចៀក ។ ខ្ញុំភ័យណាស់ស្រែករកម៉ែឲ្យជួយ ខ្ញុំហេវណាស់ ញ័រខ្លួនដូចកូនសត្វ ។ ចាំស្តាប់ស្នូរជួងបាយក៏មិនឮ ។ ភ្លៀងបន្ថយតំណក់ទឹកពេលនោះទើបឮស្នូរជួងបន្ទឺពីរោងបាយ ។ ខ្ញុំចេញដំណើរយ៉ាងលំបាកទៅទទួលរបបអាហារ ។ ពុទ្ធោ! ចុងភៅចែកបេកឲ្យម្នាក់ៗមួយផ្លែប៉ុណ្ណោះ ។ យប់នេះខ្ញុំហេវណាស់ ស្ទើរដាច់ពោះស្លាប់ ។ ភ្លៀងរាំងដាច់គ្រាប់ ព្រះចន្ទចាំងពន្លឺល្អះៗ ។ សត្វមៀម ខ្វែងស្រាកស្រែកយំនៅក្រោយផ្ទះ ។ ខ្ញុំខ្លាច ខ្ញុំឃ្លានណាស់ ។ មួយសន្ទុះទើបម្តាយខ្ញុំមកដល់ផ្ទះ ។ ខ្ញុំយកពូថៅទៅកាប់កូនត្នោតដើម្បីយកគមមកហូបបំពេញក្រពះ ។ ខ្ញុំអស់កម្លាំងល្ហិតល្ហៃស្ទើរតែលើកពូថៅកាប់មិនបាន ។

ការងារធ្វើជីត្រូវផ្អាកសិន កុមារសំដៅមុខព្រួញមួយទៀតគឺដកសំណាប ។ ពីដំបូង ប្រធានក្រុមឲ្យដកសំណាបពីរដំប (៨កណ្តាប់) បន្ទាប់មកបីដំប រហូតដល់ប្រាំពីរដំប ។ ដៃខ្ញុំពងបែកស្ទើរគ្រប់ម្រាម ក្តាប់សំណាបមិនចង់កើត ។ ពេលល្ងាចអូសកណ្តាប់ ឬស្ទូង ឬកាយរន្ធកណ្តុរ ។ យូរៗម្តង ប្រធានកងចាត់ឲ្យដើរប្រមូលដីលាមកមនុស្សលាយជាមួយនឹងផេះហៅថាជីលេខមួយ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការងារក្តៅគគុកប្រហាក់ប្រហែលនឹងកម្លាំងស្រួចដែរ ។ យើងបានបាយហូបតែពីរបីខែនៅរដូវប្រមូលផលប៉ុណ្ណោះ ក្រៅពីនេះបបររាវទៅៗរហូតស្ទើរគ្មានគ្រាប់អង្ករ ។ រដូវដែលទុរ្ភិក្សបំផុតនោះគឺរដូវដកស្ទូង ។ ថ្ងៃណាក៏បបរលាយត្រកួន លាយដំឡូង លាយផាង ត្រាវ រាវកក្តុក របបមួយពេលមួយវែកឬពីរវែក ពោតក្រហមមួយ ឬចេកណាំវ៉ាមួយ ។ ខ្ញុំហេវណាស់ដើរស្ទើរមិនរួច ញ័រក្បាលជង្គង់ ស្ងួតបំពង់ក ។ បើមិនប្រឹងធ្វើការងារ អង្គការថា ធ្វើពុតជាឈឺ ចិត្តមិនដាច់ខាតឈឺសតិអារម្មណ៍ ពេលនោះចុងភៅនឹងផ្តាច់របបអាហារ ។ ពេលខ្ញុំចុះធ្វើការតាមវាលស្រែ ខ្ញុំតែងបេះស្លឹកថ្នឹង ផ្លែជើងចាប ផ្លែសាវម៉ាវព្រៃ ហូបសម្រន់ក្តីស្រេកឃ្លាន ។ ជួនកាលម្តាយខ្ញុំរកបានគល់ចេក គល់ល្ហុងលួចស្ងោរហូបយប់ៗ ។ នៅរដូវស្រូវដើមពេលយប់ស្ងាត់ ខ្ញុំលួចចូលទៅក្នុងស្រូវដើម្បីដកកំដើមស្រូវហូប ។ ពេលខ្លះមានជំងឺរាករូស ប៉ុន្តែខ្ញុំទ្រាំទៅធ្វើពលកម្មទាំងល្ហិតល្ហៃ ។ រដូវស្រូវទុំ ខ្ញុំទៅលួចបូតស្រូវនៅវេលាយប់ យកមកលីងបុកហូប ។ បូតបានស្រូវយកមកលីងកម្មោចហើយបុកឲ្យម៉ត់ដូចកន្ទក់ ។ ពេលហូបត្រូវផឹកទឹកបណ្តើរ បើពុំដូច្នោះទេត្រូវឈ្លក់ខ្យល់ ឬក៏ស្អិតបំពង់កស្ទុះដង្ហើម ។ ទង្វើបែបនេះបើអង្គការដឹងនឹងត្រូវចាប់យកទៅដាក់សហករណ៍ ចងស្លាបសេក វាយនឹងខ្សែ

គឺ បង្អត់អាហារ ។

នៅព្រឹកមួយ ខ្ញុំឃើញរទេះគោជាច្រើនដឹកមនុស្សមួយចំនួនត្រៀមចេញដំណើរពីភូមិ ។ នៅលើរទេះមួយ ខ្ញុំឃើញមិត្តភក្តិខ្ញុំម្នាក់ឈ្មោះ អាឡុង ។ វាស្រែកប្រាប់ខ្ញុំថាវាទៅនៅដីថ្មី ហើយចាំថ្ងៃក្រោយវាមកលេង ។ ខ្ញុំឃើញវាលើកដៃគ្រវីលាដូចជានឹកសង្វេគ រលីងរលោងទឹកភ្នែក ។ ពេលដែលខ្ញុំទៅធ្វើការ កុមារខ្លះមិនឃើញមក ។ មេកងប្រាប់ឲ្យកុមារខិតខំធ្វើការថែមទៀត ព្រោះកម្លាំងមួយចំនួនត្រូវដកទៅតាមឪពុកម្តាយទៅនៅដីថ្មី ។

របបអាហារមានសភាពយ៉ាប់ទៅៗ ។ ជួនកាលយើងបានទទួលតែដំឡូងមីមួយដុំ ពោតក្រហមស្ងោរមួយវែក ក្តួចមួយកូនចាន សម្រាប់មួយពេល ។ ជួនកាលចុងភៅច្រោះជាតិពុលរបស់ក្តួចមិនអស់ បណ្តាលឲ្យពុលក្អួតចង្អោរពេញមួយភូមិ ។ មានអ្នកស្រុកស្លាប់ស្ទើររាល់ថ្ងៃព្រោះអត់អាហារ ។ បុរសម្នាក់ជាប្រជាជនថ្មី មានជំងឺហើយស្រែកទាររកបាយហូបរហូតដល់ដាច់ខ្យល់ស្លាប់ ។

ខ្ញុំឃើញអង្គការដឹកប្រជាជនថ្មីទាំងរទេះៗដូចមុនទៀត ។ ម្តងនេះ ទឹកមុខរបស់អ្នកទាំងនោះស្រងូតស្រងាត់ក្រៀមក្រំខុសពីពេលមុនៗ ។ ពីរបីថ្ងៃក្រោយ ប្រធានភូមិប្រាប់ប្រជាជនឲ្យទៅយកជ័យភណ្ឌនៅរោងបាយ ។ ជ័យភណ្ឌទាំងនោះមានសម្លៀកបំពាក់ចាស់ៗ ស្បែកជើង និងសាក់កាដូ ។ គ្រួសារខ្ញុំបានកន្សែងពោះគោខ្មៅពក្លក់មួយ ។ ម៉ែប្រាប់ថា ខោអាវទាំងនោះជារបស់អ្នកដប់ប្រាំពីរមេសាដែលអង្គការដោះទុកមុននឹងសម្លាប់ ។ ខ្ញុំសួរគាត់ថា ម៉េចម៉ែដឹង? ម៉ែប្រាប់ថា មីងម្នាក់ (មិនចាំឈ្មោះ) បានទទួលអាវរបស់កូនគាត់ គាត់បានប៉ះនិងរៀបចំឲ្យដោយផ្ទាល់ដៃដែលមុនពេលកូនគាត់ចេញដំណើរទៅ ។ តាំងពីបានដឹងរឿងនេះ ខ្ញុំមិនហ៊ានប្រើប្រាស់កន្សែងពោះគោនោះទៀតឡើយ ព្រោះខ្លាចខ្មោចលង ។

ថ្ងៃមួយ ពេលដែលខ្ញុំទៅដកសំណាបនៅខាងជើងភូមិក្បែរវត្តចាស់ ខ្ញុំឃើញមនុស្សពីរនាក់កំពុងវាយកម្ទេចរូបបដិមាព្រះពុទ្ធម្នាក់ពីលើបល្ល័ង្ក ។ រូបសំណាកព្រះពុទ្ធនិងសាឡុំត្រូវវាយបំផ្លាញខ្ទេចខ្ទីរាបដល់ដី ។ មិនយូរប៉ុន្មានទីកន្លែងនេះក្លាយជារោងចិញ្ចឹមជ្រូក ។

នៅឆ្នាំ១៩៧៧ នារដូវស្រូវដើម ប្រធានភូមិចាស់ឈ្មោះ ម៉ង់ ត្រូវអង្គការផ្លាស់ចេញ ហើយឲ្យទៅរៀនសូត្រ ។ ប្រធានភូមិថ្មីបានមកជំនួស ។ ប្រជាជនបានខ្សឹបខ្សៀវគ្នាថា ប្រធានភូមិនេះមកពីតំបន់និរតី ព្រោះនិយាយរដឺនៗ ។ ជាបន្តបន្ទាប់ អ្នកដែលជាប់ខ្សែប្រធានភូមិចាស់ត្រូវអង្គការស្នើឲ្យទៅរៀនសូត្រ ។ ប្រធានក្រុមដែលតែងតាំងថ្មីឈ្មោះ ហូរ ជាជនពិការបានកាន់អំណាច ។ ប្រធានក្រុមនេះធ្លាប់មានទំនាស់ជាមួយប៉ាខ្ញុំកាលពីឆ្នាំកន្លងទៅ អំពីគោរបស់គាត់ត្រូវគោរបស់ខ្ញុំដេញជល់ឲ្យដាច់ពីចំណង ។ ប្រធានថ្មីនេះចាប់ផ្តើមសងសឹកដោយបញ្ជាឲ្យប៉ាខ្ញុំធ្វើការគ្មានពេលសម្រាក ។ ល្ងាចមួយ គាត់បានបញ្ជាឲ្យប៉ាទៅដឹកស្រូវទាំងយប់ តែប៉ាបានអង្វរសុំចាំព្រឹកសិន ។ ដោយបានលេសនេះ ប្រធានក្រុមបានមកគំរាមកំហែងដោយចោទថា ប៉ាហ៊ានប្រឆាំងនឹងមាគ៌ាអង្គការ ទុកក៏មិនចំណេញ ដកចេញក៏មិនខាត ។ មិនបានប៉ុន្មានថ្ងៃផង ប្រធានក្រុមបានប្រាប់ឲ្យប៉ាខ្ញុំទៅប្រជុំនៅវេលាយប់ ។ យប់ជ្រៅបន្តិច ស្រាប់តែឮសំឡេងស្រែកហៅប៉ាឲ្យទៅប្រជុំជាបន្ទាន់ ។ ប៉ាដែលកំពុងដេកសន្ធឹងសន្ធៃ ក្រោកចេញដំណើរទាំងទម្រេតទម្រោត ស្លៀកខោខ្លីពាក់អាវពណ៌ខ្មៅ ។ ម្នាក់ៗក្រៀមក្រំតាំងពីដឹងថាប៉ាត្រូវអង្គការហៅទៅប្រជុំម្ល៉េះ ព្រោះអ្នកដែលអង្គការហៅទៅប្រជុំឬទៅរៀនសូត្រ មិនដែលត្រឡប់មកផ្ទះជារៀងរហូត ។ បងប្រុសខ្ញុំពីរនាក់បានលបចេញដំណើរតាមពីក្រោយ ។ មួយសន្ទុះធំឃើញបងប្រុសត្រឡប់មកវិញក្នុងសភាពភ័យស្លន់ស្លោ យំអណ្តឺតអណ្តក និយាយស្ទើរមិនចេញ ។ បងបានប្រាប់ថា ប៉ាត្រូវឈ្លបចាប់ចងស្លាបសេកបណ្តើរលើខ្នងទំនប់យកទៅបាត់ហើយ ។ មេឃងងឹតឈឹង ផ្គរបន្ទោរភ្លៀតៗ ស្ថានភាពគ្រួសារស្ថិតក្នុងទម្ងន់ភ្នំទុក្ខសោក ។ ទាំងអស់គ្នាបានពិភាក្សាដោយរន្ធត់ញាប់ញ័រ ។ ប្រហែលមួយសន្ទុះ បងទាំងពីរចេញដំណើរទៅរកឪពុកមាម្នាក់ដែលត្រូវជាប្អូនបង្កើតរបស់ប៉ា ។ ឪពុកមានេះឈ្មោះ វើង គាត់រស់នៅភូមិថ្មី ឃុំឈូកខ្សាច់ ដែលមានចម្ងាយប្រហែលប្រាំបីគីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ ។ បងទាំងពីរចេញដំណើរក្នុងសភាពភ័យស្លន់ស្លោ ចុះទឹកប្រឫងកាត់ស្នាមភ្លោះមុខផ្ទះ ហើយក៏បាត់ស្រមោលក្នុងវាលស្រូវដែលកំពុងធ្វើខ្នន ។ គាត់

ទាំងពីរមិនហ៊ានធ្វើដំណើរតាមផ្លូវព្រោះខ្លាចឈ្លបឃើញ ។ បងទាំងពីររត់កាត់វាលស្រែធំល្វឹងល្វើយ ដើរកាត់ទឹកកាត់ភក់ឆ្លងអូរត្រពាំង ទាំងយប់ងងឹតឈឹងទាំងព្រលឹងចុងសក់ ។ ខ្ញុំនិងម៉ែមិនបានដេកពួនទេ អង្គុយយំកើតទុក្ខរង់ចាំដំណឹងពីបងៗ ។ ប្រហែលម៉ោងបីទៀបភ្លឺទើបបងទាំងពីរត្រឡប់មកវិញ ។ ខ្ញុំឃើញគាត់លំបាកខ្លាំងណាស់ មុខស្លេកស្លាំង ញ័រខ្លួនទទ្រើកទទឹកជោក សក់ក្បាលក្រញេងក្រញោង ខោអាវរហែករយ៉ី ដើរខ្ញើចៗព្រោះមុតបន្លា ។ បងប្រុសទីមួយនិយាយផុតៗប្រាប់ម៉ែថា «ខ្ញុំបានទៅដល់ផ្ទះចឹក (ពូ) ហើយ ប៉ាត្រូវគេយកទៅដាក់នៅវត្តជ្រង ចឹករើងបានពឹងគេឲ្យទៅជួយហើយ» ។ ចឹករើងនេះជាជាងដំដែក ផ្ទះគាត់នៅជាប់នឹងបរិវេណវត្តជ្រងដែលជាកន្លែងឃុំឃាំងអ្នកទោស ហើយគាត់មានផ្ទះនៅក្បែរនឹងផ្ទះ ពូវឿន ។ ពូវឿន ជាក្រុមសម្លាប់មនុស្សនៅវត្តជ្រងនេះ ។ ចឹករើងបានទៅសុំអង្វរពូវឿនឲ្យជួយដោះលែងប៉ា ។ ពូវឿន បាននាំចឹករើង ទៅជួបប៉ាដែលជាប់ខ្នោះដេកនៅអែបបល្ល័ង្កព្រះ ។

មិនទាំងបានសម្រាកបន្តិចផង ម៉ែនិងបងៗត្រូវចេញទៅធ្វើការតាមមុខព្រួញរៀងៗខ្លួន ។ ឯខ្ញុំព្រឹកនេះមិនបានទៅធ្វើការទេ ព្រោះគ្រុនក្តៅខ្លួន ។ ខ្ញុំឈឺក្បាលខ្ទោកៗ ព្រឺរងាៗ ហេវស្ទើរដើរមិនរួច ។ ខ្ញុំរើសក្តីបដូងយកមកទំពា ។ ថ្ងៃខ្ពស់បន្តិចប្រធានក្រុមដើរចូលមក ។ ខ្ញុំភ័យស្ទើរសន្លប់បាត់ស្មារតី ញ័រអស់ដងខ្លួន ។ ប្រធានក្រុមសួរខ្ញុំដោយសំឡេងខ្លាំងៗ «ម៉េចបានជាអ្នកមិនទៅធ្វើការ?» ខ្ញុំឆ្លើយដោយរន្ធត់ថា «ខ្ញុំគ្រុនទៅមិនរួច» ។ គាត់គំហក «អាអ្នកធ្វើពុតខ្ជិល គ្មានសតិអារម្មណ៍ ពូជអាខ្មាំងវាមិនដែលស្មោះត្រង់ទេ» ។ ខ្ញុំភ័យញាប់ញ័ររហូតដល់រាកនោមដាក់ខោ ។ ខ្ញុំពិតជាគ្រុនហើយហេវខ្លាំងណាស់ ដេកអង្គុញដើងចាំស្តាប់ស្នូរជួងហូបបាយ ។ សម្តីចុងក្រោយរបស់ប្រធានក្រុមបានគំរាមថា «បីថ្ងៃទៀតឲ្យទៅតាមឪអ្នក» ។ ខ្ញុំចេះតែគិតថាបីថ្ងៃទៀតអង្គការដោះលែងប៉ាខ្ញុំ ឬក៏យកគ្រួសារខ្ញុំទៅសម្លាប់


ការដ្ឋានលើកទំនប់ ជីកប្រឡាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ចោល ។ កំពុងតែគិតស្រាប់តែស្ទូរជួងបន្ទឹពីរោងបាយ ខ្ញុំដូចជាភ្លេចអស់ភាពទុក្ខព្រួយ ក្រោកដើរទៅហូបបបរ ។ ពុទ្ធោ! ចុងភៅផ្ដាច់របបខ្ញុំ ។ គេថាខ្ញុំខ្ជិល មិនធ្វើការ ។ ខ្ញុំស្រវាំងភ្នែក ធេងធោងស្ទើរត្រឡប់មកវិញមិនរួច ។ ហេវណាស់ អស់កម្លាំងល្វិតល្វៃ គ្មានអ្វីហូបទេ ខ្ញុំឈឺក្បាល ក្ដៅខ្លួន ខ្ញុំស្រែកហៅម៉ែឲ្យជួយ ។ ខ្ញុំចុះក្នុងត្រពាំងបេះផ្លែស្រវាគោក ផ្លែព្រលឹត យកមកហូប ។ ម៉ែមកដល់ផ្ទះ ខ្ញុំយំប្រាប់ម៉ែ ម៉ែមិនអាចជួយកូនបានក្រៅពីបង្ហូរទឹកភ្នែកឡើយ ។ ពេលថ្ងៃខ្ញុំខំប្រឹងចេញទៅធ្វើការទាំងអត់អាហារ ។ ខ្ញុំហត់ណាស់ ថប់ៗដង្ហើម ។ ពេលយប់ម៉ែបានស្ងោរគល់ចេកឲ្យខ្ញុំហូប ។ ម៉ែនិយាយទាំងទឹកភ្នែកថា «ពីរបីថ្ងៃទៀតគេយកគ្រួសារយើងទៅវាយចោលតាមឪឯងហើយ» ។ ខ្ញុំយំក្ដុកក្ដួលស្ទើរស្ទះដង្ហើម ។ ណាមួយឃ្លាន ណាមួយឈឺ ណាមួយភ័យ ។ ពុទ្ធោ! តើអ្នកណាមិនតក់ស្លុត មិនភ័យរន្ធត់នឹងព្រឹត្តិការណ៍ដ៏មហាសោកសៅបែបនេះ ។ មើលទៅម៉ែស្គមស្គាំង ភ្នែករូង ដៃជើងខ្មៅពក្ក ឯខ្ញុំមានតែស្បែកដណ្ដប់ឆ្អឹង ដើរស្ទើរព័ន្ធជើង ដើរឡើងថ្នល់មិនចង់រួច ចុះពីលើថ្នល់រកកលដាំក្បាលទៅមុន ។ ហូបចុកមិនស្មើនឹងសត្វតិរច្ឆាន បង្ខំឲ្យធ្វើការលើសពីសត្វគោក្របី ជីវិតរង់ចាំតែសេចក្ដីស្លាប់ ។ តើនេះហើយឬជាឋាននរក?

ចូលដល់ពាក់កណ្ដាលថ្ងៃទីពីរ ស្រាប់តែឃើញឪពុកមារបស់ខ្ញុំនិងពូម្នាក់ទៀតមកដល់ផ្ទះខ្ញុំ ។ គាត់បានប្រាប់ឲ្យគ្រួសារខ្ញុំរៀបចំអីវ៉ាន់ដើម្បីទៅរស់នៅជាមួយគាត់នៅភូមិថ្មី ។ ខ្ញុំមិនបានដឹងហេតុការណ៍ដែលបណ្ដាលឲ្យសភាពការណ៍ផ្លាស់ប្ដូរយ៉ាងនេះទេ ។ ពេញមួយល្ងាច ក្រុមគ្រួសារខ្ញុំនិងគ្រួសារម្ដាយមីងខ្ញុំមិនទៅធ្វើការទេ ត្រៀមរៀបចំទៅរស់នៅភូមិថ្មី ។ ព្រឹកព្រហាមស្អែកឡើង ខ្ញុំឃើញប្រធានក្រុមដឹកគោដែលបានដកហូតមកប្រគល់ឲ្យវិញ ។ ថ្ងៃខ្ពស់បន្តិចទើបឃើញពូដែលមកពីម្សិលមិញមកទទួលចេញដំណើរ ។

មកដល់ភូមិថ្មី ឃុំឈូកខ្សាច់ ខ្ញុំឃើញប៉ាកំពុងដេកឆ្អើរភ្លើងនៅលើគ្រែកញ្ចាស់មួយ ។ មុខមាត់របស់ប៉ាហើមស្ពុរដងខ្លួនដាំប៉ុនៗបីផ្លាប់ កដែកជើងហើមប៉ោង ខ្លួនប្រាណសម្បុរខ្មៅប្រផេះមើលមិនចង់យល់ថាជាមនុស្ស ។ ឃើញមុខកូនប៉ាខំប្រឹងងើបអង្គុយយ៉ាងលំបាក ។ ប៉ានិយាយដោយសំឡេងខ្សាវៗ និងក្អកខុងៗ ។ សភាពរបស់លោកប៉ាចាប់អង្រួនកូនឲ្យស្ថិតនៅក្នុងសភាពចុកចាប់ សង្វេគ ក្រៀមក្រំ រកអ្វីមកប្រៀបពុំបាន ។ យើងបានជួបជុំគ្នាមែន ប៉ុន្តែស្ថានភាពនៅតែគ្របដណ្ដប់ដោយសមុទ្រទុក្ខនៅឡើយ ។ ជីវិតប៉ាមិនដឹងជាបានរស់ឬក៏យ៉ាងណាទេ ។ ពេលប៉ាក្អកម្ដងៗធ្លាក់លោហិតក្រហមច្រាល ។ លោកប៉ាត្រូវបានដោះលែងពីមន្ទីរឃុំឃាំងដោយសារមានអន្តរាគមន៍ពីប្រធានភូមិថ្មីឈ្មោះ កែវ ចេន និងសន្តិសុខពីរនាក់ឈ្មោះ រឿន និង ហយ ដែលត្រូវបានឪពុកមាពីងឲ្យជួយ ។ ប្រធានភូមិនេះក៏បានសម្រួលឲ្យក្រុមគ្រួសាររបស់ខ្ញុំបានមករស់នៅភូមិថ្មីដែរ ។

ដោយគុណទឹកដោះម្ដាយថ្លៃ ជីវិតគ្រួសារខ្ញុំបានចាកផុតពីអន្លង់មរណៈមួយគ្រា ។ ខ្ទមតូចមួយសង់ជាប់នឹងជង្រុកស្រូវក្រោមដើមពុទ្រា ជាលំនៅថ្មីនៃគ្រួសារខ្ញុំ ។ ក្រោយពីសុខភាពបានធូរស្រាល ប៉ាមានការងារជាជាងរទេះ នៅជាប់នឹងរោងជីដែករបស់ឪពុកមា ។ ម្ដាយខ្ញុំធ្វើស្រែក្នុងសហករណ៍ ក្រោយមកទៅកាប់រំចេកត្បាញកន្ទេលនៅភូមិសំរោងទល់ឡោ ។ បងប្រុសធ្វើការក្នុងកងចល័ត ឯខ្ញុំជាក្រុមកុមារ ។ មកដល់ទីនេះ ការងាររបស់ខ្ញុំធូរស្រាលជាងមុនច្រើន ។ រដូវវស្សា ក្រុមរបស់ខ្ញុំដើរដកស្នោស្រូវ ជញ្ជូនដីដាក់តាមស្រែ ។ រដូវស្រូវទុំ ជាន់អាចម៍គោវាសធ្វើលានបញ្ជាន់ស្រូវ ជញ្ជូនកណ្ដាប់ស្រូវទៅរៀបជាផ្ទឹម បេះសណ្ដែក កាច់ពោត ឬក៏រើសកក្កួរស្រូវ ។ ទោះបីរបបអាហារហូបមិនឆ្អែតក៏ដោយ ក៏នៅទីនេះអាចរកអ្វីហូបបានស្រួលជាងកាលនៅភូមិចាស់ដែរ ។ រដូវពោត សណ្ដែក អាចលួចសៀតនឹងចង្កេះខោបានខ្លះៗ ។ ពេលទំនេរលួចស្ទូចត្រី ចាប់ខ្យង ក្ដាម ដើរគាស់ដំឡូងព្រៃ ។

ខ្ទមខ្ញុំនៅជាប់នឹងបរិវេណមន្ទីរឃុំឃាំងវត្តជ្រង និងនៅមិនលើសពីមួយរយម៉ែត្រពីព្រៃបន្ទេរាំង កន្លែងពិឃាតអ្នកទោស ។ កាលដែលប្រឡាយនៅខាងលិចភូមិមិនទាន់ជីក ខែប្រាំងខ្វះទឹកណាស់ ។ ប្រជាជននៅម្ដុំផ្ទះខ្ញុំទៅប្រើទឹកអណ្ដូងវត្តជ្រងគ្រប់ៗគ្នា ។ ពេលព្រលប់ខ្ញុំទៅដួតទឹក បានទៅលួចមើលអ្នកជាប់ទោសតាមចន្លោះធាងដូង ។ អ្នកទោសជាប់ខ្នោះដៃខ្នោះជើងអង្គុយរណ្ដូករណែល ។ តាមខ្ញុំកត់សម្គាល់មើល អ្នកទោសដែល

ជាប់នៅទីនេះប្រហែលជាបានរស់មិនលើសពីពីរថ្ងៃទេ ត្រូវសម្លាប់ចោលអស់ហើយ ។ ពេលរសៀលមួយ ខ្ញុំបានឡើងយកកូនសត្វលលកនៅលើចុងស្វាយក្បែរអណ្តូងទឹកវត្តជ្រង ។ ពេលនោះកូនលលកមួយហើរធ្លាក់ចូលទៅក្នុងទីឃុំឃាំង ។ ខ្ញុំលួចចូលតាមទ្វារដែលបាំងដោយស្លឹកដូង ទៅរើសកូនលលក ។ ពេលនោះខ្ញុំឃើញមនុស្សប្រុសពីរនាក់ជាប់ខ្នោះជើង អង្គុយសណ្តូកជើងផ្អែកនឹងជញ្ជាំង មនុស្សស្រីម្នាក់ទៀតជើងជាប់ច្រវាក់ កំពុងបំបៅកូន ហើយមានក្មេងម្នាក់ដេកស្តូកកើយជើងរបស់គាត់ ។ ខ្ញុំឃើញស្ត្រីនោះដោះអាវលែងខ្លួនទទេ ប្រហែលជាយកអាវទៅដណ្តប់ឲ្យកូនដែលដេកកើយចុងជើងនោះក៏មិនដឹង ។ ស្អែកឡើងពេលថ្ងៃត្រង់ ខ្ញុំទៅដួតទឹកក៏លួចមើលអ្នកទោសម្តងទៀត ប៉ុន្តែខ្ញុំមិនឃើញនរណាម្នាក់ឡើយ ។ លួចមើលអ្នកទោសនៅទីនេះមិនពិបាកទេ គ្រាន់តែយកចំណីឲ្យលលកខ្មោចដែលក្រុមសន្តិសុខចិញ្ចឹមដាក់ទ្រុងព្យួរនៅមាត់ទ្វារ ហើយលួចក្រឡេកភ្នែកតែបន្តិចនឹងឃើញទិដ្ឋភាពក្នុងទីឃុំឃាំងនេះមិនខាន ។

ពេលយប់ ជួនកាលខ្ញុំឮសម្រែកអ្នកទោសល្ហើយៗកណ្តាលយប់ជ្រៅ ។ ពេលខ្លះទៀត ខ្ញុំឮសូរព្រួនង់ដែលឈ្លបខ្មែរក្រហមវាយសំពងទៅលើកញ្ចឹងកអ្នកទោស ។ ឈ្មោះ វឿន ជាអ្នកសម្លាប់មនុស្សនៅទីនេះ មានផ្ទះនៅក្បែរខ្ទមខ្ញុំ ។ ពេលព្រឹកខ្ញុំឃើញគាត់ឡើងបំបៅទឹកត្នោតជូរ ។ ពេលរសៀលគាត់ដើរបើកដុំថ្មចាប់កង្កែបអាចម៍គោអាំងក្លែមទឹកត្នោតជូរ ។ នៅនឹងចង្កេះរបស់គាត់មានកាំបិតចិតត្នោតមួយ ។ គាត់ស្លៀក ខោខ្លីមួយដែលរួញស្ទើរដល់គល់ភ្លៅ ។ ពេលព្រលប់ៗ គាត់អង្គុយក្លែមទឹកត្នោតជូរជាមួយនឹងមនុស្សប្អូនប្រាំនាក់ទៀត ។ ខ្ញុំពុំមានអារម្មណ៍ខ្លាចគាត់ទេ ជួនកាលខ្ញុំសុំទឹកត្នោតគាត់ផឹក ហើយអង្គុយស្តាប់គាត់និយាយគ្នាអំពីការសម្លាប់អ្នកទោស ។

ខ្ញុំបានស្គាល់អ្នកសម្លាប់មនុស្សម្នាក់ទៀតឈ្មោះ ប៊ិន ។ ប៊ិន តែងតែមកព្រោកប្រាជ្ញនៅរោងដំដែក ។ គាត់យកស្លឹកត្នោតដែលគាត់រូបជាទម្រង់កាំបិតស្នៀត មកឲ្យជាងដំដែកធ្វើតាម ។ ខ្ញុំតែងតែឮ ប៊ិន និយាយអួតអាងពីការសម្លាប់មនុស្ស ។ គាត់មានឈ្មោះហៅក្រៅថា "ប៊ិនកំបុត" ព្រោះគាត់កំបុតស្លឹកត្រចៀកម្ខាង រស់នៅភូមិចាន់លុង ។ ខ្ញុំឮប្រជាជននិយាយថា ប៊ិន ត្រូវជាប្អូនរបស់គណៈតំបន់ឈ្មោះ កែ ពក ។

ខែប្រាំង ខ្ញុំទៅឃ្វាលគោ ។ គោមិនសូវស៊ីស្មៅនៅក្នុងព្រៃបន្ទាំងទេ ព្រោះស្មៅនៅនោះមានក្លិនស្អាប ។ ខ្ញុំឃើញរណ្តៅកប់ខ្មោចខ្លះហើមទុលដី រុយក្បាលខៀវរោមទ្រុបទ្រុលខ្លះស្រុតដីផតឃើញមាត់រណ្តៅ ។ នៅជាប់នឹងគល់ស្វាយព្រៃមានពីររណ្តៅដែលធ្វើឲ្យស្វាយនោះជ្រុះស្លឹកងាប់ ។ ខ្ញុំឃើញដំបង គល់ឫស្សីអន្ទូងដីការត្នោត ដែលសន្តិសុខប្រើសម្រាប់វាយក្បាលអ្នកទោសនៅប្រឡាក់ឈាមខ្មៅៗនៅឡើយ បោះចោលនៅក្បែរៗមាត់រណ្តៅ ។ ពេលយប់ខ្ញុំមិនសូវហ៊ានងើប បត់ជើងឡើយព្រោះខ្លាចខ្មោច ។

ជាញយៗ ពេលល្ងាចខ្ញុំតែងតែទៅលួចដួសទឹកប្រហុកនៅឃ្លាំងពាណិជ្ជក្បែររោងចុងភៅ ។ ថ្ងៃមួយ ខ្ញុំត្រូវខ្មែរក្រហមចាប់បានហើយបង្អត់បបរខ្ញុំមួយពេល ។ ក្រោយមក បងប្រុសខ្ញុំម្នាក់ក៏ត្រូវប្រធានចុងភៅផ្តាច់របបមួយថ្ងៃដែរ ដោយចោទថាឈឺបន្តិចបន្តួចមិនទៅធ្វើការ ខ្យល់ឱល (ឱ្យលដល់) ។ ខ្ញុំឈឺភ្នែកឡើងក្រហម ពេទ្យឈ្មោះ ស៊ូ បានឲ្យថ្នាំសូនមូលៗដូចអាចម៍ទន្សាយប្អូនប្រាំគ្រាប់ ហើយប្រាប់ថាឲ្យយកទឹកនោមលុបមុខ ។ ម្តាយខ្ញុំកើតជំងឺហើមខ្លួនក៏បានទទួលថ្នាំសូនអាចម៍ទន្សាយដែរ ។

ពេលខ្លះ ខ្ញុំឃើញម៉ែយកខោអាវកញ្ចាស់ៗមកដេរប៉ះ ។ មុននឹងប៉ះ ម៉ែត្រូវរុះហូតសរសៃអំបោះពីខោចាស់ប្រើការលែងកើតមួយដើម្បីយកសរសៃអំបោះខោធ្វើជាចេសសម្រាប់ដេរ ។ ពេលយប់យើងបំភ្លឺផ្ទះដោយអុជជ័រកៅស៊ូដែលមានក្លិនស្អុយ ។ ឪពុកពិសាបារី ប៉ុន្តែបារីគាត់ជក់រុំអំពីស្លឹកសង្កែ និងស្លឹកថ្កូវ ព្រោះពុំមានថ្នាំជក់ឡើយ ។ ពុំមានដែកកេះប្រើទេគឺមានតែបំពង់ប៉ុយប៉ុណ្ណោះ ។

វត្តជ្រងលែងជាមន្ទីរសន្តិសុខទៀតហើយ ទីនេះក៏ត្រូវខ្មែរក្រហមវាយកម្ទេចបំផ្លិចបំផ្លាញគ្មានសល់ ។ កាលពីមន្ទីរឃុំឃាំងនេះនៅដំណើរការ ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមថ្នាក់លើជិះឡានម៉ាកហ្ស៊ីប មាននីរសាពីរនាក់ ស្លៀកពាក់ខោអាវខ្មៅ បង់កក្រមា ពាក់ស្បែកជើងកង់ឡាន ពាក់មួករបប ប្រដាប់ដោយកាំភ្លើងអាកាស៊ុយបត់ ។ ខ្ញុំឮថាកម្មាភិបាលនេះឈ្មោះ ស៊ី ជាគណៈតំបន់ ។ ក្រោយមកខ្ញុំឮថាឈ្មោះ ស៊ី នេះក្បត់នឹង

អង្គការ ហើយត្រូវអង្គការកម្ទេចដោយដាក់គុកហើយបង្ខំឲ្យហូបបាយរហូតហាល់ស្លាប់នៅក្នុងមន្ទីរឃុំឃាំង ។

រវាងជាងពាក់កណ្ដាល១៩៧៨ មានកម្មាភិបាលភូមិភាគមកបោះទីតាំងនៅលើទួលទំនាបមួយចន្លោះភូមិថ្មីនិងភូមិចាន់ល្ហុង ។ នៅលើទួលនោះមានផ្ទះធំមួយព័ទ្ធជុំវិញដោយផ្ទះតូចៗជាច្រើន និងមានសន្តិសុខការពារយ៉ាងរឹងមាំ ។ ពេលយប់មានភ្លើងអគ្គិសនីបំភ្លឺរយៈពេលខ្លី ។ ប្រជាជនខ្សឹបខ្សៀវគ្នាថា អ្នកដែលនៅក្នុងផ្ទះធំនោះគឺជាគណៈភូមិភាគឈ្មោះ កែ ពក ។

យូរៗម្ដង ខ្មែរក្រហមបញ្ចាំងកុនឲ្យប្រជាជនទស្សនា ។ លើកណាក៏ដូចលើកណាដែរ ខ្សែភាពយន្តបង្ហាញអំពីពុកម៉ែបងប្អូនមីងមា សស្រាក់សស្រាំដកស្ទូង ច្រូតកាត់ លើកទំនប់ជីកប្រឡាយ បងៗកងទ័ពការពារព្រំដែន ។

នៅចុងឆ្នាំ១៩៧៨ អង្គការហៅប្រជាជនប្រជុំជាញឹកញាប់ ។ ខ្លឹមសារនៃការប្រជុំគឺផែនការនិងការប្ដេជ្ញាចិត្តវាយកម្ទេចអាខ្មាំងយួន ។ អង្គការបង្កើតពាក្យស្លោកផ្សេងៗ ដើម្បីប្រឆាំងយួនឈ្លានពាន ។ អង្គការបង្គាប់ឲ្យកុមារជេរយួនថា "អាយួនកន្ទុប ស៊ីកន្ទក់ដុះកន្ទុយ"...។ ពេលនេះនៅរោងបាយមានវិទ្យុកញ្ចាស់មួយ ។ ជារឿយៗ ខ្ញុំតែងតែទៅស្ដាប់វិទ្យុនៅពេលយប់ ។ វិទ្យុនេះគ្មានថ្មពិលដាក់ទេ ។ បើចង់ស្ដាប់ត្រូវរវៃកង់ខ្សែពានដែលបន្តដោយឌីណាម៉ូកង់ភ្ជាប់ទៅនឹងខ្នងកង់ ។ អ្នកស្ដាប់ត្រូវបណ្ដាក់គ្នារវៃម្នាក់ម្ដងៗ ។ ពត៌មាននៅក្នុងវិទ្យុសុទ្ធសឹងប្រាសចាកអំពីការពិត ។ ពត៌មានអួតសរសើរអំពីការបង្កបង្កើនផលស្រូវមួយហិកតាបីតោន ប្រជាជនហូបបរិបូណ៌ ដាំដំណាំចិញ្ចឹមសត្វបានប៉ុនណោះ ប៉ុនណោះ ជ័យជំនះលើខ្មាំងយួន មហាលោតផ្លោះ មហាអស្ចារ្យ...។ល។ ខ្ញុំនៅចាំបទចម្រៀងជាតិកាលពីសម័យនោះប៉ុន្មានម៉ាត់ដែរ "ឈាមក្រហមច្រាលស្រោចស្រពក្រុងវាលកម្ពុជាមាតុភូមិ..." ។

ប្រហែលពាក់កណ្ដាលខែធ្នូ ឆ្នាំ១៩៧៨ ខ្ញុំឮសូរគ្រាប់កាំភ្លើងផ្ទុះល្ហើយៗជារៀងរាល់ថ្ងៃ ។ ពេលនោះឮចាស់ៗនិយាយថា មានផ្កាយដុះកន្ទុយ ស្រុកខ្មែរយើងកើតសង្គ្រាមរឹករវ និងពាក្យរអេចរអូចពីនេះពីនោះកាន់តែច្រើនឡើងៗ ដូចជាថាមានខ្យងចេះរាំ កំពីសភ្លឺ កណ្ដុរសធ្លាក់ពីលើមេឃ មានអ្នកមានបុណ្យជិះសេះសមកពីទិសឦសាន មានភ្លើងហោះច្រាំពីរពណ៌...។ ដោយគំនិតក្មេងខ្ចី ខ្ញុំខ្លាចលែងហ៊ានចេញពីផ្ទះនៅពេលយប់ ។ ការទៅស្ដាប់វិទ្យុក៏ត្រូវអាក់ខាន ។ ភាពរំជើបរំជួលពីបញ្ហាស្រុកទេសកាន់តែខ្លាំងឡើងៗ ។ ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមជិះម៉ូតូសេអិល ឬជិះឡានហ្ស៊ីប រត់កៀសខ្លួនតាមដងផ្លូវ ។ មានទាហានបាក់ទ័ពរត់កាត់ភូមិនេះ ជួនកាលមកសុំបាយហូប ហើយនិយាយអំពីទាហានយួនវាយបុកចូលដាច់ខ្សែត្រៀមនេះខ្សែត្រៀមនោះ ។ ចុងខែធ្នូឆ្នាំ១៩៧៨ សភាពការណ៍កាន់តែកញ្ជ្រោកទ្រុឡើង ។ កន្លែងស្នាក់នៅរបស់គណៈតំបន់ឈ្មោះ កែ ពក មានសភាពស្ងាត់ច្រៀប កងការពារក៏ដូចជាមិនឃើញមាន មិនដឹងថាអ្នកទាំងអស់នោះរត់បាត់តាំងពីពេលណា ។ ពាក្យចចាមអារ៉ាមលេចឮជាបន្តបន្ទាប់ ។ ខ្លះថា អង្គការកេណ្ឌប្រជាជនឲ្យចូលព្រៃ ។ ខ្លះទៀតថា អង្គការហៅប្រជាជនទៅប្រជុំ រួចចុចមីនឲ្យផ្ទុះ ។ ខ្លះទៀតនិយាយថា សន្តិសុខយកប្រជាជនទៅសម្លាប់ដាក់ក្នុងអណ្ដូងម្ដងមួយភូមិៗ ។ អ្នកដែលបានស្ដាប់វិទ្យុរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឬវិទ្យុអាមេរិកាំងបានខ្សឹបខ្សៀវពីនេះពីនោះ ។ ប្រជាជនដែលទៅធ្វើការឆ្ងាយៗបានត្រឡប់មកជួបជុំគ្រួសារវិញ ។ ថ្ងៃទី០៥ឬ ០៦ ខែមករា ឆ្នាំ១៩៧៩ មានយន្តហោះបេហាសិបពីរ B-52 មួយគ្រឿងហោះខ្ពស់សន្ធឹម ។ យន្តហោះនេះបាញ់ផ្សែងឆ្នូតពណ៌សដូចពពកជារង្វង់លេខសូន្យយ៉ាងធំនៅលើផ្ទៃមេឃ ។ ប្រជាជននាំគ្នានិយាយថាលេខសូន្យនេះសន្មតថាស្រុកខ្មែរ យើងចប់សង្គ្រាមហើយ ។ ពេលនោះគ្រួសារដែលជាជំនិតនឹងកម្មាភិបាលខ្មែរក្រហមបាននាំគ្នាគេចខ្លួនចូលព្រៃជាបន្តបន្ទាប់ ។ នៅព្រឹកថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ នៅឯរោងបាយនិងឃ្លាំងពាណិជ្ជកម្ម ប្រជាជនពពាក់ពពូនដណ្ដើមយករបស់របរចានឆ្នាំង ស្រូវអង្ករយ៉ាងគគ្រឹកគគ្រេង ។ គ្រួសារខ្ញុំដណ្ដើមបានអង្ករខ្លះ ស្ករខ្លះ ប្រហុកខ្លះ ឯខ្ញុំដណ្ដើមបានចានដែកមួយធំ ចានខ្លះ និងឆ្នាំងតូចៗពីរ ។ ថ្ងៃបន្តបន្ទាប់ ប្រជាជនទៅដណ្ដើមយកអ៊ីៗជារបស់រួម ដូចជាគោ ក្របី ជ្រូក មាន់ទា រុះរើជង្រុក រុះរើរោងបាយ ។ នៅកន្លែងអង្គការគណៈតំបន់ក៏ឃើញប្រជាជននាំគ្នារុះរើលីសែងរបស់របរជាហូរហែដែរ ។ ប្រជាជននាំគ្នាបររទេះទៅរុះរើដឹកសម្ភារ ពិសេស

កៅស៊ូ ក្រែប នៅរោងចក្រអាញ៉ាម័យ ចំការអណ្តូង ។

ហូបរួម ដេករួម ស្លាប់រួម ត្រូវបញ្ចប់ទាំងស្រុងនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ។ ប្រជាជនដប់ប្រាំពីរមេសា ប្រជាជនចាស់ នៅក្នុងភូមិថ្មីនេះ បានវិលទៅរកស្រុកកំណើតជាបន្តបន្ទាប់ ។ គ្រួសារខ្ញុំក៏ប្រញាប់ប្រញាល់ចាកចេញដែរ ព្រោះខ្លាចទាហានប៉ុលពតគេកេណ្ឌឲ្យចូលព្រៃ ។ ក្រុមគ្រួសារខ្ញុំចាកចេញពីសំបុកមហាកម្សត់មកស្នាក់នៅបណ្តោះអាសន្ននៅភូមិឈូកខ្សាច់ ។ ដំណើរធ្វើរជើងតាមវាលស្រែ ខ្ញុំរែកទាកាប៉ាពីរក្បាលនិងកូនទាមួយកន្ត្រក ។ មកដល់ភូមិឈូកខ្សាច់ ខ្ញុំបានស្តាប់វិទ្យុជាមួយនឹងអ្នកស្រុកពត៌មានស្តីអំពីការវាយបោសសម្អាតកងទ័ពប៉ុលពត ។ មកដល់ពេលនេះទើបខ្ញុំដឹងថា មេដឹកនាំប្រទេសរយៈពេលប៉ុន្មានឆ្នាំនេះឈ្មោះ ប៉ុល ពត, អៀង សារី ។ បទចម្រៀងដែលខ្ញុំបានស្តាប់ដំបូងសែនពីរោះលន្លង់លន្លោចនោះ គឺបទ «ឱភ្នំពេញអើយ!» ។

នៅចុងខែមករា ឆ្នាំ១៩៧៩ គ្រួសារខ្ញុំបានមករស់នៅស្រុកកំណើតវិញ គឺភូមិក្រសាំងជ័យ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ មកដល់ផ្ទះចាស់ អ្នកម្តាយរលីងរលោងទឹកភ្នែក ។ ខ្ញុំយកទាកាប៉ាទៅរក្សាទុក ។ មុខរបរដែលគ្រួសារខ្ញុំផ្តើមក្នុងជីវិតថ្មីគឺធ្វើរទេះលក់ដូរជាស្រូវ អង្ករ ឬមាស ព្រោះប្រជាជនដែលធ្វើដំណើរត្រឡប់ទៅស្រុកកំណើតភាគច្រើនត្រូវការរទេះរុញឬរទេះអូស ។ ជីវិតថ្មីលើទឹកដីចាស់ចាប់កំណើតពីពេលនោះមក ។

ព្យុះសង្ឃរានៃរបបប៉ុលពតបានផុតរលត់ តែភាពសោកសង្រេងស្រងេះស្រងោចបែកបាក់ព្រាត់ប្រាស នៅតែដក់ជាប់ក្នុងអារម្មណ៍ខ្ញុំជានិច្ច ។ របបប៉ុលពតបានរុញច្រានប្រទេសកម្ពុជាឲ្យវិលត្រឡប់ក្រឡាប់ចាក់ថយក្រោយទៅរកសង្គមបែបបុព្វកាល ។ គ្រួសារបែកបាក់ព្រាត់ប្រាស ម្តាយព្រាត់កូន ប្រពន្ធព្រាត់ប្តី បងព្រាត់ប្អូន ផ្តាច់មនោសញ្ចេតនា ភាពថ្លៃថ្នូរជាមនុស្សត្រូវបានអង្គការប៉ុលពតកម្រិតឲ្យនៅប្រហាក់ប្រហែលនឹងសត្វតិរច្ឆាន ។ មានអាហារបានមួយលិឈ១ៗដូចសត្វឆ្មា ប៉ុន្តែធ្វើការធ្ងន់ជាងសត្វគោក្របី ។ អ្វីៗដែលមហាឃោរឃៅមហាទុយ៍ស ដែលសង្គមមនុស្សស្អប់ខ្ពើម ត្រូវបានប៉ុលពតយកមកសាបព្រោះក្នុងសង្គមកម្ពុជា ។ រស់ក្នុងចង្កូមមច្ចុរាជ ក្នុងពិភពឃោរឃៅ ក្នុងគុកឥតជញ្ជាំង ។ តើទុក្ខវេទនារបស់ខ្មែរបណ្តាលមកពីព្រហ្មលិខិតឬបាបកម្មពីបុព្វេ? អ្វីៗដែលកើតឡើងគឺបណ្តាលមកពីប៉ុលពតនិងបក្ខពួករបស់គេ ។ មេដឹកនាំតែប៉ុន្មាននាក់ប៉ុណ្ណោះបានធ្វើឲ្យប្រជាជនកម្ពុជារាប់លាននាក់ធ្លាក់ទៅក្នុងនរកលោកិយ ។ ប៉ុលពតបានបង្វែរប្រទេសកម្ពុជាឲ្យក្លាយជាទីវាលកប់ខ្មោចខ្មែរ ជាទីវាលពិឃាតមនុស្ស ជាដែនដីប្រកបដោយឈាមនិងទឹកភ្នែក ។

ក្នុងវ័យត្រឹមតែដប់ពីរឆ្នាំប៉ុណ្ណោះ ខ្ញុំបានឆ្លងកាត់របបនយោបាយដល់ទៅបួន ។ ហេតុអ្វីបានជាប្រទេសកម្ពុជាយើងផ្លាស់ប្តូររបបនយោបាយលឿនដូចផ្លាស់ប្តូរសម្លៀកបំពាក់យ៉ាងនេះ? លន់ ណុល ផ្តួលរំលំរបបរាជា ហើយបង្កើតរបបសាធារណរដ្ឋ ។ មិនទាន់បានប៉ុន្មានឆ្នាំផង ប៉ុលពតបានផ្តួលរំលំលន់ ណុល ហើយបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ។ កម្ពុជាប្រជាធិបតេយ្យមានដង្ហើមជិតបួនឆ្នាំត្រូវផ្តួលរំលំហើយបង្កើតរបបនយោបាយថ្មីមួយទៀត ។ ការផ្តួលរំលំនៃរបបនយោបាយនីមួយៗ ត្រូវយកឈាមប្រជាជនដាបពោះដីរទៅប្តូរ ។ តើផលដែលប្រជាជនកម្ពុជាទទួលបានពីការផ្លាស់ប្តូររបបនយោបាយដ៏ញឹកញាប់នេះគឺអ្វី?

ក្នុងនាមជាពលរដ្ឋខ្មែរម្នាក់ដែលធ្លាប់ទទួលរងថ្នបាក់ជាច្រើនផ្ទាំង ខ្ញុំគ្មានចង់បានអ្វីក្រៅពីការរស់នៅក្នុងសភាពស្ងប់ស្ងាត់តែប៉ុណ្ណោះ ។ សូមមគ្គុទ្ទេសក៍ខ្មែរប្រកាន់ខ្ជាប់នូវធម៌អហិង្សា មេត្តា ករុណា មុទិតា ឧបេក្ខា ចៀសវាងឲ្យឆ្ងាយពីរបបគ្រប់គ្រងបែបប៉ុលពត ហើយសម្លឹងមើលនិងយកតម្រាប់តាមប្រទេសជឿនលឿនក្នុងពិភពលោក ។ សូមប្រជាពលរដ្ឋខ្មែរគ្រប់រូបមេត្តាស្រលាញ់រាប់អានគ្នាជាបងប្អូន កុំប្រកាន់បក្ខពួក កុំមានចិត្តមានះរឹងរូស ត្រូវចេះរស់នៅក្នុងផ្លូវធម៌ ទើបស្រុកទេសរបស់យើងបានសុខសន្តិភាពយូរអង្វែង ។

កុមារនិងមិត្តយុវជនជាទីស្រលាញ់ មុននឹងអ្នកប្រព្រឹត្តអ្វីអ្នកត្រូវពិចារណា អ្នកត្រូវប្រកាន់ខ្លួនជាអ្នកថ្លៃថ្នូរ តម្កល់កិត្តិយសឲ្យខ្ពស់ជាងអ្វីៗស្រលាញ់ជីវិតមនុស្សឲ្យដូចស្រលាញ់កែវភ្នែករបស់យើង ។ ទោះបីអ្នកជួបការលំបាក អត់ឃ្លាន គ្មានហូប

តែអ្នកនៅតែប្រសើរជាងការរស់នៅរបស់ខ្ញុំក្នុងរបបខ្មែរក្រហមដែរ ។ អ្នកលំបាកមែន ប៉ុន្តែអ្នកនៅមានសង្ឃឹម ។ ចំណែកខ្ញុំលំបាកជាងអ្នកទ្វេដង ហើយមិនសង្ឃឹមថាបានរស់ដល់ថ្ងៃស្អែកផង ។ រហូតមកដល់ថ្ងៃនេះ សូម្បីតែការយល់សប្តិឃើញរបបនោះក៏ធ្វើឲ្យខ្ញុំមានអារម្មណ៍ភ័យរន្ធត់ដែរ ។ ដូច្នេះ សូមប្អូនកុមារ មិត្តយុវជនដែលរងទុក្ខសោកប្លុះដោយប្រការមិនល្អ មេត្តារួសរាន់ភ្ញាក់រឭកឡើង បោះបង់នូវទង្វើលាមកចេញដើម្បីរស្មីជីវិតគ្រាប់ពេជ្រសុភមង្គលកំពុងរង់ចាំអ្នក ។

ក្នុងនាមជាពលរដ្ឋម្នាក់ដែលទទួលរងនូវអំពើអយុត្តិធម៌ក្នុងរបបខ្មែរក្រហម ចង់បានតុលាការយុត្តិធម៌មួយដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ បង្កើតឡើងឲ្យបានឆាប់រហ័សដើម្បីវិនិច្ឆ័យទោសមេដឹកនាំនៃរបបខ្មែរក្រហមប៉ុលពត រកយុត្តិធម៌ជូនវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់និងអ្នកដែលរងគ្រោះក្នុងរបបវាលពិឃាតនេះ ។ ការកាត់ទោសមិនមែនជាការសងសឹកប្តុធ្វើឲ្យសង្គមខ្មែរបែកបាក់ឡើយ ផ្ទុយទៅវិញ គឺរកឲ្យឃើញនិងដាក់ទោសទណ្ឌដល់អ្នកដែលបានប្រព្រឹត្តកំហុស ហើយក៏ទុកជាមេរៀនដល់មេដឹកនាំខ្មែរក្រោយៗទៀត ។

**សខ ហេខ**

# គំនិតផ្ទាល់ខ្លួនខ្ញុំ ចំពោះដំណោះស្រាយប្រវត្តិសាស្ត្ររបបខ្មែរក្រហម

១) រាល់រឿងរ៉ាវអ្វីៗ រាប់ទាំងធ្ងន់ទាំងស្រាល វាបានកន្លងទៅជាយូរឆ្នាំហើយ សភាពការណ៍ស្រុកទេសបានផ្លាស់ប្តូរមុខមាត់ខ្លះៗហើយ បើសិនជាយើងចង់សម្លាប់មនុស្សមានការពាក់ព័ន្ធណាម្នាក់ក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យឲ្យស្លាប់បាត់បង់ជីវិត ឬក៏តម្រូវឲ្យមានទោសអស់មួយជីវិត ទន្ទឹមនេះយើងអាចសួរថា តើអ្វីៗដែលបាត់បង់ទៅហើយ ទោះជាជីវិតមនុស្សក្តី រាល់សម្ភារផ្សេងៗក្តី តើបានវិលមកដល់ដៃយើងគ្រប់គ្នាដូចដើមដែរឬទេ? អត់! ដូច្នេះ ដែលត្រូវការបំផុតហើយចាំបាច់បំផុតនោះគឺ÷

មនុស្សសំខាន់ៗដែលធ្លាប់ដឹកនាំគ្រប់គ្រងរបបនោះ ត្រូវតែក្លាហានហ៊ានសម្តែងនូវវិប្បដិសារីស្តាយក្រោយអំពីកំហុសធ្ងន់ៗដែលចង្អោមខ្លួនកាលនោះបានចាត់បញ្ជាឲ្យអនុវត្តដោយចេតនា ឬក៏ដោយចាញ់កល្បិចនៃបនណាមួយបន្ទំជ្រកនៅពីក្រោយខ្នងហ៊ានទទួលស្គាល់ដោយស្មោះនូវកំហុសរបស់ខ្លួនក្នុងឋានៈមុខនាទីដឹកនាំគ្រប់គ្រងរបស់ខ្លួន ។ នេះជាប្រការសំខាន់និងចាំបាច់បំផុត ។

២) អង្គសវនាការកាត់ក្តីមួយតាមស្តង់ដារអន្តរជាតិត្រូវតែបង្កើតឡើងឲ្យបានឆាប់រហ័ស ចាប់ដំណើរការជម្រះក្តីឲ្យបានសមស្របតាមបំណងប្រាថ្នារបស់មតិជាតិនិងអន្តរជាតិ ។ កុំយកលេសអូសបន្លាយពេលវេលាឲ្យកន្លងហួសឥតប្រយោជន៍ ។ ទាមទារយកតាមស្តង់ដារអន្តរជាតិជាប្រការចាំបាច់ ពីព្រោះការបាត់បង់ជីវិតមនុស្សក្នុងរបប៣ឆ្នាំ៨ខែ២០ថ្ងៃ ពាក់ព័ន្ធជីវិតមនុស្សច្រើនពូជសាសន៍នៃ «ជីវិតមនុស្សជាតិ» ។

៣) ឧបមាអង្គជំនុំជម្រះបានសម្រេចកាត់ក្តីថាៈ ជនណាមួយត្រូវទទួលទោសដល់ជីវិត ឬក៏ទោសនៃបទល្មើសកម្រិតណា... ពេលនោះក្នុងនាមជាប្រមុខរដ្ឋាភិបាល យោងការចាំបាច់ផ្សេងៗពាក់ព័ន្ធវាសនាប្រទេសជាតិ គាត់តែងជាសារលិខិតក្រាបទូលថ្វាយព្រះមហាក្សត្រ សូមព្រះអង្គទ្រង់ព្រះសណ្តោសទោសលើកលែងដល់ពួកគេ ។ ពេលនោះប្រជាពលរដ្ឋខ្មែររួមមតិអន្តរជាតិផងដែរ ប្រាកដជាមានអារម្មណ៍រីករាយស្កប់ចិត្ត ពីព្រោះគេបានទទួលនូវការបំភ្លឺគ្រប់ជ្រុងជ្រោយពីសំណាក់កសិណសាក្សីនិងសេចក្តីសម្រេចរបស់អង្គសវនាការ ។

តើមានប្រយោជន៍អ្វីបើសិនជាយើងចង់សងសឹកដោយគំនិតយកពៀរទៅចងពៀរនោះ? ការចាប់ផ្តើមសាមគ្គីផ្លូវមួយបង្រួបបង្រួមជាតិចាប់ពីពេលនោះទៅ នោះខ្លឹមសារស្នូលសំខាន់ប្រាកដឲ្យលទ្ធផលជាវិជ្ជមាន ។ នោះជាមេរៀន ត្រូវជៀសវាងដាច់ខាត ។

**នូរ ហ៊ាន់**




*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្ដីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ពត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 44, August 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**